ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


វិទ្យាស្ថានជាតិអប់រំ


# និក្ខេបបទ

## ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងបណ្ណាល័យ នៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា (ករណីសិក្សានៅខេត្តស្វាយរៀង)

## The Situation of Library Management in High Schools Compared to a Standart Library of Secondary Education Study Case: Svay Rieng Province


ដោយ / By

**កុល ថាន**

KOL THAN


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥

ឆ្នាំសិក្សា ២០១៦-២០១៨


ឧបត្ថម្ភដោយ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា

( ករណីសិក្សានៅខេត្តស្វាយរៀង )

**The Situation of Library Management in High Schools Compared**

**to a Standart Library of Secondary Education**

**Study Case: Svay Rieng Province**

ដោយ / By

កុល ថាន

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥

ឆ្នាំសិក្សា ២០១៦-២០១៨

ឧបត្ថម្ភដោយ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា

( ករណីសិក្សាខេត្តស្វាយរៀង )

## The Situation of Library Management in High Schools Compared to a Standart Library of Secondary Education

## Study Case: Svay Rieng Province

ដោយ / By

**កុល ថាន**

KOL THAN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥

**សាស្ត្រាចារ្យណែនាំ:** លោកបណ្ឌិត នី រដ្ឋា

**សាស្ត្រាចារ្យជំនួយ:** លោក សៀង ឆាសនា

ឆ្នាំសិក្សា ២០១៦-២០១៨

វិទ្យាស្ថានជាតិអប់រំ ភ្នំពេញ កម្ពុជា

National Institute of Education ( NIE )

Phnom Penh, Kingdom of Cambodia

គណៈកម្មការវាយតម្លៃនៃការការពារនិក្ខេបបទ

សម្រាប់កម្មវិធី ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ

វិទ្យាស្ថានជាតិអប់រំ

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា (ករណីសិក្សាខេត្តស្វាយរៀង)

## The Situation of Library Management in High Schools Comparedto a Standart Library of Secondary Education

Study Case: Svay Rieng Province

និក្ខេបបទនេះ ត្រូវ បានឯកភាពដោយៈ

១.សាស្ត្រាចារ្យណែនាំ:

បណ្ឌិត នី រដ្ឋា

២.តំណាងវិទ្យាស្ថានជាតិអប់រំ:

ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

៣.តំណាងគណៈកម្មការវាយតម្លៃ:

ឯកឧត្តមបណ្ឌិត ជ័យ សារិន

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទ សូមប្រកាសអះអាងថា និក្ខេបបទដែលមានចំណងជើងថា៉ **ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា**៉ សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនេះគឺជាស្នាដៃសិក្សាស្រាវជ្រាវ របស់ខ្ញុំពិតប្រាកដមែន ។ ហើយស្នាដៃនេះមិនដែលបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រ នៅវិទ្យាស្ថាន និងសាកលវិទ្យាល័យណាមួយឡើយ ។ បន្ថែមលើនេះទៅទៀតរាល់សេចក្តីដកស្រង់និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់ នៅក្នុងអត្ថបទនេះសុទ្ធតែបានចុះបញ្ជី ក្នុងឯកសារយោងទាំងអស់ ។

និក្ខេបបទសិក្សាស្រាវជ្រាវខាងលើពិតជាត្រូវបានសិក្សា និងចងក្រងដោយខ្ញុំបាទពិតប្រាកមែន ។

ថ្ងៃ...............................ខែ ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...................ខែ........................ឆ្នាំ ២០១៨

ហត្ថលេខាបេក្ខជន

# **សេចក្តីបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ**

យើងខ្ញុំជាសាស្ត្រាចារ្យដឹកនាំ និងណែនាំ ការសិក្សាស្រាវជ្រាវលើនិក្ខេបបទនេះ សូមបញ្ជាក់ថា បេក្ខជន កុល ថាន ពិតជាបានសិក្សាស្រាវជ្រាវ និងសរសេរនិក្ខេបបទ ខាងលើពិតប្រាកដមែន។

ថ្ងៃ..............................ខែ ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...................ខែ........................ឆ្នាំ ២០១៨

ហត្ថលេខា

**បណ្ឌិត នី រដ្ឋា**

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវមួយនេះអាចសម្រេច ដល់គោលដៅប្រកបដោយភាពជោគជ័យគឺ ដោយ-សារមាន ការចូលរួមយ៉ាងសកម្ម ពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនានា ដែលបានចូលរួមផ្តល់ឱកាស ជួយសម្របសម្រួល និងជ្រោមជ្រែង តាំងពីដើមរហូតដល់ចប់ ។ ហេតុនេះខ្ញុំបាទដែលជាអ្នកសិក្សាស្រាវជ្រាវ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មាន និងការឧបត្ថម្ភ និងផ្តល់ឱកាសឱ្យខ្ញុំបានរៀនសូត្រ ទទួលបានផ្លែផ្កា ដូចសព្វថ្ងៃ។

ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ឱ្យខ្ញុំបាទមានឱកាសបន្តការសិក្សានៅទីនេះ ។

គណៈគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់។

លោកបណ្ឌិត នី រដ្ឋា ដែលជាសាស្ត្រាចារ្យដឹកនាំ និងណែនាំ ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោក ក្នុងការផ្តល់គំនិតណែនាំ ជាពុទ្ធិ ទ្រឹស្តីល្អៗ និងផ្តល់កម្លាំងចិត្ត បញ្ញា ស្មារតី បច្ចេកទេស វិធីសាស្ត្រនានា មិនតែប៉ុណ្ណោះ លោកបានផ្តល់ ជាឯកសារ ដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញ ទិសដៅដល់រូបខ្ញុំរហូតការសិក្សាស្រាវជ្រាវនេះ ទទួលបាន ជោគជ័យជាស្ថាពរ ។

មិត្តរួមថ្នាក់ជំនាន់ទី៥ ទាំងអស់ដែលតែងតែផ្តល់កម្លាំងចិត្តដល់រូបខ្ញុំបាទ តាមរយៈចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយ ដើម្បីសម្រេចគោលដៅ ។

លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សតាមសាលាគោលដៅទាំងអស់ ដែលបានចូល រួមសម្របសម្រួល ឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការចុះប្រមូលទិន្នន័យ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបាន ជោគជ័យ។

ជាទីបញ្ចប់នេះខ្ញុំបាទសូមគោរពជូនពរ និងប្រសិទ្ធពរ ជូនដល់ លោកអ្នកដ៏មានគុណទាំងពីរ

ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជននិងកីឡា និងឯកឧត្តម លោក លោកជំទាវ លោក លោកស្រី តំណាងអង្គការ CIESF ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យជាតិ និងអន្តជាតិ ទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ មានសុខភាពល្អបរិបូណ៌ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប

បណ្ណាល័យជាមជ្ឈមណ្ឌលនៃឯកសារ និងជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ដែលជួយឱ្យវិស័យអំណានមានភាពរីកចម្រើន ។ ដោយយល់ឃើញថាបណ្ណាល័យមានសារៈសំខាន់បែបនេះ អ្នកសិក្សាស្រាវជ្រាវ បានជ្រើសរើសយកប្រធានបទស្តីពី **"ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា"** មកសិក្សាស្រាវជ្រាវ ។

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងនៅតាមវិទ្យាល័យចំនួនប្រាំពីរ ក្នុងចំណោម វិទ្យាល័យទាំង ១៩ក្នុងខេត្តស្វាយរៀង ។ ការសិក្សាស្រាវជ្រាវនេះផ្តោតលើកម្រិតអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យនានា ហើយធ្វើការប្រៀបធៀបទៅនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា ឆ្នាំ២០១៤ ដោយមានគោលបំណងដើម្បីរកឱ្យឃើញកម្រិតអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ និងបញ្ហាប្រឈមផ្សេងៗ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា ។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍កម្រងសំណួរ ដើម្បីធ្វើការចុះប្រមូលទិន្នន័យបឋមនៅតាមវិទ្យាល័យគោលដៅ ដោយផ្តល់ជូននាយកសាលា ៧នាក់ គ្រូបង្រៀន៧០នាក់ សិស្ស១៤០នាក់បំពេញ និងធ្វើសម្ភាសន៍បណ្ណារក្ស៧នាក់ ក្នុងបន្ទប់បណ្ណា-ល័យ ។ ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវបានយកមកវិភាគតាមកម្មវិធី SPSS និង Exel ដោយវិភាគតាម Frequencies And Descriptive ដោយបង្ហាញជាតារាងស្ថិតិ និងដ្យាក្រាម ។ ការសិក្សាស្រាវជ្រាវ នេះបានរកឃើញថា ការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅវិទ្យាល័យមានសាលាធនធានមានចំណុចល្អច្រើនដូចជា ការបំពាក់ធនធានសម្ភារបរិក្ខារ ឯកសារ ការអនុវត្តការងាររដ្ឋបាល និងបច្ចេកទេស ។ រីឯវិទ្យាល័យគ្មានសាលាធនធានការអនុវត្ត ការគ្រប់គ្រងបណ្ណាល័យ នៅមានកម្រិតទាបដូចជា បន្ទប់បណ្ណាល័យជាបន្ទប់រៀនតូចចង្អៀត ការបំពាក់ធនធានសម្ភារ បរិក្ខារ ឯកសារមានតិចតួច ។ ទាំងវិទ្យាល័យមានសាលាធនធាន និងវិទ្យាល័យគ្មានសាលាធនធាន មានបញ្ហាប្រឈមជារួម គឺធនធានបណ្ណារក្សនៅមានកម្រិតទាបមិនបានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រងបណ្ណាល័យ ចំណេះដឹងភាសាអង់គ្លេស កុំព្យូទ័រ និងអង់គ្លេសទាប និងការចុះពិនិត្យតាមដានរបស់ថ្នាក់ក្រោមជាតិនៅមានកម្រិតទាបនៅឡើយ ។ ក្រៅពីនេះ វិទ្យាល័យគ្មានសាលាធនធាន ក៏មានបញ្ហាប្រឈមផ្សេងទៀតដែរដូចជានិ-យ័តភាពការងារបណ្ណារក្សនៅមានកម្រិត ខ្វះបណ្តាញអគ្គិសនីប្រើប្រាស់ ការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងសាលា ការជំរុញសិស្សចូលអាន ការបំពាក់សម្ភារបរិក្ខារក្នុងបណ្ណាល័យ ។

# Abstract

Library is the center of documents and of lifelong learning, which helps enhance reading sector. Having seen such a vital role of the library, the researcher decides to choose a topic for his thesis, "**the situation of library management in high schools compared to a standard library of secondary education**".

This study investigated in seven out of 19 high schools in Svay Rieng Province, focusing on the level of library management in high schools and comparing the found situation to 2014 standard library of secondary education to find the level of practice of library management in high schools and the challenges compared to standard library of secondary education. The researcher used the questionnaire to collect primary data from the selected high schools: 7 school principals, 70 teachers, and 140 students filled in the questionnaire and 7 librarians were interviewed in the library rooms. The Researcher used SPSS and Excel to analyze the collected data in Frequencies and Descriptives method and the data was shown in statistic tables and diagrams. The findings showed that there were many good points in the practice of library management in the high schools which had resource buildings in terms of library equipment installation, document arrangement, and administrative and technical work. However, the high schools which did not have resource buildings were in low level of practice: the libraries were cramped classrooms, little library equipment was installed, and there were few books in the libraries. The common problems all the selected high schools face were the poor abilities of untrained librarians in library management, English knowledge, and Computer skill and the limited monitoring of the sub-national management. There were some other challenges such as poor regularity of the librarians, lack of electricity and library equipment and poor attention of the school management team in encouraging students to read.

# មាតិកា

ទំព័រ

សេចក្តីប្រកាសអះអាងរបស់បេក្ខជន……………………………………………………………..i

សេចក្តីបញ្ជាក់របស់សាស្ត្រាចារ្យដឹកនាំ……………………………………………………….ii

សេចក្តីថ្លែងអំណរគុណ…………………………………………………………………………..iii

មូលន័យសង្ខេប……………………………………………………………………………………V

Abstract…………………………………………………………………………………..…Vi

មាតិកា.........................................................................................................Vii

បញ្ជីតារាង.....................................................................................................Xi

បញ្ជីរូបភាព...............................……………………………………………………........Xiii

## ជំពូកទី១ សេចក្តីផ្តើម

១.១ លំនាំបញ្ហា.............................................................................................១

១.២ ចំណោទបញ្ហា.........................................................................................២

១.៣ សំណួរស្រាវជ្រាវ.....................................................................................៣

១.៤ គោលបំណងនៃការស្រាវជ្រាវ....................................................................៤

១.៥ ដែនកំណត់នៃការស្រាវជ្រាវ.......................................................................៤

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ......................................................................៥

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......................................................................៥

## ជំពូកទី២ ការរំលឹកទ្រឹស្តី

២.១ និយមន័យពាក្យគន្លឹះ...............................................................................៧

២.២ ប្រវត្តិបណ្ណាល័យ..........៨
២.២.១ ប្រវត្តិបណ្ណាល័យនៅលើពិភពលោក..........៨
២.២.២ ប្រវត្តិបណ្ណាល័យនៅកម្ពុជា..........១០
២.២.២.១ បណ្ណាល័យសាសនបណ្ឌិត..........១១
២.២.២.២ បណ្ណាល័យជាតិកម្ពុជា..........១០
២.៣ តួនាទីបណ្ណារក្ស..........១១
២.៤ សារៈសំខាន់នៃបណ្ណាល័យ..........១២
២.៥ ការគ្រប់គ្រងបណ្ណាល័យ..........១២

## ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ

៣.១ ការជ្រើសរើសសំណាក..........១៥
៣.២ ឧបករណ៍ស្រាវជ្រាវ..........១៥
៣.៣ កម្រងសំណួរ និងគោលបំណង..........១៦
៣.៣.១ កម្រងសំណួរសម្រាប់បណ្ណារក្ស..........១៦
៣.៣.២ កម្រងសំណួរសម្រាប់នាយកសាលា..........១៦
៣.៣.៣ កម្រងសំណួរសម្រាប់គ្រូ..........១៧
៣.៣.៤ កម្រងសំណួរសម្រាប់សិស្ស..........១៧
៣.៤ ដំណើរកាប្រមូលទិន្នន័យ..........១៦
៣.៥ ការវិភាគទិន្នន័យ..........១៨
៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ..........១៨

## ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

៤.១ លទ្ធផលនៃការស្រាវជ្រាវ..........១៩

៤.១.១ អ្នកចូលរួមផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ..........................................................១៩

៤.១.២ ធនធានមនុស្ស ការបំប៉នសមត្ថភាព ការប្រជុំ ការចុះពិនិត្យតាមដាន.........................២១

៤.១.២.១ ធនធានមនុស្ស..................................................................................២១

៤.១.២.២ ការប្រជុំក្នុងសាលា................................................................................២៦

៤.១.២.៣ ការចុះពិនិត្យតដានរបស់ថ្នាក់លើ លើការងារគ្រប់គ្រងបណ្ណាល័យ.............២៧

៤.១.៣ ស្ថានភាពបណ្ណាល័យ ធនធានសម្ភារ និងធនធានឯកសារ.....................................២៨

៤.១.៣.១ ស្ថានភាពអគារ បន្ទប់បណ្ណាល័យ......................................................២៨

៤.១.៣.២ ស្ថានភាពសម្ភារ បរិក្ខារ បំពាក់ក្នុងបណ្ណាល័យ........................................២៩

៤.១.៣.៣ ធនធានឯកសារក្នុងបណ្ណាល័យ..........................................................៣១

៤.១.៤ ការងារបច្ចេកទេស រដ្ឋបាល និងសេវាកម្មបណ្ណាល័យ...........................................៣៣

៤.១.៤.១ ការងារបច្ចេកទេស និងរដ្ឋបាល.........................................................៣៣

៤.១.៤.២ សេវាកម្មបណ្ណាល័យ..........................................................................៣៧

៤.១.៥ ទស្សនៈ នាយកសាលា បណ្ណារក្ស គ្រូ សិស្ស ....................................................៣៩

៤.១.៥.១ ការយល់ឃើញរបស់គ្រូពីសារៈសំខាន់ និងសេវាកម្មបណ្ណាល័យ................៣៩

៤.១.៥.២ ស្ថានភាពរបស់គ្រូក្នុងការប្រើប្រាស់សេវាកម្មបណ្ណាល័យលើការបង្រៀន.....៣៩

៤.១.៥.៣ ការយល់ឃើញរបស់គ្រូលើទម្លាប់អានរបស់សិស្ស..................................៤០

៤.១.៥.៤ បញ្ហាប្រឈមពាក់ព័ន្ធនឹងបណ្ណាល័យ...................................................៤២

៤.១.៥.៥ សំណូមពរផ្សេងៗរបស់អ្នកចូលរួមឆ្លើយសំណួរ ....................................៤៤

៤.២ ការពិភាក្សា .......................................................................................................៤៧

៤.២.១ ការយល់ឃើញរបស់នាយកសាលា បណ្ណាររក្ស គ្រូ សិស្ស លើការគ្រប់គ្រងបណ្ណាល័យ..........៤៧

៤.២.២ ស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យ...........................................................................៤៨

## ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១ សេចក្តីសន្និដ្ឋាន.....៥១

៥.២ សំណូមពរ.....៥២

**ឯកសារយោង**.....៥៥

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១ ស្តង់ដាបណ្ណាល័យមធ្យមសិក្សា

ឧបសម្ព័ន្ធទី២ កម្រងសំណួរស្រាវជ្រាវ

## បញ្ជីតារាង

តារាងទី១៖ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ.....១៩

តារាងទី២៖ ចំនួននាយកសាលា បណ្ណារក្ស គ្រូបង្រៀនចូលរួមតាមមុខវិជ្ជាឯកទេស.....២០

តារាងទី៣៖ ចំនួនបណ្ណារក្សសរុបមធ្យម និងចំនួនថ្នាក់សរុបមធ្យម.....២១

តារាងទី៤៖ ចំនួនបណ្ណារក្សតាមអាយុ.....២១

តារាងទី៥៖ កម្រិតវិជ្ជាជីវៈបណ្ណារក្ស.....២២

តារាងទី៦៖ កម្រិតវប្បធម៌បណ្ណារក្ស.....២២

តារាងទី៧៖ ស្ថានភាពបន្ទប់បណ្ណាល័យនៃវិទ្យាល័យគ្មានសាលាធនធានទាំងប្រាំ.....២៨

តារាងទី៨៖ ចំនួនសិស្សសរុបមធ្យមនៃវិទ្យាល័យគ្មានសាលាធនធាន.....២៩

តារាងទី៩៖ ចំនួនសៀវភៅសិក្សាគោល និងសៀវភៅគ្រូ សម្រាប់សិស្សគ្រូ ស្រាវជ្រាវ.....៣១

តារាងទី១០៖ យោបល់សិស្សលើស្ថានភាពសៀវភៅអានសម្រាប់ស្រាវជ្រាវក្នុងបណ្ណាល័យ.....៣៣

តារាងទី១១៖ ការចុះបញ្ជីរួម បញ្ជីសារពើភ័ណ្ឌ ការរៀបចំសៀវភៅចូលធ្នើ ការចុះលេខកូដដឺវ៉េ ការរៀបចំ
បទបញ្ជាផ្ទៃក្នុង ការរៀបចំឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន ការរៀបចំបញ្ជីខ្ចីសងនៃ

វិទ្យាល័យគ្មានសាលាធនធាន ...........................................................................................៣៤
តារាងទី១២ ការចុះបញ្ជីរួម បញ្ជីសារពើភ័ណ្ឌ ការរៀបចំសៀវភៅចូលធ្នើ ការចុះលេខកូដឌីវេ ការរៀបចំ
បទបញ្ជាផ្ទៃក្នុង ការរៀបចំឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន ការរៀបចំបញ្ជីខ្ចីសងនៃ
វិទ្យាល័យមានសាលាធនធាន ...........................................................................................៣៤
តារាងទី១៣៖ ការយល់ឃើញរបស់គ្រូលើបញ្ហាប្រឈមពាក់ព័ន្ធនឹងបណ្ណាល័យ...............................៤២
តារាងទី១៤៖ ការយល់ឃើញរបស់នាយកសាលាលើបញ្ហាប្រឈមពាក់ព័ន្ធនឹងបណ្ណាល័យ...............៤២
តារាងទី១៥៖ ការយល់ឃើញរបស់បណ្ណារក្សលើបញ្ហាប្រឈមបណ្ណាល័យ.....................................៤៣
តារាងទី១៦៖ សំណូមពររបស់គ្រូ.........................................................................................៤៤
តារាងទី១៧៖ សំណូពររបស់សិស្ស.......................................................................................៤៥
តារាងទី១៨៖ សំណូមពររបស់នាយកសាលា ...........................................................................៤៦
តារាងទី១៩៖ សំណូមពររបស់បណ្ណារក្ស................................................................................៤៦

## បញ្ជីរូបភាព

ដ្យាក្រាមទី១៖ ចំនួនសិស្សតាមកម្រិតថ្នាក់..................................................................................២០
ដ្យាក្រាមទី២៖ អតីតភាពការងារក្នុងមុខតំណែងរបស់នាយកសាលា បណ្ណារក្ស គ្រូបង្រៀន................២១
ដ្យាក្រាមទី៣៖ ចំណេះដឹងភាសាអង់គ្លេសបណ្ណារក្ស.....................................................................២៤
ដ្យាក្រាមទី៤៖ ចំណេះដឹងកុំព្យូទ័របណ្ណារក្ស................................................................................២៤
ដ្យាក្រាមទី៥៖ ការបំប៉នសមត្ថភាពបណ្ណារក្សស្ដីពីជំនាញគ្រប់គ្រងបណ្ណាល័យ.................................២៥
ដ្យាក្រាមទី៦៖ ការធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្ដូរបទពិសោធន៍របស់បណ្ណារក្ស...................................២៦
ដ្យាក្រាមទី៧៖ ការបញ្ចូលប្រធានបទបណ្ណាល័យក្នុងរបៀបវារៈប្រជុំប្រចាំខែ....................................២៧
ដ្យាក្រាមទី៨៖ ចំនួនសាលាដែលថ្នាក់លើបានចុះពិនិត្យតាមដាន...................................................២៧
ដ្យាក្រាមទី៩៖ ចំនួនធ្នើមុខមួយ និងធ្នើមុខពីរសម្រាប់ដាក់សៀវភៅក្នុងបណ្ណាល័យ...........................២៩

ដ្យាក្រាមទី១០៖ ស្ថានភាពនៃការប្រើប្រាស់បណ្តាញអ៊ិនធឺណិតក្នុងបណ្ណាល័យ................................៣០
ដ្យាក្រាមទី១១៖ ចំនួនសៀវភៅអាន ក្រៅពីសៀវភៅសិក្សាគោលគិតជាមធ្យម................................៣២
ដ្យាក្រាមទី១២៖ ការសម្អាតបណ្ណាល័យ..........................................................................................៣៥
ដ្យាក្រាមទី១៣៖ ការណែនាំសិស្សចូលអានក្នុងបណ្ណាល័យ..........................................................៣៦
ដ្យាក្រាមទី១៤៖ ការគោរពពេលម៉ោងធ្វើការ......................................................................................៣៧
ដ្យាក្រាមទី១៥៖ ស្ថិតិសិស្ស គ្រូ អ្នកក្រៅ ចូលអានក្នុងបណ្ណាល័យប្រចាំខែជាមធ្យម..........................៣៨
ដ្យាក្រាមទី១៦៖ ទស្សនៈរបស់គ្រូលើបណ្ណាល័យទាក់ទងការរៀនសូត្ររបស់សិស្ស..........................៣៩
ដ្យាក្រាមទី១៧៖ ភាពញឹកញាប់របស់គ្រូលើការប្រើប្រាស់សេវាកម្មបណ្ណាល័យ................................៤០
ដ្យាក្រាមទី១៨៖ ការយល់ឃើញរបស់គ្រូ លើទម្លាប់អានរបស់សិស្ស..............................................៤០
ដ្យាក្រាមទី១៩៖ ទស្សនៈរបស់គ្រូចំពោះសេវាកម្មបណ្ណាល័យសាលារបស់ខ្លួន ................................៤១

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## *១.១ លំនាំបញ្ហានៃការស្រាវជ្រាវ*

ប្រទេសកម្ពុជាជាប្រទេសមួយដែលបានឆ្លងកាត់សង្គ្រាមជាញឹកញាប់ ។ ក្នុងរបបខ្មែរក្រហមបានបំផ្លិចបំផ្លាញ វប្បធម៌ខ្មែរ ហេដ្ឋារចនាសម្ព័ន្ធ បំបាត់មិនឱ្យមានវត្តអារាម សាលារៀន ទំនៀមទំលាប់រៀបអាពាហ៍ពិពាហ៍ ការបង្ខំមនុស្សឱ្យ ធ្វើការលើសកម្លាំង ការកាប់សម្លាប់មនុស្សយ៉ាងព្រៃផ្សៃ។ តែក្រោយសម័យរំដោះ ៧មករា ឆ្នាំ ១៩៧៩ មក សេដ្ឋកិច្ចប្រទេសជាតិ និងវប្បធម៌ខ្មែរត្រូវបានស្តារឡើងវិញ ជាបន្តបន្ទាប់។ សព្វថ្ងៃរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់អភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ដោយបានបង្កើតយុទ្ធសាស្រ្តចតុកោណ នីតិកាលទី៥ ដំណាក់កាលទី៣ ដែលមានចតុកោណបួនគឺ ចតុកោណទី១ ការលើកស្ទួយវិស័យកសិកម្ម ចតុកោណទី២ ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ចតុកោណទី៣ ការអភិវឌ្ឍវិស័យឯកជននិងការងារ និងចតុកោណទី៤ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស (សម្តេច ហ៊ុន សែន ឆ្នាំ ២០១៣) ។ ស្របជាមួយចតុកោណទីបួនខាងលើ ក្រសួងអប់រំបានបង្កើតផែនការយុទ្ធ-សាស្រ្តវិស័យអប់រំ (២០១៤ – ២០១៨) ដែលក្នុងនោះមានការកំណត់នូវគោលនយោបាយចំនួនពីរគឺ (១) ការធានា បានការអប់រំប្រកបដោយសមធម៌ និង(២) លើកកម្ពស់គុណភាព និងភាពឆ្លើយតប (ក្រសួងអប់រំ យុវជន និងកីឡា ២០១៤)។ ដើម្បីធានាបាននូវផែនការយុទ្ធសាស្រ្តខាងលើ ក្រសួងអប់រំបានបង្កើតឱ្យមានសាលាធនធាន នៅតាមរាជធានី ខេត្តក្រុង ដើម្បីធានាបានការបង្រៀននិងរៀន ឱ្យកាន់តែមានភាពល្អប្រសើរជាងមុន។ ជាពិសេសសាលាធនធានដែលបានសាងសង់ឡើង ត្រូវបានរៀបចំឱ្យមាន បន្ទប់ពិសោធសម្រាប់ធ្វើការពិសោធលើមុខវិជ្ជាវិទ្យាសាស្រ្ត បន្ទប់កាត់ដេរ បន្ទប់កុំព្យូទ័រ សាលប្រជុំ បន្ទប់សាស្រ្តាចារ្យ និងបន្ទប់បណ្ណាល័យមានលក្ខណៈធំទូលាយ ដែលបំពាក់ដោយបរិក្ខារ និងឯកសារអានច្រើនប្រភេទ សម្រាប់សិស្ស គ្រូ ធ្វើការសិក្សាស្រាវជ្រាវបន្ថែម។ ស្របជាមួយគ្នានេះដែរនៅក្នុងខេត្តស្វាយរៀង ក្រសួងអប់រំបានសាងសង់សាលាធនធានចំនួនពីរ និងបានដាក់ឱ្យដំណើររួចហើយ។ សាលាធនធានទាំងពីរនោះ គឺ សាលាធនធានស្វាយរៀង និងសាលាធនធានហ៊ុនសែនប្រសូតិ។ ចំណែកវិទ្យាល័យ អនុវិទ្យាល័យដែលនៅក្បែរៗសាលាធនធាន អាចចូលជាសាលាសម្ព័ន្ធ ឬជាសាលាបណ្តាញ នៃសាលាធនធានដើម្បីបានប្រើប្រាស់សាលាធនធាន ក្នុងការបង្រៀន និងរៀនផងដែរ (ក្រសួងអប់រំ យុវជន និងកីឡា ២០០៨, និង ២០១៦)។

ក្រៅពីរៀបចំឱ្យមានសាលាធនធាននៅតាមរាជធានីខេត្ត ក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋាភិបាលនិងទំនាក់ទំនងសប្បុរសជន ដៃគូអភិវឌ្ឍន៍នានាចូលរួមកសាងបណ្ណាល័យល្អៗនៅក្នុងប្រទេសរបស់យើង ដូចជា បណ្ណាល័យជាតិ បណ្ណាល័យសម្តេចហ៊ុនសែន បណ្ណាល័យបារាំង ... មានទីតាំងក្នុងរាជធានីភ្នំពេញជាបណ្ណាល័យធំៗមានឯកសារសម្បូរបែបសម្រាប់អ្នកសិក្សាធ្វើការសិក្សាស្រាវជ្រាវ ។ ចំពោះថ្នាក់តំបន់ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដូចជា អង្គការ Kape អង្គការ Childfund អង្គការ Roomtoread ។ ដើម្បីធានាបានគុណភាពនៃការបង្រៀន អង្គការទាំងនោះបានជួយវិស័យអប់រំ យ៉ាងច្រើនដូចជា ការផ្តល់សម្ភារសិក្សាសម្រាប់សិស្សក្រីក្រ ផ្តល់កុំព្យូទ័រសម្រាប់សិស្សសិក្សាក្នុងសាលា សាងសង់បណ្ណាល័យ និងផ្តល់ឯកសារដល់បណ្ណាល័យសម្រាប់សិស្សធ្វើការសិក្សាស្រាវជ្រាវព្រមទាំងបណ្តុះបណ្តាលជំនាញបណ្ណាល័យដល់បណ្ណារក្សផងដែរ។ បើតាមប៉ុលប៊ូដេ លេខ២ ឆ្នាំ ២០០៦ បានឱ្យដឹងថា អង្គការ រូមធូរីដ បានជួយសាងសង់បណ្ណាល័យ ចំនួន ៦០៧ ដែលបំពាក់ទៅដោយ ទូ ធ្នើ ឯកសារ...។ បណ្ណាល័យទាំងនោះស្ថិតនៅក្នុងរាជធានីខេត្តមួយចំនួនដូចជា រាជធានីភ្នំពេញ សៀមរាប កំពង់ធំ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងព្រះវិហារ ។

លើសពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡាក៏បានយកចិត្តទុកដាក់រៀបចំវគ្គបណ្តុះបណ្តាលបណ្ណារក្ស នាយកសាលា ស្តីពីការងារគ្រប់គ្រង និងស្តង់ដាបណ្ណាល័យបឋមសិក្សា ហើយក្រសួងបានសហការ ជាមួយអង្គការ**អេដអេអាក់ស្យុង** បង្កើតបណ្ណាល័យ អេឡិចត្រូនិច ១០សាលា ដើម្បីការរៀន និងការបង្រៀន តាមប្រព័ន្ធអេឡិចត្រូនិច (សន្និបាតអប់រំ យុវជន និងកីឡា ឆ្នាំ២០១៦ - ២០១៧) ។ បន្ថែមពីនេះ ដើម្បីធានាបានការស្រាវជ្រាវបន្ថែមរបស់សិស្ស នៅតាមវិទ្យាល័យនានាក្នុងខេត្តស្វាយរៀង ថ្នាក់ក្រសួងអប់រំ ក៏ដូចថ្នាក់មន្ទីរអប់រំ ក៏បានជំរុញឱ្យវិទ្យាល័យនីមួយៗដែលមិនមានសាលាធនធាន ឱ្យរៀបចំបណ្ណាល័យមួយក្នុងសាលា ដើម្បីធ្វើជាកន្លែងសម្រាប់ស្តុកសៀវភៅ ជាបន្ទប់សម្រាប់សិស្សចូលអង្គុយអានខ្ចីសៀវភៅ និងធានាបានដំណើរការប្រតិបត្តិការឱ្យមានប្រសិទ្ធភាព។

### *១.២ ចំណោទបញ្ហាស្រាវជ្រាវ*

បណ្ណាល័យដែលមានលក្ខណៈស្តង់ដា ជាបណ្ណាល័យគំរូ ដែលធានាបាននូវ អ្នកគ្រប់គ្រងបណ្ណាល័យ បណ្ណារក្ស អនុវត្តការបំពេញការងាររបស់ខ្លួនបានល្អ។ បណ្ណាល័យមួយដែលមានសៀវភៅអានតាមតម្រូវការរបស់សិស្ស និងមានបណ្ណារក្ស ដែលចូលចិត្តអាននិងប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ នោះនឹងបង្កើននូវចំណាប់អារម្មណ៍អាន និងទម្លាប់អានដល់សិស្សយ៉ាងប្រសើរ (Bamberger, 1975) សិស្សដែលស្រលាញ់ការអាន និងចូលចិត្តអាន ចំណេះដឹងរបស់គេនឹងមានការរីកចម្រើនជាបន្តបន្ទាប់ ហើយប្រទេស

ជាតិសម្បូរទៅដោយធនធានមនុស្សពេញលេញ ។ ប៉ុន្តែការកសាងបណ្ណាល័យមួយ ដែលមានលក្ខណៈស្តង់ដា មានការលំបាក ព្រោះមានតម្រូវការធាតុសំខាន់ជាច្រើននិងគ្រប់គ្រាន់ ដូចជា ធនធានមនុស្ស ធនធានសម្ភារ និងការងារបច្ចេកទេស រដ្ឋបាល ជាដើម (ក្រសួងអប់រំ យុវជន និងកីឡា ២០១៤)។ តាមការសិក្សាស្រាវជ្រាវរបស់ប្រាក់ ទិត្យវ៉ានី ២០១៧ បណ្ណាល័យសាលាវិទ្យាល័យក្នុងរាជធានី ភ្នំពេញ ពុំទាន់មានលក្ខណៈប្រសើរ នៅឡើយទេ ពោលគឺ ឯកសារសម្រាប់អានមិនទាន់មានលក្ខណៈសម្បូរបែប ហើយនាយកសាលាមិនទាន់មានចំណាត់ការ ជំរុញសិស្សឱ្យចូលប្រើប្រាស់បណ្ណាល័យបានច្រើន នៅឡើយ ។ រាជធានីភ្នំពេញជាទីប្រជុំជន ហើយបណ្ណាល័យសាលានៅមានកម្រិតនៅឡើយ នេះអាចសន្និដ្ឋានបានថា នៅទីជនបទ បណ្ណាល័យអាចនៅមានកម្រិតទាបជាងនេះ ការប្រើប្រាស់បណ្ណាល័យសាលានឹងមាន បញ្ហាប្រឈមជាច្រើនមិនខាន។ ម្យ៉ាងវិញទៀត បើតាមឯកសារនៃសន្និបាតអប់រំ ឆ្នាំ២០១៦-២០១៧ បានបង្ហាញថា សាលារៀនមានបណ្ណាល័យចំនួន៣៥៥២ ក្នុងនោះជាអគារចំនួន៦៧៣ ជាបន្ទប់រៀនចំនួន ២៣២៦ ជាទីចាត់ការចំនួន៧៦៤ ជ្រុងថ្នាក់១៧៥ និងបណ្ណាល័យចល័តចំនួន៨០។ ត្រង់នេះបង្ហាញថា នៅតាមសាលារៀននៅមិនទាន់មានបណ្ណាល័យដាច់ដោយឡែក ចំនួនច្រើនទេ ហើយសាលាខ្លះ យកទីចាត់ការ និងជ្រុងថ្នាក់សម្រាប់ធ្វើជាបណ្ណាល័យ ដែលជាចំណុចប្រឈមមួយដល់ការចូលអានរបស់សិស្ស។ ម្យ៉ាងវិញទៀត ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់បំប៉នវគ្គស្តីពី ការងារគ្រប់គ្រង និងស្តង់ដាបណ្ណាល័យបឋមសិក្សា ដល់នាយកសាលា គ្រូឧទ្ទេស បណ្ណារក្ស សាលាបឋមសិក្សា សាលាគរុកោសល្យនិងវិក្រឹតការ ។ ចំណែកបណ្ណារក្ស និងនាយកសាលាមធ្យមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា មិនមាន បង្ហាញពីការបំប៉នវគ្គស្តីពីស្តង់ដាបណ្ណាល័យមធ្យមសិក្សា ក្នុងសន្និបាតប្រចាំឆ្នាំឡើយ។ ដូចនេះ អ្នកស្រាវជ្រាវអាច សន្និដ្ឋានបានថា បណ្ណាល័យសាលាមធ្យមសិក្សាកំពុងមានបញ្ហាប្រឈមលើបញ្ហា កង្វះធនធានមនុស្ស សម្រាប់គ្រប់គ្រងបណ្ណាល័យ។ បើតាមសិក្សាស្រាវជ្រាវរបស់លោកប៉ូលប៊ូដេលេខ២ ឆ្នាំ២០០៦ បានឱ្យដឹងថា ស្ថានភាពបណ្ណាល័យក្នុងប្រទេសកម្ពុជា នៅមានការខ្វះខាតទាំងបរិមាណ ទាំងគុណភាព ដូចជា ចំនួនបណ្ណាល័យនៅមានតិច ឯកសារពុំទាន់មានគ្រប់គ្រាន់តាមតម្រូវការសម្ភារ បរិក្ខារ នៅខ្សត់ខ្សោយ បណ្ណារក្ស មួយភាគធំពុំទាន់ទទួលបានការបណ្តុះបណ្តាលពេញលេញ ត្រឹមត្រូវ តាមបច្ចេកទេសការងារ បណ្ណាល័យនៅឡើយ។

## *១.៣ គោលបំណងនៃការស្រាវជ្រាវ*

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ពីរគឺ ៖ (១) រកឱ្យឃើញកម្រិតអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យធៀបនឹង ស្តង់ដាបណ្ណាល័យមធ្យមសិក្សា និង(២) រកឱ្យឃើញបញ្ហាប្រឈម

នានាក្នុងការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។

### *១.៤. សំណួរស្រាវជ្រាវ*

ការគ្រប់គ្រងបណ្ណាល័យមួយឱ្យមានប្រសិទ្ធភាព និងគុណភាព និងមានលក្ខណៈស្តង់ដា វាជាចំណែកមួយដែល ជួយអភិវឌ្ឍគុណភាពអប់រំ ។ ដើម្បីសម្រេចគោលបំណងខាងលើ ការសិក្សាស្រាវជ្រាវនេះផ្តោតលើសំណួរស្រាវជ្រាវចំនួនបីដូចខាងក្រោម៖

១. តើការអនុវត្តការងារគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យបានកម្រិតណា ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា?

២. តើការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការអនុវត្តការងារគ្រប់-គ្រងបណ្ណាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា?

៣. តើ នាយកវិទ្យាល័យ លោកគ្រូ អ្នកគ្រូ បណ្ណារក្ស និងសិស្សានុសិស្ស មានទស្សនៈ ដូចម្តេចខ្លះចំពោះការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា ?

### *១.៥ ដែនកំណត់នៃការស្រាវជ្រាវ*

អាស្រ័យដោយពេលវេលា ឯកសារដែលពាក់ព័ន្ធនឹងការស្រាវជ្រាវពិបាករក ធនធានមានកំណត់ និងដោយសារកង្វះលទ្ធភាពក្នុងការចុះប្រមូលទិន្នន័យឱ្យបានគ្រប់វិទ្យាល័យទូទាំងប្រទេស ដែលត្រូវការចំណាយច្រើន ដូចនេះការសិក្សាស្រាវជ្រាវនេះ នឹងផ្តោតលើវិទ្យាល័យមួយចំនួនក្នុងខេត្តស្វាយរៀងប៉ុណ្ណោះ។ ការស្រាវជ្រាវនេះ ផ្តោតទៅលើ គ្រូបង្រៀន បណ្ណារក្ស សិស្ស និងនាយកវិទ្យាល័យ។ ភាគ-សំណាកទាំងអស់ នឹងត្រូវជ្រើសរើសយកវិទ្យាល័យចំនួន៧ ក្នុងនោះវិទ្យាល័យមានសាលាធនធាន មានចំនួន២សាលា និងវិទ្យាល័យគ្មានសាលាធនធាន ចំនួន៥សាលា ដែលស្ថិតនៅក្នុងខេត្តស្វាយរៀង។ វិទ្យាល័យដែលមានសាលាធនធានទាំងពីរនោះគឺ វិទ្យាល័យស្វាយរៀង និងវិទ្យាល័យហ៊ុនសែនប្រសូតិ។ ចំណែកវិទ្យាល័យដែលគ្មានសាលាធនធានទាំងប្រាំនោះរួមមាន វិទ្យាល័យហ៊ុនសែនស្វាយជ្រំ វិទ្យាល័យហ៊ុនសែនរមាសហែក វិទ្យាល័យហ៊ុនសែនកំពង់ចក វិទ្យាល័យហ៊ុនសែនចេក និងវិទ្យាល័យហ៊ុនសែនសាមគ្គីដូនស។ យើងនឹងសិក្សាស្រាវជ្រាវដោយរៀបចំតាក់តែងកម្រងសំណួរ សម្រាប់បំពេញ និងធ្វើការសម្ភាស បណ្ណារក្ស គ្រូ សិស្ស នាយកវិទ្យាល័យនៅតាមសាលានីមួយៗ។ ការសម្ភាសផ្តោតលើ សមាសភាគទាំងបីនៃស្តង់ដាបណ្ណាល័យមធ្យមសិក្សារួមមាន **សមាសភាគទី១** ធនធានមនុស្ស ការបំប៉នសមត្ថភាព

ការប្រជុំ ការពិនិត្យតាមដាន **សមាសភាគទី២** ស្ថានភាពបណ្ណាល័យធនធានសម្ភារនិងឯកសារ **សមាសភាគទី៣** ការងារបច្ចេកទេស រដ្ឋបាល និងសេវាកម្មបណ្ណាល័យ។ ចំពោះចំនួនសំណាកដែលត្រូវចូលរួមបំពេញកម្រងសំណួរ រួមមាន នាយកសាលា ៧នាក់ ( ០១នាក់ក្នុងមួយសាលា) គ្រូបង្រៀន ៧០នាក់ (១០នាក់ក្នុងមួយសាលា) សិស្ស ១៤០នាក់ (២០នាក់ ក្នុងមួយសាលា) ។ ចំណែកសំណាកដែលត្រូវចូលរួមសម្ភាសមាន បណ្ណារក្ស ០៧នាក់ ( ១នាក់ក្នុងមួយសាលា)។

## *១.៦ សារៈសំខាន់នៃការស្រាវជ្រាវ*

តាមការបង្ហាញខាងលើ បណ្ណាល័យមានសារៈសំខាន់ណាស់ក្នុងការរួមចំណែក ការអភិវឌ្ឍគុណភាពអប់រំ។ បណ្ណាល័យជាកន្លែងសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាគ្រប់រូប ដែលមានចំណង់ចំណូលចិត្តអានសៀវភៅ ។ បណ្ណាល័យជាកន្លែងបណ្តុះនូវទម្លាប់អានរបស់សិស្ស។ ការសិក្សាស្រាវជ្រាវនេះនឹងធ្វើឱ្យយើងមានការយល់ដឹង កាន់តែច្បាស់លាស់ពីការគ្រប់គ្រង បណ្ណាល័យ និងកំណត់បានពីសារៈសំខាន់ នៃស្តង់ដាបណ្ណាល័យ និងលើកកម្ពស់គុណភាពបណ្ណាល័យ ពិសេសគឺចូលរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពការបង្រៀន និងរៀន ពោលគឺផ្នែកអំណាន។ ការសិក្សាស្រាវជ្រាវនេះ មិនបានធ្វើទូលំទូលាយឱ្យគ្រប់សាលាមធ្យមសិក្សាចំណោះទូទៅ ក្នុងខេត្តស្វាយរៀងក៏ពិតមែន តែវាអាចទុកជាឯកសារសម្រាប់អ្នកស្រាវជ្រាវក្រោយៗយកទៅសិក្សាបន្តទៀត។

## *១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ*

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូក រួមមាន៖

**ជំពូកទី១ សេចក្តីផ្តើម៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវ នឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២ ការរំលឹកទ្រឹស្តី៖** រាល់ទ្រឹស្តីរបស់អ្នកសិក្សាស្រាវជ្រាវមុនៗ ដែលពាក់ព័ន្ធនឹងប្រធានបទនេះ ត្រូវបានលើកឡើងដើម្បីធ្វើជាគំនិត និងឆ្លុះបញ្ចាំង ទៅនឹងការរកឃើញថ្មី នៅក្នុងស្នាដៃស្រាវជ្រាវនេះផងដែរ។

**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញ នូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូសំណាក ព្រមទាំងវិធីសាស្ត្រវិភាគទិន្នន័យដែលប្រមូលបាន ។
**ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវ៖** លទ្ធផលនៃការស្រាវជ្រាវ នឹងត្រូវបានយកមកបកស្រាយ និង

ពិភាក្សា  យ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងវិញ នៅក្នុងស្ថាន ភាពជាក់ស្តែង របស់សាលារៀននីមួយៗ ។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** នេះជាផ្នែកដែលអ្នកស្រាវជ្រាវ ធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលបានយកមកវិភាគ ព្រមទាំងលើកឡើងនូវសំណូមពរ មួយចំនួនក្នុងបំណង លើកកម្ពស់ ការគ្រប់គ្រង បណ្ណាល័យឱ្យមានលក្ខណៈល្អប្រសើរឡើង។

# ជំពូកទី២
# ការរំលឹកទ្រឹស្តី

# ជំពូកទី២

# ការរំលឹកទ្រឹស្តី

បណ្ណាល័យជាកន្លែងអភិវឌ្ឍវិស័យអំណាន និងផ្សព្វផ្សាយការអាន។ ការផ្សព្វផ្សាយការអាន គឺអភិវឌ្ឍចំណេះដឹង អាកប្បកិរិយា និងតម្លៃរបស់កុមារ ដោយភ្ជាប់ជាមួយសេចក្តីត្រូវការ ជាមុនចំពោះសិទ្ធិកុមារដើម្បីទទួលបានការអប់រំ និងវប្បធម៌របស់ពួកគេ (ក្រសួងអប់រំ យុវជន និងកីឡា ២០០៨ ) ។ នៅតាមសាលារៀន តាមរយៈសកម្មភាពអានក្នុងបណ្ណាល័យ ជាកត្តាសំខាន់មួយក្នុងការជំរុញ គុណភាពបង្រៀន និងរៀន ។ ដើម្បីពង្រីកវិសាលភាពការងារបណ្ណាល័យនៅតាមសាលារៀន ឱ្យទទួលបានគុណភាពខ្ពស់ ចំបាច់ត្រូវមានស្តង់ដាបណ្ណាល័យជាក់លាក់ ដែលសំដៅការចូលរួមលើកកម្ពស់ការអាន នៅប្រទេសកម្ពុជាយើងឱ្យមានការរីកចម្រើនជាលំដាប់ ។

## *២.១ និយមន័យនៃពាក្យគន្លឹះ*

- **ការគ្រប់គ្រង** សំដៅដល់ការធ្វើផែនការ ការរៀបចំចាត់ចែង ការដឹកនាំ ការត្រួតពិនិត្យ ធនធានមនុស្ស និងធនធានដ៏ទៃទៀត ដើម្បីសម្រេចគោលដៅរបស់អង្គភាព ឬស្ថាប័ន ប្រកបដោយប្រសិទ្ធភាព (ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)។
- **បណ្ណាល័យ** ជាមជ្ឈមណ្ឌលសិក្សាអស់មួយជីវិត និងជាគ្រឹះស្ថានអប់រំសម្រាប់ជនគ្រប់រូប ដែលធានាលើការការពារសិទ្ធិនៃការអប់រំ (ទូត វាសនា ២០១៦ )
- **បណ្ណាល័យ** ជាកន្លែងសម្រាប់ផ្ទុកសៀវភៅសិក្សាគោល ដ៏មានសុវត្ថិភាពបំផុត ដែលអាច ធានាឱ្យជៀសផុត ពីភាពអន្តរាយនានា ដូចជាពន្លឺ ខ្យល់ ភ្លៀង ធូលី... ដែលនាំឱ្យខូចខាត ឬបាត់បង់។ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៥ )។

  **ស្តង់ដាបណ្ណាល័យ** ជាបណ្ណាល័យគំរូ ដែលធានាបាននូវ អ្នកគ្រប់គ្រងបណ្ណាល័យ បណ្ណារក្ស អនុវត្តការបំពេញការងាររបស់ខ្លួនបានល្អ (ក្រសួងអប់រំ យុវជននិងកីឡា ២០១៤)។
- **បណ្ណាល័យដាច់ដោយឡែក** ជាបណ្ណាលល័យដែលមានអគារដាច់ដោយឡែក មិនមែនជាបន្ទប់-រៀន (ក្រសួងអប់រំ យុវជន និងកីឡា ២០១០ ) ។
- **បណ្ណាល័យបន្ទប់រៀន** ជាបណ្ណាល័យដែលយកបន្ទប់រៀនធ្វើជាបណ្ណាល័យ។
- **បណ្ណាល័យបុរាណ** ជាបណ្ណាល័យដែលមានអគារផ្ទុកសៀវភៅឬឯកសារ មានកន្លែងសម្រាប់អាន និងខ្ចី។ រាល់កំណត់ត្រា និងការចុះបញ្ជីផ្សេងៗ គឺសរសេរដោយដៃ ។ រាល់ឯកសារត្រូវទុកក្នុងទូ

និងមានសរសេរឈ្មោះ អ្នកនិពន្ធ ចំណងជើងសៀវភៅ និងចំណាត់សៀវភៅទៅតាមកន្លែង ផ្សេងៗដើម្បីងាយស្រួលរក (ក្រសួងអប់រំ យុវជន និងកីឡា ២០១០)។

- **បណ្ណាល័យស្វ័យប្រវត្តិ** ជាបណ្ណាល័យដែលមានអគារផ្ទុកសៀវភៅ ឬឯកសារ និងកន្លែងសម្រាប់អាន និងខ្ចី ដូច បណ្ណាល័យបុរាណដែរ។ ប៉ុន្តែបណ្ណាល័យប្រភេទនេះមានបញ្ចូលព័ត៌មានមួយចំនួនរបស់សៀវភៅក្នុងប្រព័ន្ធ កុំព្យូទ័រ ដូចជាឈ្មោះ អ្នកនិពន្ធ ចំណងជើងសៀវភៅ ឈ្មោះគ្រឹះស្ថាន បោះពុម្ព កន្លែងបោះពុម្ព ឆ្នាំបោះពុម្ព ប្រភេទសៀវភៅ លេខកូដសៀវភៅ លេខ ISBN ពាក្យគន្លឹះ របស់ឯកសារ និងសង្ខេបខ្លឹមសារសៀវភៅដែលជា ព័ត៌មានដល់អ្នកអាន ( ក្រសួងអប់រំ យុវជន និងកីឡា ២០១០)។
- **បណ្ណាល័យអេឡិចត្រូនិច** ជាបណ្ណាល័យដែលគ្មានផ្ទុកសៀវភៅ ឬឯកសារ កន្លែងសម្រាប់អាន និងខ្ចីទេ (ក្រសួងអប់រំ យុវជន និងកីឡា ២០១០)។ បណ្ណាល័យអេឡិចត្រូនិចគឺជាមូលដ្ឋានទិន្នន័យ (Database ) ដែលគេអាចរមើល និងអានបានពីចម្ងាយ តាមរយៈ អិនធឺណិត (E–book) នៅប្រទេសកម្ពុជាសព្វថ្ងៃ មានបណ្ណាល័យអេឡិចត្រូនិចចំនួន ១០សាលា ដែលបណ្ណាល័យ ទាំងនោះកំពុងអនុវត្ត នៅសាលាជំនាន់ថ្មី (សន្និបាតអប់រំ ២០១៨ )។
- **សេវាកម្មបណ្ណាល័យ** ជាដំណើរការរបស់បណ្ណាល័យ ដើម្បីបម្រើឱ្យអ្នកអានគ្រប់រូប ។
- **បណ្ណារក្ស** ជាអ្នកធ្វើការនៅក្នុងបណ្ណាល័យ មើលថែឯកសារ គ្រប់គ្រងឯកសារក្នុងបណ្ណាល័យ។

## *២.២ ប្រវត្តិបណ្ណាល័យ*

### *២.២.១.ប្រវត្តិបណ្ណាល័យនៅលើពិភពលោក*

តាមរយៈឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡា សៀវភៅណែនាំស្ដីពីបណ្ណាល័យ ចុះផ្សាយនាឆ្នាំ ២០០៨ បណ្ណាល័យមានមុនគេនៅក្នុងលោកគឺ នៅបាប៊ីឡោនតាមរយៈកាកសំណល់ ដូចជាកម្ទេចក្បឿង ដុំឥដ្ឋ គឺនៅសតវត្សទី២១មុនគ.ស។ នៅប្រទេសអេហ្ស៊ីប អ្នកនិពន្ធជនជាតិក្រិច ម្នាក់ឈ្មោះ ឌីយ៉ូដូរូស ស៊ីកូឡូស ( Diodorus Siculus ) បានអធិប្បាយអំពីកាតាឡុករបស់ស្ដេច រ៉ាមសែស (Ramses III ឆ្នាំ ១២០០ មុនគ.ស នៅតំបន់ Nineveh ដែលបានកត់សម្គាល់ពី អាឡិចហ្សង់ដ្រា។ តាមប្រាសាទនៅ ហ្សេរូសាឡឹម មានប្រាសាទដ៏ពិសិដ្ឋមួយ។ បណ្ណាល័យសាធារណៈដែលគេបង្កើតឡើងលើកដំបូង នៅប្រទេសក្រិច ក្នុងឆ្នាំ ៣៣០មុនគ.ស ដើម្បីការពារកិច្ចការស្នាដៃល្ខោន ។ ក្នុងចំណោមបណ្ណាល័យបុរាណ នោះបណ្ណាល័យអាឡិចហ្សង់ដ្រា ល្បីជាងគេដែលបានកសាងដោយPtoLemyIក្នុងនោះមានឯកសារ ក្រិចចំនួន

៧០០០០០។ បណ្ណាល័យនៅភើហ្គាមូម Pergamum ចំណាយក្នុងការកសាងដោយ អ៊ីមែនីស॥ ជាគូប្រជែងនឹងអាឡិចហ្សង់ដ្រា។ បណ្ណាល័យនៅទីក្រុងរ៉ូម ត្រូវនាំយកពីប្រទេសក្រិចក្នុងតំបន់ Asia minor ប្រទេសស៊ីរី ជាលទ្ធផលមួយនៃការច្បាំងដណ្តើមគ្នា នៅក្នុងសតវត្សទី១ និងសតវត្សទី២ មុនគ.ស។ បណ្ណាល័យ Caius Asinius Pollio បានបង្កើតនៅឆ្នាំ៤០ មុន គ.ស គឺជាបណ្ណាល័យសាធារណៈដំបូងគេ នៅប្រទេសរ៉ូម៉ាំង ប៉ុន្តែបណ្ណាល័យ សាធារណៈដែលធំល្បីជាងគេ នៃចក្រភពរ៉ូម៉ាំងឈ្មោះ អុកតាវីយ៉ង់ Octavian ដែលបានខូចខាត នៅឆ្នាំ ៨០នៃគ.ស ហើយ បណ្ណាល័យឈ្មោះបាឡាទីន Palatine បានខូចខាតនៅឆ្នាំ ១៩០ នៃគ.ស បណ្ណាល័យដែលសំខាន់ជាងគេ នោះគឺ បណ្ណាល័យ Ulpian ដែលកសាងក្នុងរជ្ជកាល Trajan ។ លើសពីនេះទៅទៀតក៏មានបណ្ណាល័យ ឯកជនល្អៗ ច្រើនទៀតនៅពេលដែល បណ្ណាល័យសាធារណៈរបស់ចក្រភពរ៉ូម បានបាត់បង់នៅឆ្នាំ មុន គ.ស ហើយនៅសេសសល់តែកំទេចបាក់បែកនៅតំបន់ Herculaneum។ បណ្ណាល័យគ្រីស្តសាសនា ដំបូងគេស្ថិតក្នុងវិហារគ្រីស្តសាសនា ដែលបានប្រមូលផ្តុំ នូវការប្រសិទ្ធពរជ័យនៅវិហារ Mote casino។ ប្រទេសរ៉ូម៉ាំង បាននាំយកសៀវភៅទៅប្រទេសអង់គ្លេស ប៉ុន្តែបណ្ណាល័យសំខាន់ដំបូងគេបានកសាងឡើង នៅទីក្រុង យ៉កវៀម៉ូត York Wearmouth កង់តែរី Canterbury និង ទីកន្លែងផ្សេងទៀត ក្នុងប្រទសអង់គ្លេស និងប្រទេសអៀកឡង់ ដោយព្រះសង្ឃប្រើភាសាអង់គ្លេស ។ លោកសន្តបុគ្គលកូឡូមបង់ (St Columban) និងសហការីផ្សេងទៀតបានស្ថាបនាបណ្ណាល័យ ក្នុងព្រះវិហារគ្រីស្តសាសនា នៅសតវត្សទី៦ ។ អត្ថបទ ក្រិច និងអត្ថបទឡាតាំងដែលបុរាណជាងគេហើយបានរក្សាទុករហូតមកដល់សម័យទំនើប គឺរក្សាទុកនៅបណ្ណាល័យ Medieval European Monastory Libraries ។

ការប្រមូលផ្តុំ និងការរក្សាបណ្ណាល័យនៅក្នុងសតវត្សទី៩ ដល់ទី១៥ ជនជាតិជ្វីស និងប៊ីហ្សង់ទីន ក៏បានអភិវឌ្ឍបណ្ណាល័យល្អៗផងដែរ នៅក្នុងមជ្ឈឹមសម័យ (Medieval Period) ។ នៅសតវត្សទី ១៤ និងទី១៥ស្តេចឆាលទីV (Charles V) នៃប្រទេសបារាំង បានបង្កើតបណ្ណាល័យល្អៗជាច្រើន ដែលជា ផ្នែក បណ្ណាល័យ Urbino ឥឡូវស្ថិតនៅក្នុងបណ្ណាល័យប្រទេសវ៉ាទីកង់ ។ នៅសតវត្សទី១៥ បណ្ណាល័យ ប្រទេសវ៉ាទីកង់ ជាបណ្ណាល័យចំណាស់ជាងគេនៅអឺរ៉ុប។ លោក ប្លាទីណា Platina ជាបណ្ណារក្ស ដំបូងគេ នៅក្នុងឆ្នាំ ១៤៧៥ ដែលបានបង្កើតកាឡុងរួមបញ្ចូលទាំងអត្ថបទ ២៥២៧ខ្សែ (Volumes) ។

នៅសហរដ្ឋអាមេរិក បណ្ណាល័យបានរីកសាយនៅឆ្នាំ ១៧៣២ បានប្រារព្ធឡើងនៅ Benjamin Pranklin។ តែទោះជាយ៉ាងណាក៏ដោយបណ្ណាល័យសាធារណៈនៅអាមេរិកដែលបានបើកដំបូងគេនៅ ទីក្រុង Boston ឆ្នាំ១៦៥៣ ។

### ២.២.២ ប្រវត្តិបណ្ណាល័យនៅប្រទេសកម្ពុជា

#### ២.២.២.១ បណ្ណាល័យសាសនបណ្ឌិត្យ

បើតាមការសិក្សាស្រាវជ្រាវរបស់លោក ប៉ូល ប៊ូដេលេខ២ ឆ្នាំ ២០០៦ បានឱ្យដឹងថា ខ្មែរយើងជំនាន់ដើម តែងចារអក្សរនៅលើស្លឹករឹត និងនៅលើក្រាំង ព្រមទាំងនៅលើថ្ម រហូតមកដល់សតវត្សទី២០ ទើបមានក្រដាសសរសេរដូចសព្វថ្ងៃ។ ចាប់ពីប្រជាជនខ្មែរកាន់សាសនាព្រះពុទ្ធមក ខ្មែរយើងមានទម្លាប់យកគម្ពីរ និងក្បួនច្បាប់ផ្សេងៗ ទៅរក្សាទុក នៅក្នុងវត្តអារាម ដោយយល់ថា វត្តអារាមជាមណ្ឌលវប្បធម៌ ជាសាលារៀន ជាកន្លែងអប់រំបណ្តុះបណ្តាល និងជាជម្រុកចំណេះដឹងផ្សេងៗ ។ លុះមកដល់ សម័យចតុមុខ ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ នៅឆ្នាំ១៩០៩ ព្រះអង្គបានបង្កើតសាលាបាលីពីរ មួយនៅខេត្តសៀមរាប និងមួយទៀតនៅរាជធានីភ្នំពេញ សម្រាប់រក្សាទុកឯកសារក្បួនច្បាប់ផ្សេងៗ ក្នុងស្រុក ខេត្ត។ ប៉ុន្តែមកដល់ឆ្នាំ ១៩១១ សាលាបាលីនៅខេត្តសៀមរាបបានបិទទ្វារទៅវិញដោយសារស្ថិតនៅឆ្ងាយពីទីក្រុង។ លុះមកដល់ឆ្នាំ ១៩២១ ព្រះអង្គបានបង្កើតបណ្ណាល័យ មួយនៅទីក្រុងភ្នំពេញ ឱ្យឈ្មោះថា ខេមរៈបណ្ណាល័យ ។ នៅឆ្នាំ១៩២៥ បណ្ណាល័យនេះបានក្លាយជា ព្រះរាជបណ្ណាល័យ ។

កន្លងមកដល់ឆ្នាំ ១៩៣០ ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស ព្រះអង្គបានបញ្ជាឱ្យស្ថាបនា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ហើយបញ្ចូលព្រះរាជបណ្ណាល័យក្នុងស្ថាប័ននេះដែរ ។ ដូច្នេះ បណ្ណាល័យក៏ក្លាយជាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យចាប់ពីពេលនោះមក ។ មកដល់ឆ្នាំ ១៩៦៤ អង្គការយូណេស្កូបានឱ្យតម្លៃ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ថាជាបណ្ណាល័យដែលមានតម្លៃជាងគេនៅអាស៊ីអាគ្នេយ៍ ខាងប្រមូលចងក្រងឯកសារ និងថែរក្សា តម្កល់ទុកឯកសារទាក់ទងនឹង វិស័យមនុស្សសាស្ត្រ ដូចជា សាសនា ប្រវត្តិវិទ្យា បុរាណវិទ្យា អក្សរសិល្ប៍ សិល្បៈ ។ល។ ចាប់ពី ឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ក្នុងរបបខ្មែរក្រហម បណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានបិទទ្វារ ហើយធនធាន ឯកសារទាំងមូលត្រូវបានបំផ្លាញ ។ មកដល់ឆ្នាំ១៩៩២ ក្រសួងធម្មការ ត្រូវបានបង្កើតឡើងវិញ ហើយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យក៏បានកែលម្អបន្តិចម្តងៗឡើងវិញដែរ ។ រហូតមកដល់ឆ្នាំ២០០២ បានប្តូរទីកន្លែងថ្មី ដោយមកតាំងនៅជិតសាលាមហោស្រព ទន្លេបាសាក់ ។

#### ២.២.២.២ បណ្ណាល័យជាតិកម្ពុជា

បណ្ណាល័យជាតិកម្ពុជាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩២៤ ដោយរដ្ឋាភិបាលអាណានិគមបារាំងនៅឥណ្ឌូចិន និងក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ក្នុងសម័យនេះបារាំងជាអ្នកគ្រប់គ្រងបណ្ណាល័យនេះ រួម

ជាមួយបណ្ណសារដ្ឋានជាតិ រហូតដល់ឆ្នាំ១៩៥៣ ។ បណ្ណាល័យ នេះត្រូវបាន សាងសង់លើទីកន្លែងស្រឡះ ខាងលិចវត្តភ្នំជូនពេញ ហើយបានបើកទ្វារជូនសាធារណៈជន ប្រើប្រាស់ នៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩២៤ ដោយប្រសិទ្ធិនាមថា បណ្ណាល័យកណ្តាល ដែលមានសៀវភៅតែ ៣០០០ក្បាលប៉ុណ្ណោះ ។ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យ ក្នុងឆ្នាំ ១៩៥៣ បារាំងបានប្រគល់បណ្ណាល័យកណ្តាលមកឱ្យខ្មែរកាន់កាប់ជាសម្បត្តិជាតិខ្មែរវិញ ហើយត្រូវបាន ប្តូរឈ្មោះមកជា បណ្ណាល័យជាតិ ។ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បណ្ណាល័យ ជាតិត្រូវបានបិទទ្វារ សៀវភៅ ឯកសារ ត្រូវបានបំផ្លាញអស់ ។ ក្រោយឆ្នាំ ១៩៧៩ បណ្ណាល័យជាតិបានរស់ឡើងវិញ ហើយបានបើកទ្វារសារជាថ្មី ក្នុងឆ្នាំ ១៩៨០ ក្រោមការគ្រប់គ្រង របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (ប៉ូល ប៊ូដេ លេខ ២ ឆ្នាំ ២០០៦)។

### *២.៣ តួនាទីបណ្ណារក្ស*

បណ្ណារក្ស គឺជាអ្នកជួយសម្របសម្រួលក្នុងការទំនាក់ទំនង រវាងសៀវភៅសិក្សា និងសិស្ស តាម-រយៈការផ្តល់ភាពសប្បាយរីករាយដល់អ្នកអាន ដើម្បីឱ្យពួកគេមានអារម្មណ៍ ធូរស្រាល សប្បាយ និងមានចិត្តរំភើបចង់ចូលបណ្ណាល័យ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៥ ) ។ បណ្ណារក្ស ជាមនុស្សមានកម្រិតវប្បធម៌ ល្អបង្គួរ មានចំណេះដឹងទូលំទូលាយពីរបៀបរៀបចំ ចងក្រងការប្រើប្រាស់ និងថែទាំសៀវភៅបានល្អប្រសើរ មានគំនិតច្នៃប្រឌិតខ្ពស់ មានភាពឈ្លាសវៃ ចេះគ្រប់គ្រងធនធានសម្ភារ បរិក្ខារ ថែរក្សាឯកសារនានាបានល្អ មានទំនាក់ទំនងល្អជាមួយ មជ្ឈដ្ឋាននានា ឧស្សាហ៍ព្យាយាម ស្រឡាញ់ចូលចិត្តការងារ ។

បណ្ណារក្សមានការទទួលខុសត្រូវ លើការអនុវត្តការងារដូចជា៖

- រៀបចំ ថែទាំ និងគ្រប់គ្រងបណ្ណាល័យ ទូ ធ្នើ និងសៀវភៅរបស់សាលារៀន
- បង្កលក្ខណៈងាយស្រួលដល់សិស្ស និងគ្រូ ក្នុងអំណានសៀវភៅ ក្នុងបណ្ណាល័យ
- ទទួលខុសត្រូវលើការថែរក្សា ទុកដាក់ ជួសជុលសៀវភៅសិក្សាគោលដែលខូចខាត
- ធ្វើបញ្ជីសារពើភ័ណ្ឌសៀវភៅ និងសម្ភារ បរិក្ខារ ក្នុងបណ្ណាល័យ
- ធ្វើគម្រោងចំណាយ ដើម្បីស្នើសុំទិញសៀវភៅសិក្សាថ្មី និងគម្រោងចំណាយ លើការជួសជុលសៀវភៅសិក្សាគោល និងសម្ភារ បរិក្ខារ បណ្ណាល័យ ។
- រៀបចំកាលវិភាគសម្រាប់សិស្សចូលអាន និងសហការជាមួយគ្រូបង្រៀន តាមមុខវិជ្ជា ដើម្បីជំរុញការសិក្សារបស់សិស្ស
- ចាត់តាំងការខ្ចីសង សៀវភៅសិក្សារបស់សិស្ស និងគ្រូគ្រប់កម្រិតសិក្សា

- ធ្វើរបាយការណ៍ ដែលពាក់ព័ន្ធនឹងការបាត់ ឬខូចសៀវភៅសិក្សាគោល ពេលចុងឆ្នាំសិក្សា
- គោរពតាមការណែនាំរបស់នាយក ស្តីពីការថែទាំ និងគ្រប់គ្រងសៀវភៅ
- ផ្សព្វផ្សាយពីរបៀបថែទាំ និងប្រើប្រាស់សៀវភៅសិក្សាគោលដល់សិស្ស និងគ្រូ
- បណ្ណារក្សត្រូវជ្រើសចេញពីគ្រូបង្រៀនដែលមានសុខភាពល្អមានចំណេះដឹងទូលំទូលាយ ឧស្សាហ៍ព្យាយាមក្នុងការស្រាវជ្រាវ មានទេពកោសល្យ និងទទួលបានការបំប៉នផ្នែកបណ្ណារក្ស (ក្រសួងអប់រំ យុវជន និងកីឡា ២០១៥)

## *២.៤ សារៈសំខាន់នៃបណ្ណាល័យ*

ការពង្រីកបណ្ណាល័យជាមធ្យោបាយ ជួយកាត់បន្ថយអត្រាអនក្ខរភាព និងរួមចំណែកកសាងធនធានមនុស្ស តាមគោលដៅអប់រំជាតិ ក៏ជួយសម្រេចផែនការអប់រំជាតិសម្រាប់ទាំងអស់គ្នាផងដែរ។ ហេតុនេះភាពជាដៃគូដ៏ស្អិតល្មួតរវាងស្ថាប័នពាក់ព័ន្ធ ម្ចាស់ជំនួយ អង្គការជាតិ អន្តរជាតិ អជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ វត្តអារាម និងប្រជាជន ជាការចាំបាច់បំផុតដែលមិនអាចខ្វះបាន ក្នុងការធ្វើឱ្យបណ្ណាល័យមានស្ថិរភាព (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៧)។ បើតាមក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៤ បណ្ណាល័យសាលាមានសារៈសំខាន់ជាច្រើនដូចជា៖

- បណ្ណាល័យជាកន្លែងផ្តល់ការឯកភាពក្នុងការអភិវឌ្ឍការងារបណ្ណាល័យ
- បណ្ណាល័យជាកន្លែងផ្តល់ចំណេះដឹងមូលដ្ឋាន ផ្នែកបណ្ណាល័យដល់បណ្ណារក្ស
- បណ្ណាល័យជាកន្លែងជំរុញ និងលើកទឹកចិត្តបណ្ណារក្ស ។
- បណ្ណាល័យជាកន្លែង លើកកម្ពស់ការអាន និងការស្រាវជ្រាវ សម្រាប់សាធារណៈជនទូទៅ
- បណ្ណាល័យជាកន្លែងបណ្តុះទម្លាប់អាន និងការសិក្សាស្រាវជ្រាវ ដល់សិស្សានុសិស្ស
- រួមចំណែកគាំទ្រគោលនយោបាយ ស្តីពីសាលាកុមារមេត្រី ។

## *២.៥ ការគ្រប់គ្រងបណ្ណាល័យ*

តាមឯកសាររបស់លោក Michael Scott ឆ្នាំ២០១៦ បានបង្ហាញថា ដើម្បីគ្រប់គ្រងបណ្ណា-ល័យមួយ ឱ្យមានលក្ខណៈរឹងមាំត្រូវ៖

- ជួលអ្នកគ្រប់គ្រងបណ្ណាល័យ និងធ្វើការវាយតម្លៃអ្នកគ្រប់គ្រងនោះជាប្រចាំ
- កំណត់ប្រាក់ខែដល់ អ្នកគ្រប់គ្រង និងបុគ្គលិកបណ្ណាល័យ

- រៀបចំថវិកាសម្រាប់ទ្រទ្រង់បណ្ណាល័យដែលកំណត់ដោយក្រុមប្រឹក្សា
- ត្រួតពិនិត្យការចំណាយ និងអនុម័តនៃការចំណាយលើបណ្ណាល័យ
- រៀបចំ និងអនុម័តគោលនយោបាយប្រតិបត្តិការបណ្ណាល័យ
- ធ្វើផែនការរយៈពេលខ្លី និងរយៈពេលវែងសម្រាប់ពេលអនាគតបណ្ណាល័យ
- អនុវត្តត្រួតពិនិត្យតាមដានលើដំណើរការបណ្ណាល័យ

តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សារបស់ ក្រសួងអប់រំ យុវជន និងកីឡា ចុះផ្សាយនាឆ្នាំ២០១៤ បណ្ណាល័យត្រូវមានសមាសភាគសំខាន់បីគឺៈ

- **ធនធានបណ្ណារក្ស ការប្រជុំ ការចុះពិនិត្យតាមដាន** បណ្ណារក្សត្រូវមានចំណេះដឹង ភាសាអង់គ្លេស កុំព្យូទ័រខ្លះៗ ដែលអាចជួយសម្រួលការងារ បច្ចេកទេស រដ្ឋបាល ។ លើសពីនេះ បណ្ណារក្សត្រូវមានសុខភាពល្អ និងមានអាយុមិនលើសពី ៥០ឆ្នាំ ។ នាយកសាលា ត្រូវធ្វើការប្រជុំប្រចាំខែដោយ បញ្ចូលរបៀបវារៈបណ្ណាល័យក្នុងអង្គប្រជុំ ចំណែកថ្នាក់ក្រសួងអប់រំ មន្ទីរអប់រំ ការិយាល័យអប់រំត្រូវចុះពិនិត្យតាមដានតាមការកំណត់។
- **ស្ថានភាពបណ្ណាល័យ ធនធានសម្ភារ បរិក្ខារ ធនធានឯកសារ** បន្ទប់បណ្ណាល័យត្រូវមានលក្ខណៈស្អាត និងមានផាសុខភាព បំពាក់សម្ភារបរិក្ខារ និងឯកសារអានសម្បូរបែប។

- **ការងារបច្ចេកទេស រដ្ឋបាល** បណ្ណារក្សត្រូវចេះការងារបច្ចេកទេស រដ្ឋបាលច្បាស់លាស់ ដូចជាការធ្វើរបាយការណ៍ ការធ្វើផែនការ ការថែទាំងឯកសារ និងការផ្តល់សេវាកម្មបណ្ណាល័យបានល្អ។

  តាមឯកសារក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការងារបណ្ណាល័យមធ្យមសិក្សា ឆ្នាំ២០១០ ដើម្បីបានបណ្ណាល័យមួយមានលក្ខណៈល្អទាក់ទងនឹងចំណុចជាច្រើនដូចជាៈ

  - ការបង្កើតបណ្ណាល័យ ត្រូវពិនិត្យមើលលើស្ថានភាពទីតាំង ការគាំទ្រពីសាលា និងស្ថាប័នពាក់ព័ន្ធ ការស្វែងរកឯកសារសម្រាប់បណ្ណាល័យ និងការជ្រើសរើសបណ្ណារក្ស ។
  - សេវាកម្មបណ្ណាល័យ ដើម្បីធានាបានការអានមានប្រសិទ្ធភាពទាមទារសេវាកម្មបណ្ណាល័យល្អគឺ បណ្ណាល័យបើកទ្វារគ្រប់ពេល និងមានបណ្ណារក្សនៅរោងចាំផ្តល់ប្រឹក្សាដល់ អ្នកអានគ្រប់ពេល។
  - ការងាររដ្ឋបាលបណ្ណាល័យ រួមមានការចាត់ចែងបុគ្គលិក ការពិនិត្យតាមដាននិងការវាយតម្លៃបុគ្គលិក ការទិញ ការធ្វើអំណោយ ការដោះដូរ ។
  - ការងារទំនាក់ទំនង ការទំនាក់ទំនងក្នុងសាលារៀន និងការទំនាក់ទំនងក្រៅសាលារៀន ។

តាមឯកសារក្រសួងអប់រំ យុវជន និងកីឡា ស្តីពីបណ្ណាល័យ និងសៀវភៅសម្រាប់កុមារ ចេញផ្សាយនាឆ្នាំ២០០៧ បណ្ណាល័យជាកន្លែងសម្រាប់អ្នកទូទៅប្រើប្រាស់ ដែលមានបណ្ណារក្ស ជាអ្នកទទួលខុសត្រូវ ក្នុងការធ្វើឱ្យបណ្ណាល័យមានគុណភាព និងនិរន្តរភាពតាមរយៈការគ្រប់គ្រងល្អ អំពីទីកន្លែង សង្ហារឹម សម្ភារ សៀវភៅ និងអ្នកអាន ។ បណ្ណារក្សត្រូវមានជំនាញ ក្នុងការ រៀបចំសម្ភារបរិក្ខារ ក្នុងបណ្ណាល័យឱ្យមានរបៀបរៀបរយ ការធ្វើការសម្អាតក្នុងបន្ទប់ និងក្រៅបន្ទប់បណ្ណាល័យឱ្យបានស្អាត ការជួសជុលថែទាំសៀវភៅ ការរៀបចំបញ្ជីសារពើភ័ណ្ឌ ការចុះលេខកូដសៀវភៅ ការរៀបចំសៀវភៅចូលធ្នើ ការធ្វើបញ្ជីខ្ចីសង ការប្រមូលសៀវភៅថ្មី ការរៀបចំឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន ការធ្វើកាលវិភាគប្រចាំសប្តាហ៍ ការលើកទឹកចិត្តសិស្សដែលស្ម័គ្រចិត្តជួយ ធ្វើការងារ បណ្ណាល័យ ការធ្វើផែនការប្រចាំខែ ការធ្វើរបាយការណ៍ ការធ្វើសំណើសុំសម្ភារ ការធ្វើទំនាក់ទំនងល្អ ។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## *៣.១. ការជ្រើសរើសសំណាក*

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យដែលមានការចូលរួមពីភាគីពាក់ព័ន្ធដូចជា បណ្ណារក្ស លោកគ្រូ អ្នកគ្រូ លោកនាយក នាយិកា និងសិស្ស។ ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះរួមមានបណ្ណារក្សចំនួន ០៧នាក់ នាយកសាលា ០៧នាក់ លោកគ្រូ អ្នកគ្រូចំនួន ៧០នាក់ និងសិស្សានុសិស្ស ចំនួន១៤០នាក់ ដែលបានជ្រើសរើសចេញពី វិទ្យាល័យចំនួន ០៧ ក្នុងស្រុក/ក្រុងចំនួន៥ នៅខេត្តស្វាយរៀងតែប៉ុណ្ណោះ។ សូមបញ្ជាក់ផងដែរ ខេត្តស្វាយរៀងមានស្រុកក្រុងចំនួនប្រាំបី និងមានវិទ្យាល័យចំនួន១៩ ដែលក្នុងនោះវិទ្យាល័យមានសាលាធនធានមានចំនួន២សាលា និងវិទ្យាល័យគ្មានសាលាធនធានមានចំនួន១៧សាលា។ ក្នុងចំណោម វិទ្យាល័យទាំង០៧ យើងបានជ្រើសរើសវិទ្យា-ល័យដែលមានសាលាធនធានចំនួនពីរសាលាស្មើ១០០% នៃវិទ្យាល័យដែលមានសាលាធនធានទាំងអស់ក្នុងខេត្តស្វាយរៀង និងវិទ្យាល័យចំនួន០៥ទៀត ស្មើ២៩.៤១% នៃវិទ្យាល័យដែលគ្មាន សាលាធនធានទាំងអស់ក្នុងខេត្តស្វាយរៀង ។ មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវជ្រើសរើសយក ទាំងវិទ្យាល័យមានសាលាធនធាន និងវិទ្យាល័យគ្មានសាលាធនធាន គឺដើម្បីយកមកធ្វើការប្រៀបធៀបគ្នាលើផ្នែកមួយចំនួននៃស្ថានភាពការគ្រប់គ្រងបណ្ណាល័យសាលា ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។ រីឯសំណាកដែលត្រូវជ្រើសរើសមកបំពេញកម្រងសំណួរ និងសម្ភាស គឺយើងធ្វើការជ្រើសរើស ដោយចៃដន្យ ចំពោះគ្រូ (ចំនួន១០នាក់ក្នុងមួយសាលា) និងសិស្ស (ចំនួន២០នាក់ក្នុងមួយសាលា) ។ ចំណែក នាយកសាលា (១នាក់ក្នុងមួយសាលា) និងបណ្ណារក្ស (១នាក់ក្នុងមួយសាលា) យើងបានធ្វើការណាត់ជួបភាគសំណាកទាំងអស់ជាមុនទៅតាមពេលវេលាដែលបានកំណត់។

## *៣.២. ឧបករណ៍ស្រាវជ្រាវ*

ចំពោះឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរៀបចំបង្កើតកម្រងសំណួរដែលជាលក្ខណៈកម្រិតចម្លើយ និងសំណួរទម្រង់បើកសម្រាប់គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ បណ្ណារក្ស និងសិស្ស។ កម្រងសំណួរមានបួនប្រភេទ ត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យ រួមមាន៖

កម្រងសំណួរសម្រាប់នាយកសាលា សម្រាប់លោកគ្រូ អ្នកគ្រូ សម្រាប់បណ្ណារក្ស និងសម្រាប់សិស្ស។ ក្នុងការសិក្សាស្រាវជ្រាវនេះ យើងប្រើប្រាស់កម្រងសំណួរចំនួន០៧ច្បាប់ សម្រាប់បណ្ណារក្ស កម្រងសំណួរ ០៧ច្បាប់ សម្រាប់នាយកសាលា កម្រងសំណួរ៧០ច្បាប់ សម្រាប់គ្រូបង្រៀន និងកម្រងសំណួរ១៤០ច្បាប់ សម្រាប់សិស្ស សរុបទាំងអស់មាន ២២៤ច្បាប់។ ក្នុងការបង្កើតកម្រងសំណួរនេះ យើងខ្ញុំបានរៀបចំតាក់តែង ខ្លឹមសារ កម្រងសំណួរ ស្របនឹងខ្លឹមសារឯកសារស្តង់ដាបណ្ណាល័យមធ្យមសិក្សា ដែលបានបោះពុម្ព ឆ្នាំ ២០១៤ និងដកស្រង់ ខ្លះៗពី Ton, S.I. (2007). Report on Secondary School Library Situation Analysis. Pedagogical Research Department of the Ministry of Education, Youth and Sport។

## *៣.៣. កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ*

### *៣.៣.១ កម្រងសំណួរសម្រាប់បណ្ណារក្ស*

កម្រងសំណួរសម្រាប់បណ្ណារក្ស មាន៥ ផ្នែក និងមាន ២១សំណួរ ៖

- **ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន** ក្នុងផ្នែកនេះមាន៧សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីកម្រិតវប្បធម៌ អាយុ ភេទ អតីតភាពការងារជាបណ្ណារក្ស មុខវិជ្ជាឯកទេស ចំណេះដឹង ភាសាអង់គ្លេស និងមុខវិជ្ជាឯកទេសរបស់អ្នកបំពេញកម្រងសំណួរ។
- **ផ្នែកទី២ ការបំប៉នសមត្ថភាព** ក្នុងផ្នែកនេះមាន២សំណួរ។ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញថា បណ្ណារក្សធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបណ្ណាល័យ ដែរឬទេ?
- **ផ្នែកទី៣ ការប្រជុំក្នុងសាលា និងការពិនិត្យតាមដានរបស់ថ្នាក់លើ** មាន២សំណួរអ្នក ស្រាវជ្រាវចង់រកឱ្យឃើញថាការប្រជុំក្នុងសាលា បានយកចិត្តទុកដាក់ចំពោះ បណ្ណាល័យកម្រិតណា? ហើយថ្នាក់លើមានការចុះពិនិត្យតាមដាន ស្ថានភាពគ្រប់គ្រង បណ្ណាល័យកម្រិតណា?
- **ផ្នែកទី៤ អំពីធនធានសម្ភារ និងធនធានឯកសារ** មាន៥សំណួរ អ្នកស្រាវជ្រាវចង់រកឱ្យឃើញថា ក្នុងបណ្ណាល័យ សាលាមានបំពាក់ធនធានសម្ភារ និងឯកសារ មានកម្រិតណា?
- **ផ្នែកទី៥ ការងារបច្ចេកទេស រដ្ឋបាល និងសេវាកម្មបណ្ណាល័យ** មាន៥សំណួរអ្នកស្រាវជ្រាវចង់រកឱ្យឃើញ ពីកម្រិតអនុវត្ត ការងាររដ្ឋបាល និងការងារបច្ចេកទេស របស់បណ្ណារក្សបានកម្រិតណាដែរ? អ្នកស្រាវជ្រាវក៏ចង់រកឱ្យឃើញនូវសេវាកម្មបណ្ណាល័យ ដូចជា ស្ថិតិសិស្សចូលអាន ការរៀបចំបញ្ជីខ្ចីសង ការរៀបចំបទបញ្ជាផ្ទៃក្នុងបណ្ណាល័យ...។

### *៣.៣.២ កម្រងសំណួរសម្រាប់នាយកសាលា*

កម្រងសំណួរសម្រាប់នាយកសាលា មាន៣ផ្នែក និងមាន១៦សំណួរ ៖

- **ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន** ក្នុងផ្នែកនេះមាន៥សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីកម្រិតវប្បធម៌ អាយុ ភេទ ស្ថិតិសិស្ស ថ្នាក់ គ្រូ អតីតភាពជានាយក របស់អ្នកបំពេញកម្រងសំណួរ។

- **ផ្នែកទី២ លក្ខណៈទូទៅនៃបណ្ណាល័យ** មាន៥សំណួរ អ្នកស្រាវជ្រាវចង់ដឹងអំពី លក្ខណៈអគារ គុណភាពសំណង់បណ្ណាល័យ។
- **ផ្នែកទី៣ អំពីបណ្ណារក្ស** ក្នុងផ្នែកនេះមាន៦សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹង ពីចំនួនបណ្ណារក្ស បំណែងចែកភារកិច្ចបណ្ណារក្ស ការអនុវត្តការងាររបស់បណ្ណារក្ស ការចូលរួមប្រជុំ ការធ្វើរបាយ-ការណ៍ ការបម្រើសេវាកម្មបណ្ណាល័យ និងសំណូមពររបស់នាយក។

### *៣.៣.៣ កម្រងសំណួរសម្រាប់គ្រូ*

កម្រងសំណួរសម្រាប់គ្រូ មានពីរផ្នែក និងមាន១២សំណួរ ៖

ផ្នែកទី១ ព័ត៌មានទូទៅរបស់គ្រូ ក្នុងផ្នែកនេះមាន៣សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹងពី ភេទ អាយុ មុខវិជ្ជាឯកទេស អតីតភាពការងារ និងកម្រិតវិជ្ជាជីវៈរបស់លោកគ្រូ អ្នកគ្រូ។

ផ្នែកទី២ ទស្សនៈរបស់គ្រូចំពោះបណ្ណាល័យ ក្នុងផ្នែកនេះមាន៩សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹង ពីសារៈសំខាន់នៃបណ្ណាល័យ ទស្សនៈរបស់គ្រូចំពោះការអានសៀវភៅ របស់សិស្ស បញ្ហាប្រឈមនានានៃបណ្ណាល័យនិងយោបល់របស់គ្រូដើម្បីរួមចំណែក អភិវឌ្ឍបណ្ណាល័យ។

### *៣.៣.៤ កម្រងសំណួសម្រាប់សិស្ស*

កម្រងសំណួសម្រាប់សិស្ស មានបួនផ្នែកដែលចែកចេញជា ១៦សំណួរ ៖

ផ្នែកទី១ ព័ត៌មានទូទៅ មាន១សំណួរ ដែលសួរលើចំណុចដូចជា ភេទ អាយុ ថ្នាក់ ។

ផ្នែកទី២ អំពីការសិក្សាស្រាវជ្រាវ ក្នុងផ្នែកនេះមាន៣សំណួរ។ អ្នកស្រាវជ្រាវ ចង់ដឹងអំពីរបៀបស្វែងរកឯកសាររបស់សិស្ស ភាពញឹកញាប់នៃការប្រើប្រាស់មធ្យោបាយផ្សេងៗ នៃការស្វែងរកឯកសារស្រាវជ្រាវ។

ផ្នែកទី៣ អំពីគ្រូបង្រៀន និងនាយកសាលាក្នុងផ្នែកនេះមាន៦សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងពីការជំរុញរបស់លោកគ្រូ អ្នកគ្រូ នាយកសាលា ដើម្បីឱ្យសិស្ស ស្វែងរកឯកសារសម្រាប់ធ្វើការស្រាវជ្រាវ និងការជំរុញឱ្យសិស្សថែទាំសៀវភៅសិក្សាគោល ។

ផ្នែកទី៤ អំពីបណ្ណាល័យ និងបណ្ណារក្ស ក្នុងផ្នែកនេះមាន៦សំណួរ។ អ្នកស្រាវជ្រាវ ចង់ដឹងពីការបំពេញតម្រូវការនៃការអានសៀវភៅក្នុងបណ្ណាល័យ ការបម្រើសេវាកម្មរបស់បណ្ណារក្ស ចំពោះសិស្សដែលចូលអានសៀវភៅ និងយោបល់សំណូមពររបស់សិស្ស ក្នុងការរួមចំណែកកសាងបណ្ណាល័យ។

### *៣.៤. ដំណើរការប្រមូលទិន្នន័យ*

មុនពេលផ្តល់កម្រងសំណួរនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងអ្នកស្រាវជ្រាវបានធ្វើ លិខិតស្នើសុំចុះប្រមូលទិន្នន័យ ពីវិទ្យាស្ថានជាតិអប់រំ បន្ទាប់មកយកទៅប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដើម្បីសុំលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យស្រាវជ្រាវ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារួចមក អ្នកស្រាវជ្រាវ ក៏បានយកលិខិតស្នើសុំនោះ ទៅប្រគល់ជូន លោកប្រធានការិយាល័យអប់រំស្រុក ដើម្បីសាកសួរព័ត៌មានពីទីតាំង ដែលត្រូវចុះប្រមូលទិន្នន័យ។ បន្ទាប់ពីបាន

ទំនាក់ទំនងជាមួយមន្ត្រីស្រុករួចមក យើងខ្ញុំបានជួបជាមួយនាយក នាយិកាសាលា លោកគ្រូអ្នកគ្រូ បណ្ណារក្ស និងសិស្ស ដើម្បីជម្រាបពួកគាត់ពីគោលបំណងនៃការចុះសិក្សាស្រាវជ្រាវនេះ ព្រមទាំងសុំ ការអនុញ្ញាតដើម្បីឱ្យគាត់ជួយ ផ្តល់បទសម្ភាស ក៏ដូចជាសាកសួរព័ត៌មានអំពីពួកគាត់។ បន្ទាប់មកទៀត យើងខ្ញុំក៏បានផ្តល់កម្រងសំណួរដល់ គណៈនាយក /នាយិកា បណ្ណារក្ស លោកគ្រូ អ្នកគ្រូ សិស្ស ដើម្បីបំពេញ និងធ្វើការសម្ភាស។

### *៣.៥. ការវិភាគទិន្នន័យ*

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវជ្រាវប្រើប្រាស់កម្មវិធី SPSS ដើម្បីបញ្ចូល និងវិភាគទិន្នន័យ និងប្រើកម្មវិធី Ms. Excel ដើម្បី បង្ហាញតារាង និងតាងក្រាហ្វិក ក្នុងការវិភាគតាមបែបបរិមាណវិស័យ ដែលបង្ហាញពីកម្រិតចម្លើយនៃសកម្មភាពនានាដែលពាក់ព័ន្ធនឹងស្ថានភាពនៃការគ្រប់គ្រង បណ្ណាល័យ ដោយគិតជា ចំនួនមធ្យម និងភាគរយ។ ចំណែកសំណួរបើកវិញជាសំណួរបែបគុណវិស័យ យើងខ្ញុំវិភាគដោយប្រើប្រាស់កម្មវិធី SPSS និងWord។ ដូច្នេះ នៅក្នុងការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ ត្រូវបានធ្វើការវិភាគ គឺអាស្រ័យទៅលើប្រភេទនៃសំណួរ ថាតើវាជាប្រភេទសំណួរបើក ឬសំណួរបិទ។ ចំពោះការវិភាគនេះ អ្នកសិក្សាស្រាវជ្រាវ បានវិភាគលើចំណុចសំខាន់មួយចំនួន ដូចជាកម្រិតនៃការអនុវត្តការងារ ការយកចិត្តទុកដាក់ពីថ្នាក់លើ ការជំរុញទឹកចិត្តសិស្សចូលអានសៀវភៅ ស្ថានភាពការបំពាក់សម្ភារ បរិក្ខារ ធនធានឯកសារ...។

### *៣.៦. ក្រមសីលធម៌នៃការស្រាវជ្រាវ*

ចំពោះការសិក្សាស្រាវជ្រាវនេះ ដើម្បីរក្សាបាននូវក្រមសីលធម៌ យើងបានរៀបចំលិខិត ដើម្បីសុំការអនុញ្ញាតពីថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបានផ្តល់ដំណឹងបន្ត ទៅដល់មូលដ្ឋាន ក្នុងការសុំជួបសម្ភាសជាមួយ នាយក នាយិកា លោកគ្រូ អ្នកគ្រូ សិស្ស បណ្ណារក្ស ។ នៅគ្រប់ការជួបសម្ភាស ជាមួយនាយក នាយិកា លោកគ្រូ អ្នកគ្រូ សិស្ស និងបណ្ណារក្ស យើងតែងតែជម្រាប ពួកគាត់អំពីក្រមសីលធម៌របស់អ្នកសិក្សា ស្រាវជ្រាវ ដែលរក្សានូវការសម្ងាត់ នូវរាល់ចម្លើយរបស់ លោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូ ដែលមិនបានបង្ហាញពីឈ្មោះរបស់អ្នកឆ្លើយពិតប្រាកដនោះទេ ដើម្បីទាមទារឲ្យបានចម្លើយដែលពិតប្រាកដ។

# ជំពូកទី៤

# លទ្ធផលនៃការសិក្សាស្រាវជ្រាវ

# និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផលនៃការសិក្សាស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងចំពូកនេះ អ្នកសិក្សាស្រាវជ្រាវ នឹងបង្ហាញនូវលទ្ធផលដែលប្រមូលបានទៅតាម ខ្លឹមសារនៃកម្រងសំណួរម្តងមួយៗ តាមរយៈតារាង និងក្រាហ្វិក ហើយនិងធ្វើការបកស្រាយ ធៀបនឹងខ្លឹមសារនៃស្តង់ដាបណ្ណាល័យមធ្យមសិក្សា ឆ្នាំ២០១៤ ។

## *៤.១ លទ្ធផលនៃការសិក្សាស្រាវជ្រាវ*

### *៤.១.១ អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ*

ក្រោយពេលបូកសរុបទិន្នន័យបឋម ដែលប្រមូលបានពីការបំពេញកម្រងសំណួរ និងឆ្លើយ សំណួរសម្ភាសរួចមក អ្នកសិក្សាស្រាវជ្រាវរកឃើញថា អ្នកចូលរួមឆ្លើយក្នុងការផ្តល់ព័ត៌មាន សរុបមានចំនួន ២២៣នាក់ ស្រី១១២នាក់ ដែលក្នុងនោះ នាយកសាលា ៦នាក់ ស្រី0នាក់ បណ្ណារក្ស ៧នាក់ ស្រី ៥នាក់ គ្រូបង្រៀន ៧០នាក់ ស្រី ១៩នាក់ និង សិស្ស ១៤០នាក់ ស្រី ៨៨ (តារាងទី១)។

តារាងទី១៖ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ

| អ្នកចូលរួមឆ្លើយសំណួរ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| នាយកសាលា | ៦នាក់ | ០នាក់ | ៦នាក់ |
| បណ្ណារក្ស | ២នាក់ | ៥នាក់ | ៧នាក់ |
| គ្រូ | ៥១នាក់ | ១៩នាក់ | ៧០នាក់ |
| សិស្ស | ៥២នាក់ | ៨៨នាក់ | ១៤០នាក់ |
| សរុប | ១១១នាក់ | ១១២នាក់ | ២២៣នាក់ |

តារាងទី២៖ ចំនួននាយកសាលា បណ្ណារក្ស គ្រូបង្រៀនដែលបានចូលរួមតាមមុខវិជ្ជាឯកទេសនីមួយៗ

| | គណិត | ខ្មែរ | រូប | គីមី | ជីវៈ | ប្រវត្តិ | ភូមិ | អង់គ្លេស | ផែនដី | បារាំង | សេដ្ឋកិច្ច | សីល |
|---|---|---|---|---|---|---|---|---|---|---|---|---|
| នាយក | 1 | 1 | 1 | 1 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 |
| បណ្ណារក្ស | 1 | 2 | 0 | 0 | 1 | 2 | 1 | 0 | 0 | 0 | 0 | 0 |
| គ្រូ | 14 | 12 | 4 | 8 | 10 | 5 | 3 | 7 | 3 | 1 | 1 | 2 |
| សរុប | 16 | 15 | 5 | 9 | 11 | 7 | 5 | 8 | 3 | 1 | 1 | 2 |

តាមតារាងទី២៖ គ្រូបង្រៀន នាយកសាលា បណ្ណារក្ស ដែលបានចូលរួមឆ្លើយសំណួរភាគច្រើនមានឯកទេស គណិតវិទ្យា(១៦នាក់) ភាសាខ្មែរ(១៥នាក់) ជីវវិទ្យា(១១នាក់) គីមីវិទ្យា(៩នាក់) ភាសាអង់គ្លេស(៨នាក់) ប្រវត្តិវិទ្យា(៧នាក់) ភូមិវិទ្យា(៥នាក់) និងរូបវិទ្យា(៥នាក់)។ ចំណែកមុខវិជ្ជាផ្សេងទៀតអ្នកចូលរួមឆ្លើយមានមានចំនួនតិចតួច គឺ ផែនដីវិទ្យា(៣នាក់) សីលធម៌ពលរដ្ឋ(២នាក់) ភាសបារាំង និងសេដ្ឋកិច្ច (១នាក់) ។

ដ្យាក្រាមទី១៖ ចំនួនសិស្សតាមកម្រិតថ្នាក់ (នាក់)




តាមដ្យាក្រាមទី១ សិស្សដែលបានចូលរួមបំពេញកម្រងសំណួរមាន ថ្នាក់ទី១០ ចំនួន ៣៣នាក់ ស្រី ១៩នាក់ ថ្នាក់ទី១១មាន ៥១នាក់ ស្រី ៣៦នាក់ និងថ្នាក់ទី១២មាន ៥៦នាក់ស្រី ៣៣នាក់។ យើងសង្កេតឃើញថា សិស្សស្រីដែលបានចូលរួមឆ្លើយសំណួរមានចំនួនច្រើនជាងសិស្សប្រុស។

ដ្យាក្រាមទី២៖ អតីតភាពការងារក្នុងមុខតំណែងរបស់នាយកសាលា បណ្ណារក្ស គ្រូបង្រៀន (%)




តាមដ្យាមក្រាមទី២ បង្ហាញថាអ្នកដែលបានចូលរួម ឆ្លើយសំណួរ មាននាយកសាលាចំនួន ៣៣.៣២% ស្មើ២នាក់ បណ្ណារក្ស ចំនួន២៨.៥៧% ស្មើ២នាក់ និងគ្រូបង្រៀន ចំនួន៤.២៨% ស្មើ៣នាក់ មានអតីតភាពការងារក្នុងមុខតំណែងរបស់ខ្លួនទាបជាង៣ឆ្នាំ។ នាយកសាលាចំនួន១៦.៦៦%ស្មើ ១នាក់ បណ្ណារក្សចំនួន២៨.៥៧% ស្មើ២នាក់ គ្រូបង្រៀនចំនួន៧.១៤% ស្មើ៥នាក់ មានអតីតភាព ការងារក្នុងមុខតំណែងរបស់ខ្លួនចន្លោះពី៣ឆ្នាំ ទៅ៥ឆ្នាំ។ នាយកសាលាចំនួន៣៣.៣២% ស្មើ២នាក់ គ្រូបង្រៀនចំនួន ៣៤.៣២% ស្មើ២៤នាក់ មានអតីតភាពការងារក្នុងមុខតំណែងរបស់ខ្លួន ចន្លោះពី៦ឆ្នាំ ទៅ១០ឆ្នាំ។ នាយកសាលាចំនួន១៦.៦៦% ស្មើ១នាក់ បណ្ណារក្សចំនួន៤២.៨៤% ស្មើ៣នាក់ និងគ្រូបង្រៀនចំនួន ៥៤.២៦% ស្មើ៣៨នាក់ មានអតីតភាពការងារ ក្នុងមុខតំណែងរបស់ខ្លួនលើសពី១០ឆ្នាំ។ នេះបង្ហាញថា គ្រូបង្រៀនដែលបានចូលរួមឆ្លើយសំណួរភាគច្រើន មានអតីតភាពការងារលើសពី១០ឆ្នាំ ។

### *៤.១.២ ធនធានមនុស្ស ការបំប៉នសមត្ថភាព ការប្រជុំ និងការចុះពិនិត្យតាមដាន*

#### *៤.១.២.១ ធនធានមនុស្សជាបណ្ណារក្ស*

**តារាងទី៣៖ ចំនួនបណ្ណារក្សបណ្ណារក្សសរុបមធ្យម និងចំនួនថ្នាក់សរុបមធ្យម**

| | វិទ្យាល័យ គ្មានសាលាធនធាន | វិទ្យាល័យ មានសាលាធនធាន | ស្តង់ដា |
|---|---|---|---|
| ចំនួនថ្នាក់សរុបមធ្យម | ៣១.២ថ្នាក់ | ៥៣.៥ថ្នាក់ | >៣១ថ្នាក់ |
| ចំនួនបណ្ណារក្សសរុបមធ្យម | ២.៤នាក់ | ៣.៥ | ៣នាក់ |

**តាមតារាងទី៣** វិទ្យាល័យគ្មានសាលាធនធាន មានចំនួនថ្នាក់សរុបមធ្យម ៣១.២ថ្នាក់>៣១ថ្នាក់ និងមានចំនួនបណ្ណារក្ស សរុបមធ្យម ២.៤នាក់ <៣នាក់។ បើតាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា ឆ្នាំ ២០១៤ សាលាដែលមានចំនួនសិស្សសរុបចាប់ពី៣១ថ្នាក់ឡើងទៅ ត្រូវមានបណ្ណារក្សចំនួន៣នាក់។ ដូច នេះ ការប្រើចំនួនបណ្ណារក្សនៃសាលាវិទ្យាល័យ គ្មានសាលាធនធានធៀបនឹងស្តង់ដាបណ្ណាល័យមធ្យម សិក្សា គឺនៅមានកម្រិតទាបជាងបន្តិច។ ចំណែកវិទ្យាល័យមានសាលាធនធានចំនួនថ្នាក់សរុបមធ្យម ស្មើ ៥៣.៥ថ្នាក់ >៣១ថ្នាក់ និងចំនួនបណ្ណារក្សសរុបមធ្យម ៣.៥ នាក់ ។ បើតាមស្តង់ដាបណ្ណាល័យមធ្យម សិក្សា វិទ្យាល័យមានសាលាធនធាន ការប្រើចំនួនបណ្ណារក្សមានកម្រិតលើស្តង់ដាបានកំណត់។ បើតាម សេចក្តីណែនាំលេខ៣៣ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៤ សាលាដែលមានចំនួនថ្នាក់ចាប់ពី៣០ ទៅ៤០ថ្នាក់ ត្រូវប្រើ បណ្ណារក្សចំនួន២នាក់ និងសាលាដែលមានចំនួនថ្នាក់ចាប់ពី ៤១ថ្នាក់ទៅ ៦០ថ្នាក់ត្រូវ ប្រើបណ្ណារក្ស ចំនួន៣នាក់ និងអាចស្នើសុំចំនួនបណ្ណារក្សបន្ថែម បើបណ្ណាល័យសាលារៀននោះមានបំពាក់ សម្ភារ បរិក្ខារ និង មានសកម្មភាព ។

តារាងទី៤៖ ចំនួនបណ្ណារក្សតាមអាយុ

| អាយុ | ២១-៣០ឆ្នាំ | ៣១ - ៤០ឆ្នាំ | ៤១ - ៥០ឆ្នាំ | ៥១ - ៦០ឆ្នាំ |
|---|---|---|---|---|
| វិទ្យាល័យគ្មានសាលាធនធាន | ០០នាក់ | ០០នាក់ | ៣នាក់ | ២នាក់ |
| វិទ្យាល័យមានសាលាធនធាន | ១នាក់ | ០០នាក់ | ១នាក់ | ០០នាក់ |
| សរុបរួម | ១នាក់ | ០០នាក់ | ៤នាក់ | ២នាក់ |

តាមតារាងទី៤ បង្ហាញថា បណ្ណារក្សនៃវិទ្យាល័យគ្មានសាលាធនធាន ចំនួន៥នាក់ ក្នុងនោះ បណ្ណា-រក្សមានអាយុ ចាប់ពី៤១ឆ្នាំ ដល់ ៥០ឆ្នាំ មានចំនួន ៣នាក់ ស្មើ ៦០% និងបណ្ណារក្ស ២នាក់មានអាយុ លើ ៥០ឆ្នាំស្មើ៤០% ។ ចំណែកវិទ្យាល័យដែលមានសាលាធនធានបណ្ណារក្សមាន២នាក់ ១នាក់ស្មើ៥០%

មានអាយុ ចាប់ពី២១ ទៅ៣០ឆ្នាំ និង១នាក់ទៀតស្មើ៥០% មានអាយុចាប់ពី៤១ ទៅ៥០ឆ្នាំ ។ បើតាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា ក្រសួងអប់ រំ យុវជន និងកីឡា ឆ្នាំ២០១៤ បានបង្ហាញថា ធនធានបណ្ណារក្សត្រូវមានសុខភាពល្អ និងមានអាយុមិនលើសពី៥០ឆ្នាំ។ នេះបញ្ជាក់ថា វិទ្យាល័យគ្មាន សាលាធនធាន ធនធានបណ្ណារក្សស្ថិតក្រោមស្តង់ដាបន្តិចដោយសារតែវិទ្យាល័យទាំងនេះ មានបណ្ណារក្សអាយុ លើស៥០ឆ្នាំដល់ទៅពីរនាក់ ស្មើ៤០% ។ រីឯវិទ្យាល័យមានសាលាធនធាន ធនធានបណ្ណារក្សមានអាយុ សមស្របនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សាដែលបានកំណត់ ។

តារាងទី៥៖ កម្រិតវិជ្ជាជីវៈបណ្ណារក្ស

| កម្រិតវិជ្ជាជីវៈ | គ្រូកម្រិតមូលដ្ឋាន | គ្រូកម្រិតឧត្តម | ផ្សេងទៀត |
|---|---|---|---|
| វិទ្យាល័យគ្មានសាលាធនធាន | ៥នាក់ | ០នាក់ | ០នាក់ |
| វិទ្យាល័យមានសាលាធនធាន | ២នាក់ | ០នាក់ | ០នាក់ |
| សរុបរួម | ៧នាក់ | ០នាក់ | ០នាក់ |

តាមតារាងទី៥ បណ្ណារក្ស ទាំងអស់ទាំងវិទ្យាល័យគ្មានសាលាធនធាន ទាំងបណ្ណារក្សនៃវិទ្យាល័យមានសាលាធនធាន សុទ្ធសឹងជាគ្រូបង្រៀនកម្រិតមូលដ្ឋាន១០០% និងមិនមានបណ្ណារក្សណាម្នាក់ជាគ្រូបង្រៀន កម្រិតឧត្តមនោះទេ។ បើយើងពិនិត្យលើស្តង់ដាបណ្ណាល័យមធ្យមសិក្សាបានកំណត់ថា បណ្ណារក្សត្រូវជ្រើសរើសចេញពីគ្រូបង្រៀន ដែលមានក្របខណ្ឌគ្រូមធ្យមសិក្សាបឋមភូមិ និងមានទីលំនៅ ក្នុងមូលដ្ឋាន។ នេះបញ្ជាក់ថា ទាំងវិទ្យាល័យគ្មានសាលាធនធាន ទាំងវិទ្យាល័យមានសាលាធនធាន កម្រិតវិជ្ជាជីវៈបណ្ណារក្សដែលបានជ្រើសរើសគឺសមស្របនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សាបានកំណត់។

**តារាងទី៦៖ កម្រិតវប្បធម៌បណ្ណារក្ស**

| កម្រិតវប្បធម៌ | មធ្យមសិក្សា បឋមភូមិ | មធ្យមសិក្សា ទុតិយភូមិ | វិញ្ញាបត្រ |
|---|---|---|---|
| វិទ្យាល័យគ្មានសាលាធនធាន | ៥នាក់ | ០នាក់ | ០នាក់ |
| វិទ្យាល័យមានសាលាធនធាន | ១នាក់ | ១នាក់ | ០នាក់ |
| សរុបរួម | ៦នាក់ | ១នាក់ | ០នាក់ |

តាមតារាងទី៦ បណ្ណារក្សនៃវិទ្យាល័យគ្មានសាលាធនធាន មានបណ្ណារក្សចំនួន៥នាក់ស្មើ១០០% មានកម្រិតវប្បធម៌ត្រឹមមធ្យមសិក្សាបឋមភូមិ ចំណែកវិទ្យាល័យដែលមានសាលាធនធាន មានបណ្ណារក្សចំនួន១នាក់ ស្មើ៥០% មានកម្រិតវប្បធម៌ត្រឹមមធ្យមសិក្សាបឋមភូមិ និង១នាក់ទៀតស្មើ ៥០% មានកម្រិតវប្បធម៌មធ្យមសិក្សាទុតិយភូមិ ។ ត្រង់ចំណុចនេះ ស្តង់ដាបណ្ណាល័យមធ្យមសិក្សាមិនបានកំណត់ឡើយ។

**ដ្យាក្រាមទី៣៖ ចំណេះដឹងភាសាអង់គ្លេស បណ្ណារក្ស (%)**




**ដ្យាក្រាមទី៤៖ ចំណេះដឹងកុំព្យូទ័រ បណ្ណារក្ស (%)**



**ដ្យាក្រាមទី៣ និងទី៤** បង្ហាញថា ចំណេះដឹងភាសាអង់គ្លេស និងកុំព្យូទ័ររបស់បណ្ណារក្ស វិទ្យាល័យមានសាលាធនធាន មានបណ្ណារក្ស៥០% ស្មើ១នាក់ ចេះភាសាអង់គ្លេស និងកុំព្យូទ័រខ្លះៗ និងបណ្ណារក្ស៥០% ទៀត ស្មើ១នាក់ មានចំណេះដឹងភាសាអង់គ្លេសនិងកុំព្យូទ័រខ្សោយ។ រីឯវិទ្យាល័យមានសាលាធនធាន បណ្ណារក្ស ដែលជាសំណាកទាំងអស់ចំនួន១០០% ស្មើ៥នាក់ មានចំណេះដឹងភាសាអង់គ្លេស និងកុំព្យូទ័រខ្សោយ។ ចំណែកចំណេះដឹងលើផ្នែកកុំព្យូទ័រមានបណ្ណារក្ស២០% ស្មើ១នាក់ ចេះកុំព្យូទ័រ តិចតួច និង៨០%ស្មើ៤នាក់ មានចំណេះដឹងកុំព្យូទ័រខ្សោយ ។ តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សារបស់ក្រសួងអបរំ យុវជន និងកីឡា ឆ្នាំ២០១៤ បណ្ណារក្សត្រូវមានចំណេះដឹង ភាសាអង់គ្លេស និងកុំព្យូទ័រខ្លះៗ ដែលអាចជួយបំពេញការងារ រដ្ឋបាលផ្សេងៗក្នុងបណ្ណាល័យបាន។ ដូច្នេះ ទាំងវិទ្យាល័យគ្មានសាលាធនធាន ទាំងវិទ្យាល័យមានសាលាធនធាន ចំណេះដឹង ភាសាអង់គ្លេស និងកុំព្យូទ័ររបស់បណ្ណារក្ស មិនទាន់បំពេញតាមកម្រិតស្តង់ដាបណ្ណាល័យ មធ្យមសិក្សានៅឡើយ គឺមានកម្រិតចំណេះដឹងទាបជាង កម្រិតស្តង់ដាដែលបានកំណត់។ មូលហេតុដែលបណ្ណារក្សមានចំណេះដឹងភាសាអង់គ្លេស និងកុំព្យូទ័រខ្សោយ ព្រោះខណៈពួកគាត់នៅរៀនថ្នាក់កម្រិតមូលដ្ឋាន ការរៀនភាសាអង់គ្លេសមិនមានភាពទូលំទូលាយនៅឡើយ។

**ដ្យាក្រាមទី៥៖ ការបំប៉នសមត្ថភាពបណ្ណារក្សស្តីពីការគ្រប់គ្រងបណ្ណាល័យ**



**ដ្យាក្រាមទី៦ ៖ ការធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍របស់បណ្ណារក្ស**




**ដ្យាក្រាមទី ៥ និងទី៦** បង្ហាញថាមានតែបណ្ណារក្ស នៅវិទ្យាល័យមានសាលាធនធាន៥០%ស្មើ១នាក់ប៉ុណ្ណោះ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលលើការងារគ្រប់គ្រងបណ្ណាល័យ ចំណែកបណ្ណារក្ស ១០០% ស្មើ៦នាក់ នៅវិទ្យាល័យគ្មានសាលាធនធាន មិនមានបណ្ណារក្សណាម្នាក់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបណ្ណាល័យនោះទេ។ ចំពោះការធ្វើទស្សនកិច្ចសិក្សានៅបណ្ណាល័យនានាដើម្បីផ្លាស់ប្តូរបទពិសោធន៍ ទាំងវិទ្យាល័យមានសាលាធនធាន ទាំងវិទ្យាល័យគ្មានសាលាធនធាន មិនមានបណ្ណារក្សណាម្នាក់បានចូលរួមនោះទេ។ បើតាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា បណ្ណារក្សត្រូវទទួលបានវគ្គបណ្តុះបណ្តាល មូលដ្ឋាន វគ្គបំប៉នបន្ត និងវគ្គកុំព្យូទ័រ សម្រាប់គ្រប់គ្រងបណ្ណាល័យ។ នេះបញ្ជាក់ថាបណ្ណារក្សដែល កំពុងបំពេញការងារនៅតាម វិទ្យាល័យនានា មិនមានចំណេះដឹងជំនាញគ្រប់គ្រងបណ្ណាល័យនៅឡើយ និងមិនធ្លាប់បានធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ ពីបណ្ណារក្សនៃបណ្ណាល័យល្អៗដទៃម្តងណាទេ ។

### *៤.១.២.២ ការប្រជុំក្នុងសាលា*

ដ្យាក្រាមទី៧៖ ការបញ្ចូលប្រធានបទបណ្ណាល័យក្នុងរបៀបវារៈប្រជុំ និងការដោះស្រាយ




ដ្យាមក្រាមទី៧ បង្ហាញថា រាល់ការប្រជុំប្រចាំខែក្នុងសាលានៃវិទ្យាល័យទាំងអស់(ទាំងវិទ្យាល័យមានសាលាធនធាន និងវិទ្យាល័យគ្មានសាលាធនធាន) មានសាលា២៩% ដែលបានបញ្ចូលប្រធានបទបណ្ណាល័យក្នុងអង្គប្រជុំ និងមានការដោះស្រាយ សាលា១៤% បានបញ្ចូលប្រធានបទ បណ្ណាល័យ និងមានការដោះស្រាយបានញឹកញាប់ សាលា១៤% បានបញ្ចូលប្រធានបទបណ្ណាល័យ និងមានការដោះស្រាយបានម្តងម្កាល និងសាលា៤៣% មិនមានបញ្ចូលប្រធានបទ បណ្ណាល័យក្នុងអង្គប្រជុំ និងមិនមានការដោះស្រាយទេ។

### *៤.១.២.៣ ការពិនិត្យតាមដានរបស់ថ្នាក់លើ លើការងារអនុវត្តន៍ការគ្រប់គ្រងបណ្ណាល័យ*

ដ្យាក្រាមទី៨៖ ចំនួនសាលាទាំង៧ (បណ្ណាល័យ) ដែលថ្នាក់លើបានចុះពិនិត្យតាមដានប្រចាំឆ្នាំ (%)



ដ្យាក្រាមទី៨៖ បង្ហាញថាមានសាលា១៤.២៨% ស្មើ១សាលា ថ្នាក់ក្រសួងអប់រំ និងថ្នាក់ មន្ទីរអប់រំ យុវជន និងកីឡា មិនបានចុះត្រួតពិនិត្យតាមដានប្រចាំឆ្នាំ និងមានសាលាចំនួន៨៥.៧២% ស្មើ៦សាលា ថ្នាក់ក្រសួងអប់រំ និងថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាបានចុះពិនិត្យតាមដាន១ដងក្នុង១ឆ្នាំ។ រីឯថ្នាក់ការិយាល័យអប់រំ មានសាលាចំនួន២៨.៥៦% ស្មើ២សាលា ដែលថ្នាក់ការិយាល័យអប់រំស្រុកមិនបានចុះត្រួតពិនិត្យតាមដានប្រចាំឆ្នាំទេ ហើយមានសាលាចំនួន៧១.៤៤% ស្មើ៥សាលា ថ្នាក់ការិយាអប់រំស្រុកបានចុះពិនិត្យតាមដាន១ដងក្នុងមួយឆ្នាំ។ តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា២០១៤ កំណត់ថាថ្នាក់ជាតិត្រូវចុះប្រមូលព័ត៌មាន និងកែលម្អប្រព័ន្ធអនុវត្តន៍ ការងារបណ្ណាល័យ១ដង ក្នុង១ឆ្នាំ។ ចំណែកថ្នាក់ក្រោមជាតិ មានថ្នាក់មន្ទីរអប់រំ និងថ្នាក់ការិយាល័យអប់រំ ត្រូវចុះតាមដានការអនុវត្ត រៀងរាល់១ឆមាសម្តង ។ នេះយើងអាចសន្និដ្ឋានបានថា ថ្នាក់ជាតិ បានធ្វើការពិនិត្យតាមដានបណ្ណាល័យសាលា បានល្អ ៨៥.៨២% បើធៀបនឹងស្តង់ដា។ ចំពោះថ្នាក់ក្រោមជាតិមានថ្នាក់មន្ទីរអប់រំ និងថ្នាក់ការិយាល័យអប់រំ មិនទាន់បានអនុត្តការពិនិត្យតាមដានបណ្ណាល័យសាលា នៅមានកម្រិតទាបធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សាបានកំណត់ ។

### *៤.១.៣ ស្ថានភាពបណ្ណាល័យ ធនធានសម្ភារ និងធនធានឯកសារ*

#### *៤.១.៣.១ ស្ថានភាពអគារ/ បន្ទប់បណ្ណាល័យ*

តារាងទី៧៖ ស្ថានភាពបន្ទប់បណ្ណាល័យនៃវិទ្យាល័យគ្មានសាលាធនធានទាំងប្រាំ (ចំនួនសិស្សមធ្យម និងទំហំបណ្ណាល័យមធ្យម)

| | |
|---|---|
| ចំនួនសិស្សសរុបមធ្យម | ១៣៦៩នាក់ ស្រី ៦៩០នាក់ |
| បណ្តោយបន្ទប់ | ៨ម៉ែត្រ |
| ទទឹងបន្ទប់ | ៧ម៉ែត្រ |
| ខ្ពស់ផុតពីដី | ០.៣មែត្រ |

តាមតារាងទី៧ វិទ្យាល័យទាំងអស់ដែលជាសំណាកដែលបានជ្រើសរើស មានចំនួនសិស្សសរុបមធ្យម ១៣៦៩នាក់ ។ បណ្ណាល័យវិទ្យាល័យទាំងនេះមានបណ្ណាល័យលក្ខណៈជាបន្ទប់រៀនទាំងអស់ គឺ យកបន្ទប់រៀនធ្វើជាបណ្ណាល័យ ។ បន្ទប់បណ្ណាល័យមានទទឹងមធ្យម ៧ម៉ែត្រ បណ្តោយជាមធ្យមគឺ ៨ម៉ែត្រ ស្ថិតនៅផ្ទាល់ដីដែលមានកម្ពស់គ្រឹះ មធ្យម ០.៣ម៉ែត្រជាមធ្យម ។ គុណភាព ដំបូល ជញ្ជាំង ទ្វារ បង្អួចរឹងមាំមធ្យម ។ នៅរដូវវស្សាមានបញ្ហាប្រឈមនឹងសំណើមពីខាងក្រោម ដែលធ្វើឱ្យសៀវភៅឯកសារខូចខាតប្រសិនបើដាក់ផ្ទាល់នឹងកម្រាលឥដ្ឋ ។ បើតាម

ស្តង់ដាបណ្ណាល័យ ក្រសួងអប់រំឆ្នាំ ២០១៤ បានបង្ហាញថា បណ្ណាល័យបន្ទប់រៀនដែល ត្រូវតាមស្តង់ដាបណ្ណាល័យមធ្យមសិក្សាគឺ មានទទឹង និងបណ្តោយ ៧ម៉ែត្រ គុណនឹង ៨ម៉ែត្រ ចំពោះសាលាដែលមានសិស្ស ក្រោម ១០០០នាក់។ បើសាលាដែលមានសិស្សលើសពី ១០០០នាក់ ទំហំបណ្ណាល័យត្រូវគុណនឹងពីរ។ ដូចនេះទំហំបណ្ណាល័យសាលាទាំងអស់ខាងលើមិនទាន់ត្រឹមត្រូវ តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សានៅឡើយ ព្រោះវិទ្យាល័យទាំងអស់មានចំនួនសិស្សសរុបមធ្យម លើសពី ១០០០នាក់ ។

### *៤.១.៣.២ ស្ថានភាពសម្ភារ បរិក្ខារ បំពាក់ក្នុងបណ្ណាល័យ*

តារាងទី៨៖ ចំនួនសិស្សសរុបមធ្យម នៃវិទ្យាល័យគ្មានសាលាធនធាន និងវិទ្យាល័យមានសាលាធនធាន

| | វិទ្យាល័យគ្មានសាលាធនធាន | វិទ្យាល័យមានសាលាធនធាន |
|---|---|---|
| ចំនួនសិស្សសរុបមធ្យម | ១៣៦៩នាក់ | ២៣០០នាក់ |

ដ្យាក្រាមទី៩៖ ចំនួនធ្នើមុខពីរ និងចំនួនធ្នើមុខមួយសម្រាប់ដាក់សៀវភៅ ក្នុងបណ្ណាល័យសាលា




ដ្យាក្រាមទី៩ វិទ្យាល័យគ្មានសាលាធនធាន ចំនួនធ្នើមុខមួយមធ្យមស្មើ៣ ចំនួនធ្នើមុខពីរសម្រាប់ដាក់សៀវភៅមាន ៤.២។ រីឯវិទ្យាល័យមានសាលាធនធាន ចំនួនធ្នើមុខមួយមធ្យមមាន ៧.០០ និងចំនួន

ផ្ទៃមុខពីរមធ្យមមាន៤។ តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សាក្រសួងអប់រំ ២០១៤ បានកំណត់ថា ចំពោះបណ្ណាល័យជាបន្ទប់រៀន ត្រូវមានផ្ទៃមុខមួយបួនថ្នាក់ (០.៥០ម៉ែត្រគុណ ១.៥០ម៉ែត្រ គុណ១.៨០ម៉ែត្រ) ចំនួន៤ និងផ្ទៃមុខពីរមានបួនថ្នាក់ (ទំហំ ០.៣០ម៉ែត្រ គុណ១.៥០ម៉ែត្រ គុណ១.៨០ម៉ែត្រ) ចំនួន៣។ បើចំនួនសិស្សលើសពី១០០០នាក់ ត្រូវបំពាក់បរិក្ខារគុណនឹងពីរ។ ចំណែក បណ្ណាល័យជាអគារត្រូវមាន ផ្ទៃមុខពីរបួនថ្នាក់ (០.៥០ម៉ែត្រគុណ ១.៥០ម៉ែត្រ គុណ១.៨០ម៉ែត្រ) ចំនួន៦ និងផ្ទៃមុខមួយមាន បួនថ្នាក់ (ទំហំ ០.៣០ម៉ែត្រ គុណ១.៥០ម៉ែត្រ គុណ១.៨០ម៉ែត្រ) ចំនួន៨។ បើចំនួនសិស្សលើសពី១០០០នាក់ ត្រូវបំពាក់បរិក្ខារគុណនឹងពីរ។ វិទ្យាល័យគ្មានសាលាធនធាន និងវិទ្យាល័យមានសាលាធនធាន មានបណ្ណាល័យជាបន្ទប់ មិនមែនជាបណ្ណាល័យដាច់ដោយឡែក ហើយសាលាទាំងនេះមានចំនួន សិស្សសរុបមធ្យមលើសពី១០០០នាក់។ ដូចនេះតាមដ្យាក្រាមខាងលើ បង្ហាញថា ការបំពាក់បរិក្ខារ ផ្ទៃមុខមួយ និងផ្ទៃមុខពីរសម្រាប់ដាក់សៀវភៅនៃវិទ្យាល័យគ្មានសាលាធនធាន នៅមានកម្រិតទាបជាង កម្រិតស្តង់ដាប្រហែលពាក់កណ្តាល។ ប៉ុន្តែមានវិទ្យាល័យខ្លះបានច្នៃធ្វើផ្ទៃដាក់សៀវភៅ ដែលមិនមានលក្ខណៈស្តង់ដាដោយខ្លួនឯងផងដែរ។ ចំណែកវិទ្យាល័យមានសាលាធនធាន ការបំពាក់បរិក្ខារផ្ទៃមុខមួយ និងផ្ទៃមុខពីរសម្រាប់ដាក់សៀវភៅ មានកម្រិតប្រហាក់ប្រហែល ស្តង់ដាបានកំណត់។

ដ្យាក្រាមទី១០៖ ស្ថានភាពនៃការប្រើប្រាស់បណ្តាញអ៊ិនធឺណិតក្នុងបណ្ណាល័យ(%)



ដ្យាក្រាមទី១០ បង្ហាញពី ការតភ្ជាប់ និងដំណើរការនៃការប្រើប្រាស់ សេវាអ៊ិនធឺណែតក្នុងបណ្ណា-ល័យ។ វិទ្យាល័យមានសាលាធនធាន គ្រូ៧០% ស្មើ១៤នាក់ ឆ្លើយថា ក្នុងបណ្ណាល័យ មានបំពាក់ប្រព័ន្ធសេវាអ៊ិនធឺណិតនិងប្រើប្រាស់បានចាំប្រចាំ គ្រូ១៥% ស្មើ៣នាក់បានឆ្លើយថាមាន បំពាក់ប្រព័ន្ធសេវាអ៊ិនធឺណិតនិងប្រើប្រាស់បានម្តងម្កាល និងគ្រូ១៥% ស្មើ៣នាក់ទៀត បានឆ្លើយថាមានបំពាក់សេវាអ៊ិនធឺណិតនិងប្រើប្រាស់មិនបាន។ ចំណែកវិទ្យាល័យគ្មានសាលាធនធាន គ្រូ៦% ស្មើ៦នាក់ បានឆ្លើយថាបណ្ណាល័យមានបំពាក់ប្រព័ន្ធសេវាអ៊ិនធឺណិត និងប្រើប្រាស់បានជាប្រចាំ គ្រូ២%ស្មើ ៣នាក់បានឆ្លើយថា បណ្ណាល័យមានបំពាក់ប្រព័ន្ធសេវាអ៊ិនធឺណិតតែប្រើប្រាស់មិនបាន និងគ្រូ៩២% បានឆ្លើយថាបណ្ណាល័យ មិនមានបំពាក់ប្រព័ន្ធសេវាអ៊ិនធឺណិតទេ។

### *៤.១.៣.៣ ធនធានឯកសារក្នុងបណ្ណាល័យ*

តារាងទី៩៖ ចំនួនសៀវភៅសិក្សាគោល និងសៀវភៅគ្រូសម្រាប់សិស្សគ្រូធ្វើការសិក្សាស្រាវជ្រាវ

| | N | Mean | Std Deviation | កម្រិត | លំដាប់ |
|---|---|---|---|---|---|
| វិទ្យាល័យគ្មានសាលាធនធាន | | | | | |
| ស្ថានភាពសៀវភៅសិក្សាគោល សម្រាប់ សិស្សស្រាវជ្រាវ | 5 | 4.40 | 0.54 | ខ្ពស់ | ១ |
| ស្ថានភាពសៀវភៅគ្រូ សម្រាប់គ្រូស្រាវជ្រាវ | 5 | 2.00 | 1.41 | ទាប | ២ |
| វិទ្យាល័យមានសាលាធនធាន | | | | | |
| ស្ថានភាពសៀវភៅសិស្សសម្រាប់សិស្ស ស្រាវជ្រាវ | 2 | 5.00 | 0.00 | ខ្ពស់ | ៣ |
| ស្ថានភាពសៀវភៅគ្រូសម្រាប់គ្រូស្រាវជ្រាវ | 2 | 4.00 | 1.41 | ខ្ពស់ | ៤ |

តារាងទី៩៖ តាមOxford and Burry – Stock(1995) តម្លៃ Mean 1.0 ទៅ2.4 មានន័យថាអនុវត្តបានកម្រិតទាប តម្លៃ Mean ចាប់ពី 2.5 ទៅ3.4 មានន័យថាការអនុវត្តបានកម្រិតមធ្យម និងតម្លៃMean

ចាប់ពី 3.5 ឡើងទៅមានន័យថាការអនុវត្តបានកម្រិតខ្ពស់។ តារាងទី៩ បង្ហាញថា ស្ថានភាពរក្សាទុកសៀវភៅសិក្សាគោលសម្រាប់សិស្សធ្វើការសិក្សាស្រាវជ្រាវក្នុងបណ្ណាល័យ បណ្ណារក្សអនុវត្តបានកម្រិតខ្ពស់ ទាំងវិទ្យាល័យគ្មានសាលាធនធាន ទាំងវិទ្យាល័យមានសាលាធនធាន។ រីឯស្ថានភាពរក្សាទុក សៀវភៅគ្រូសម្រាប់គ្រូស្រាវជ្រាវ ក្នុងបណ្ណាល័យ បណ្ណារក្សវិទ្យាល័យគ្មានសាលាធនធាន អនុវត្តបានកម្រិតទាប (តម្លៃ mean = 2.00) ចំពោះវិទ្យាល័យដែលមានសាលាធនធាន បណ្ណារក្សអនុវត្តបានកម្រិតខ្ពស់ (mean=4.00) បើធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។ តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា ២០១៤ បណ្ណារក្សត្រូវរក្សាទុកសៀវភៅសិក្សាគោល ក៏ដូចសៀវភៅគ្រូ មួយមុខវិជ្ជា១ក្បាលគ្រប់កម្រិតថ្នាក់ទាំងអស់ ដើម្បីទុកសម្រាប់សិស្សធ្វើការសិក្សាស្រាវជ្រាវក្នុងបណ្ណាល័យ។

ដ្យាក្រាមទី១១៖ ចំនួនសៀវភៅអានក្រៅពីសៀវភៅសិក្សាគោលគិតជាមធ្យម




តាមដ្យាក្រាមទី១១ វិទ្យាល័យមានសាលាធនធានមានសៀវភៅអានមធ្យមចំនួន៣៦០២ ក្បាល និងមាន ៨៥៨ចំណងជើង។ ចំណែកវិទ្យាល័យគ្មានសាលាធនធាន មានសៀវភៅអាន មធ្យមចំនួន៣៩៩ក្បាល និងមាន២៩៤ចំណងជើង។ បើតាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា ២០១៤ ចំពោះបណ្ណាល័យជាអគារត្រូវមានសៀវភៅអានយ៉ាងតិចចំនួន១០០០ក្បាល និងមាន ចំណងជើងសៀវភៅ ៨០០យ៉ាងតិច។ ចំណែកបណ្ណាល័យជាបន្ទប់រៀនត្រូវមានសៀវភៅអាន យ៉ាងតិច៦០០ក្បាល និងមាន៥០០ចំណងជើងឡើងទៅ។ នេះបញ្ជាក់ថា វិទ្យាល័យមានសាលាធនធាន ចំនួនសៀវភៅអាន មានកម្រិតលើស្តង់ដាដែល

បានកំណត់៦ដង និងមានចំនួនចំណងជើងសៀវភៅ ប្រហាក់ប្រហែលនឹងស្តង់ដាដែរ។ ចំណែកវិទ្យាល័យគ្មានសាលាធនធាន ចំនួនសៀវភៅអាន និងចំនួនចំណងជើងសៀវភៅនៅមានកម្រិតទាបជាងស្តង់ដាជិត ២ដង។ នេះបង្ហាញថា ការគ្រប់គ្រងសៀវភៅអាន នៅវិទ្យាល័យមានសាលាធនធានអនុវត្តបានល្អ ហើយការគ្រប់គ្រងសៀវភៅអាននៅវិទ្យាល័យគ្មានសាលាធនធានអនុវត្តមិនទាន់បានល្អនៅឡើយ។

តារាងទី១០៖ យោបល់សិស្សលើស្ថានភាពសៀវភៅអានសម្រាប់សិស្សស្រាវជ្រាវក្នុងបណ្ណាល័យ(%)

| | មានគ្រប់គ្រាន់ | មានភាគច្រើន | មានខ្លះៗ | មិនមាន |
|---|---|---|---|---|
| វិទ្យាល័យគ្មានសាលាធនធាន | ៦% | ៣៦% | ៥៨% | ៩% |
| វិទ្យាល័យមានសាលាធនធន | ៣៦.៨% | ៤៤.៧% | ១៨.៤% | 0% |

តាមតារាងទី១០ វិទ្យាល័យគ្មានសាលាធនធានសិស្ស៦% បានឆ្លើយថាក្នុងបណ្ណាល័យសាលារបស់គាត់ មានសៀវភៅអានគ្រប់គ្រាន់ សិស្ស៣៦% បានឆ្លើយថាបណ្ណាល័យសាលារបស់គាត់មានសៀវភៅអានភាគច្រើន សិស្ស៥៨% បានឆ្លើយថា បណ្ណាល័យសាលារបស់គាត់មានសៀវភៅអាន ខ្លះៗ និងសិស្ស៩% បានឆ្លើយថាបណ្ណាល័យសាលារបស់គាត់មិនមានសៀវភៅសម្រាប់គាត់ចង់អានទេ។ ចំពោះវិទ្យាល័យមានសាលាធនធាន សិស្ស៣៦.៨% បានឆ្លើយថា បណ្ណាល័យសាលារបស់គាត់មានសៀវភៅអានគ្រប់គ្រាន់ សិស្ស៤៤.៧% ឆ្លើយថា បណ្ណាល័យសាលារបស់គាត់ មានសៀវភៅអាន ភាគច្រើន និងសិស្ស១៨.៤% ឆ្លើយថា បណ្ណាល័យសាលារបស់គាត់មានសៀវភៅអានខ្លះៗ។

### *៤.១.៤. ការងារបច្ចេកទេស រដ្ឋបាល និងសេវាកម្មបណ្ណាល័យ*

#### *៤.១.៤.១ ការងារបច្ចេកទេស និងរដ្ឋបាល*

តារាងទី១១៖ ការចុះបញ្ជីរួម បញ្ជីសារពើភ័ណ្ឌ ការរៀបសៀវភៅចូលធ្នើ ការចុះលេខកូដដឺវេ៉ ការរៀបចំបទបញ្ជាផ្ទៃក្នុង ការរៀបឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន ការរៀបចំបញ្ជីខ្ចីសង សម្រាប់វិទ្យាល័យគ្មានសាលាធនធាន

| បរិយាយ | N | Mean | Std. Deviation | កម្រិត | លំដាប់ |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| ការចុះបញ្ជីរួមសៀវភៅចូលថ្មី | 5 | 3.20 | 1.10 | មធ្យម | ១ |
| ការរៀបចំបញ្ជីសារពើភ័ណ្ឌសៀវភៅ | 5 | 1.20 | 0.45 | ទាប | ២ |
| ការរៀបចំសៀវភៅចូលធ្នើ | 5 | 2.40 | 0.89 | ទាប | ៣ |
| ការធ្វើចំណាត់ថ្នាក់ដឺវ៉េ និងចុះលេខកូដដឺវ៉េ | 5 | 1.00 | 0.00 | ទាប | ៤ |
| ការរៀបចំបទបញ្ជាផ្ទៃក្នុងបណ្ណា-ល័យ | 5 | 3.80 | 1.30 | ខ្ពស់ | ៥ |
| ការរៀបចំឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន | 5 | 3.20 | 1.10 | មធ្យម | ៦ |
| ការរៀបចំបញ្ជីខ្ចីសង | 5 | 4.00 | 0.71 | ខ្ពស់ | ៧ |

តាមរាងទី១១ តាមOxford and Burry – Stock(1995) តម្លៃ Mean 1.0 ទៅ2.4 មានន័យថាអនុវត្តបានកម្រិតទាប តម្លៃ Mean ពី2.5 ទៅ3.4 មានន័យថាការអនុវត្តបានកម្រិតមធ្យម និងតម្លៃ Mean ចាប់ពី 3.5 ឡើងទៅមានន័យថាការអនុវត្តបានកម្រិតខ្ពស់។ ដូចនេះយើងឃើញថា ការងារមួយ ចំនួនទាក់ទងនឹងការងារបច្ចេកទេស និងរដ្ឋបាល បណ្ណារក្សវិទ្យាល័យគ្មានសាលាធនធានអនុវត្តបានកម្រិតខ្ពស់ ដូចជា ការរៀបចំ បទបញ្ជាផ្ទៃក្នុងបណ្ណាល័យ និងការរៀបចំ បញ្ជីខ្ចីសង។ ចំណែកការងារចុះបញ្ជីរួមសៀវភៅចូលថ្មី និងការរៀបចំឧបករណ៍សម្រង់ស្ថិតិសៀវភៅចូលអាន បណ្ណារក្សវិទ្យាល័យគ្មានសាលាធនធានអនុវត្តបានកម្រិតមធ្យម។ ចំពោះការរៀបចំបញ្ជីសារពើភ័ណ្ឌសៀវភៅ ការរៀបចំសៀវភៅចូលធ្នើ ការធ្វើចំណាត់ថ្នាក់ដឺវ៉េ និងចុះលេខកូដដឺវ៉េ បណ្ណារក្សអនុវត្តបានកម្រិតទាប។ សរុបមកការអនុវត្ត ការងារបច្ចេកទេស និង កិច្ចការរដ្ឋបាលខាងលើ បណ្ណាអនុវត្តបានកម្រិត មធ្យមធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។

**តារាងទី១២៖ ការចុះបញ្ជីរួម បញ្ជីសារពើភ័ណ្ឌ ការរៀបសៀវភៅចូលធ្នើ ការចុះលេខកូដដឺវ៉េ ការរៀបចំបទបញ្ជាផ្ទៃក្នុង ការរៀបឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន ការរៀបចំបញ្ជីខ្ចីសង (សម្រាប់វិទ្យាល័យមានធនធាន)**

| បរិយាយ | N | mean | Std. Deviation | កម្រិត | លំដាប់ |
|---|---|---|---|---|---|
| ការចុះបញ្ជីរួមសៀវភៅចូលថ្មី | 2 | 4.50 | 0.71 | ខ្ពស់ | ១ |
| ការរៀបចំបញ្ជីសារពើភ័ណ្ឌសៀវភៅ | 2 | 2.50 | 0.71 | ទាប | ២ |
| ការរៀបចំសៀវភៅចូលធ្នើ | 2 | 4.00 | 0.00 | ខ្ពស់ | ៣ |

| | | | | | |
|---|---|---|---|---|---|
| ការធ្វើចំណាត់ថ្នាក់ជីវ័ និងចុះលេខកូដជីវ័ | 2 | 3.50 | 0.71 | មធ្យម | ៤ |
| ការរៀបចំបទបញ្ជាផ្ទៃក្នុងបណ្ណាល័យ | 2 | 5.00 | 0.00 | ខ្ពស់ | ៥ |
| ការរៀបចំឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន | 2 | 5.00 | 0.00 | ខ្ពស់ | ៦ |
| រៀបចំបញ្ជីខ្ចីសង | 2 | 5.00 | 0.00 | ខ្ពស់ | ៧ |

តាមរាងទី១២ តាមOxford and Burry – Stock (1995) តម្លៃ Mean1.0 ទៅ2.4 មានន័យថាអនុវត្តបានកម្រិតទាប តម្លៃ Mean ចាប់ពី 2.5ទៅ 3.4 មានន័យថាការអនុវត្តបានកម្រិតមធ្យម និងតម្លៃ Mean ចាប់ពី 3.5ឡើងទៅមានន័យថាការអនុវត្តបានកម្រិតខ្ពស់។ ដូចនេះយើងឃើញថា ការងារមួយចំនួន ទាក់ទងការងារបច្ចេកទេស និងរដ្ឋបាល បណ្ណារក្សវិទ្យាល័យមានសាលាធនធានអនុវត្តបានកម្រិតខ្ពស់ ដូចជាការចុះបញ្ជីរួមសៀវភៅចូលថ្មី ការរៀបចំសៀវភៅចូលធ្នើ ការរៀបចំបទបញ្ជាផ្ទៃក្នុងបណ្ណា-ល័យការរៀបចំឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន ការរៀបចំបញ្ជីខ្ចីសង។ ចំណែកការធ្វើចំណាត់ជីវ័ និងការចុះលេខកូដជីវ័សៀវភៅ បណ្ណារក្សវិទ្យាល័យមានសាលាធនធានអនុវត្តបានកម្រិតមធ្យម។ ចំពោះការចុះបញ្ជីសារពើភ័ណ្ឌសៀវភៅ បណ្ណារក្សអនុវត្តបានកម្រិតទាប។ បើនិយាយជារួមកិច្ចការបច្ចេកទេស និងការងាររដ្ឋបាលខាងលើ បណ្ណារក្សវិទ្យាល័យមានសាលាធនធានអនុវត្តបានកម្រិតខ្ពស់ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។

**ដ្យាក្រាមទី១២៖ ការសម្អាតបណ្ណាល័យ(%)**



ដ្យាក្រាមទី១២ បង្ហាញថាវិទ្យាល័យមិនមានសាលាធនធាន សិស្ស៤៤.៤% បានឆ្លើយថា បណ្ណារក្សតែងតែសម្អាតបណ្ណាល័យជាប្រចាំ សិស្ស២៨.៣% បានឆ្លើយថា បណ្ណារក្ស បានសម្អាតបណ្ណាល័យបានញឹកញាប់ សិស្ស១៥.២% បានឆ្លើយថា បណ្ណារក្ស បានសម្អាតបណ្ណាល័យបានម្តងម្កាល និងសិស្ស ១២.១% បានឆ្លើយថាបណ្ណារក្សមិនបានសម្អាតបណ្ណាល័យទេ។ ចំពោះវិទ្យាល័យមានសាលាធនធាន សិស្ស៨៦.៨% បានឆ្លើយថាបណ្ណារក្សតែងតែ សម្អាតបណ្ណាល័យជាប្រចាំ សិស្ស១៣.២% បានឆ្លើយថា បណ្ណារក្សបានសម្អាតបណ្ណាល័យញឹកញាប់ ។ តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា ក្រសួងអប់រំ ២០១៤ បង្ហាញថា បណ្ណារក្ស ត្រូវបោសសម្អាតបន្ទប់បណ្ណាល័យ សម្ភារបរិក្ខារ និងឯកសារជាប្រចាំ។ យើងអាចបញ្ជាក់បានថា បណ្ណារក្សនៃវិទ្យាល័យមានសាលាធនធាន អនុវត្តការងារសម្អាតបណ្ណាល័យបានល្អ ៨៦.៨% ដោយគោរពតាមការណែនាំនៃឯកសារស្តង់ដាបណ្ណាល័យមធ្យមសិក្សា។ ចំណែកវិទ្យាល័យ គ្មានសាលាធនធាន បណ្ណារក្សអនុវត្តការសម្អាតបណ្ណាល័យបានកម្រិតល្អតែ ៤៤.៤% ប៉ុណ្ណោះ។

ដ្យាក្រាមទី១៣៖ ការណែនាំសិស្សចូលអានក្នុងបណ្ណាល័យ




ដ្យាក្រាមទី១៣ បង្ហាញថាវិទ្យាល័យគ្មានសាលាធនធាន សិស្ស២៩% បានឆ្លើយថា បណ្ណារក្សតែងតែណែនាំសិស្សអំពីការស្វែងរក និងការប្រើប្រាស់សៀវភៅ សិស្ស២៥% បានឆ្លើយថា បណ្ណារក្សបានណែនាំ ពីការស្វែងរក និងការប្រើប្រាស់សៀវភៅ បានញឹកញាប់ សិស្ស៣១% បានឆ្លើយថា បណ្ណារក្សបានណែនាំ ពីការស្វែងរក និងការប្រើប្រាស់សៀវភៅបានម្តងម្កាល និងសិស្ស១៥% បានឆ្លើយថាបណ្ណារក្សមិនបានណែនាំ ពីរការស្វែងរក និងការប្រើប្រាស់សៀវភៅទេ។ ចំពោះវិទ្យាល័យមានសាលាធនធាន សិស្ស

១០.៥% បានឆ្លើយថា បណ្ណារក្សតែងតែណែនាំពីការស្វែងរក និងការប្រើប្រាស់សៀវភៅជាប្រចាំ សិស្ស ៤៧.៤% បានឆ្លើយថា បណ្ណារក្សបានណែនាំពីការស្វែងរក និងការប្រើប្រាស់សៀវភៅបានញឹកញាប់ សិស្ស៣១.៦% បានឆ្លើយថា បណ្ណារក្សបានណែនាំ ពីការស្វែងរក និងការប្រើប្រាស់សៀវភៅបានម្តងម្កាល សិស្ស១០.៥% បានឆ្លើយថា បណ្ណារក្សមិនបានណែនាំពីការស្វែងរក និងការប្រើប្រាស់សៀវភៅនោះទេ។ តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា ២០១៤ បណ្ណារក្ស ត្រូវណែនាំ សិស្សជាក្រុម ឬជាបុគ្គលស្តីពី ការស្វែងរក និងការថែទាំសៀវភៅនៅពេលប្រើប្រាស់ និងឱ្យយល់ ពីតម្រូវការរបស់ពួកគេពេលពួកគេចូលបណ្ណាល័យ។ ដូចនេះបណ្ណារក្សទាំងសាលា វិទ្យាល័យគ្មានសាលាធនធាន និងបណ្ណារក្ស វិទ្យាល័យមានសាលាធនធានបានអនុវត្តតាមស្តង់ដា ។

### *៤.១.៤.២ សេវាកម្មបណ្ណាល័យ*

ដ្យាក្រាមទី១៤៖ ការគោរពពេលម៉ោងធ្វើការ




ដ្យាក្រាមទី១៤ បង្ហាញពីនិយតភាពការងារបណ្ណារក្សវិទ្យាល័យគ្មានសាលាធនធាន អ្នកឆ្លើយសំណួរ ៤៥% ស្មើ ៤៥នាក់ បានឆ្លើយថាបណ្ណារក្សគោរពពេលម៉ោងធ្វើការបានទៀងទាត់ អ្នកឆ្លើយសំណួរ ៣២% ស្មើ៣២នាក់បានឆ្លើយថា បណ្ណារក្សគោរពពេលម៉ោងធ្វើការបានញឹកញាប់ អ្នកឆ្លើយសំណួរ ២០%

ស្មើ២០នាក់បានឆ្លើយថា បណ្ណារក្សគោរពពេលម៉ោងធ្វើការបានម្តងម្កាល និងអ្នកឆ្លើយសំណួរ ៣% ស្មើ ៣នាក់ បានឆ្លើយថា បណ្ណារក្សកម្រមកធ្វើការ ។ ចំពោះវិទ្យាល័យធនធាន អ្នកឆ្លើយសំណួរ ៦១.៥% ស្មើ ២៥នាក់ បានឆ្លើយថា បណ្ណារក្សគោរពពេលម៉ោងធ្វើការបានទៀងទាត់ អ្នកឆ្លើយសំណួរ ៣៥.៩% ស្មើ ១៤នាក់ បានឆ្លើយថា បណ្ណារក្សគោរពពេលម៉ោងធ្វើការបានញឹកញាប់ អ្នកឆ្លើយសំណួរ ២.៦% ស្មើ១នាក់ បានឆ្លើយថា បណ្ណារក្សគោរពពេលម៉ោងធ្វើការបានម្តងម្កាល និងមិនមានអ្នកឆ្លើយសំណួរណាម្នាក់បានឆ្លើយថា បណ្ណារក្សកម្រមកធ្វើការនោះទេ ។ តាមស្តង់ដាបណ្ណាល័យមធ្យមសិក្សា ២០១៤ បណ្ណារក្សត្រូវបើកទ្វាររៀងរាល់ម៉ោងសិក្សា ករណីបណ្ណារក្សអវត្តមាននាយកសាលាត្រូវរកអ្នក ប្រចាំការបណ្ណាល័យជំនួស ។ តាមទិន្នន័យខាងលើយើងអាចនិយាយបានថា បណ្ណារក្ស ៥៣.៥% គោរពពេលម៉ោងធ្វើការបានទៀងទាត់ ចំណែកបណ្ណារក្សផ្សេងទៀតមិនបានគោរពពេលម៉ោងធ្វើការបានខ្ជាប់ខ្ជួននោះទេ ។

តារាងទី១៥៖ ស្ថិតិសិស្ស. គ្រូ អ្នកក្រៅចូលអានក្នុងបណ្ណាល័យប្រចាំខែជាមធ្យម(នាក់)




ដ្យាក្រាមទី១៥ បង្ហាញថាវិទ្យាល័យមានសាលាធនធាន ស្ថិតិសិស្សចូលអានប្រចាំខែជាមធ្យមគឺ ១២១៦ នាក់ និងគ្រូចូលអានប្រចាំខែជាមធ្យមគឺ២១នាក់ អ្នកមកពីក្រៅ ០នាក់។ ចំណែក បណ្ណាល័យវិទ្យាល័យគ្មានសាលាធនធាន ចំនួនសិស្សចូលអានប្រចាំខែជាមធ្យមគឺ ៤២៨នាក់ និងគ្រូ មាន០២នាក់ និងអ្នកមកពីក្រៅ ០នាក់ ។ ស្ថិតិសិស្សវិទ្យាល័យមានសាលាធនធានមានចំនួនច្រើនលើសលុបបើធៀបនឹងវិទ្យាល័យគ្មានសាលាធនធាន នេះគឺដោយសារតែ សាលាធនធានមានបណ្ណាល័យធនធាន មាន

ស្តង់ដាបន្ទប់ធំទូលាយ មានបំពាក់សម្ភារ បរិក្ខារ អគ្គីសនី កង្ហារ អ៊ិនធឺណិត បន្ទប់មានផាសុខភាព ជាពិសេស បណ្ណាល័យធនធានមានរៀបចំកាលវិភាគសម្រាប់សិស្សចូលអានក្នុងបណ្ណាល័យ ។

### *៤.១.៥ ទស្សនៈ នាយកសាលា បណ្ណារក្ស គ្រូ សិស្សចំពោះការគ្រប់គ្រងបណ្ណាល័យធៀបនឹងស្តង់ដា បណ្ណាល័យមធ្យមសិក្សា*

### *៤.១.៥.១. ការយល់ឃើញរបស់គ្រូពីសារៈសំខាន់នៃបណ្ណាល័យ និងសេវាកម្មបណ្ណាល័យ*

**ដ្យាក្រាមទី១៦៖ ទស្សនៈរបស់គ្រូចំពោះបណ្ណាល័យទាក់ទងការរៀនសូត្ររបស់សិស្ស**




ដ្យាមក្រាមទី១៦ បង្ហាញពីទស្សនៈយល់ឃើញអំពីបណ្ណាល័យ យើងឃើញថា ទាំងវិទ្យាល័យមានសាលាធនធាន និងវិទ្យាល័យមិនមានសាលាធនធាន គ្រូចំនួន ៩៥.៧% ស្មើ ៦៧នាក់ យល់ឃើញថាបណ្ណាល័យមានសារៈសំខាន់ណាស់សម្រាប់ការបង្រៀន និងរៀន គ្រូ២.៩%ស្មើ២នាក់ បានយល់ឃើញថាបណ្ណាល័យមានសារៈសំខាន់ល្មម ចំណែកគ្រូចំនួន ១.៤% ស្មើ១នាក់ យល់ឃើញថាបណ្ណាល័យមានសារៈសំខាន់តិចតួច សម្រាប់ការបង្រៀន និងរៀន។ នេះយើងឃើញថាគ្រូបង្រៀនភាគច្រើនបានយល់ថា បណ្ណាល័យពិតជាមានសារៈសំខាន់ណាស់សម្រាប់ ការអភិវឌ្ឍ ការបង្រៀន និងរៀន ។

### *៤.១.៥.២ ស្ថានភាពរបស់គ្រូក្នុងការប្រើប្រាស់សេវាកម្មបណ្ណាល័យសម្រាប់ការបង្រៀន និងរៀន*




ដ្យាក្រាមទី១៧ បង្ហាញថា គ្រូភាគច្រើន ៦៤%ក្នុងវិទ្យាល័យទាំងប្រាំពីរ ដែលអ្នកសិក្សា ចុះស្រាវជ្រាវ បានប្រើប្រាស់សេវាកម្មបណ្ណាល័យម្ដងម្កាល ប៉ុណ្ណោះ លើការបង្រៀន និងរៀន ។ មូលហេតុនេះដោយពួកគាត់បានយល់ថា បណ្ណាល័យនៅក្នុងសាលារៀនរបស់ពួកគាត់ មានបន្ទប់តូចចង្អៀត មិនជាសសុកភាព មិនមានសៀវភៅ ឯកសារ សម្រាប់ធ្វើការស្រាវជ្រាវសម្បូរបែបនោះទេ ។ ហើយគោលបំណងដែលពួកគាត់ចូលបណ្ណាល័យភាគច្រើនគឺ ចូលខ្ចីសៀវភៅសិក្សាគោល និងសៀវភៅសម្រាប់គ្រូពីបណ្ណាល័យ ។

### *៤.១.៥.៣ ការយល់ឃើញរបស់គ្រូ លើទម្លាប់អានរបស់សិស្ស*



ដ្យាក្រាម១៨ បង្ហាញថា គ្រូប្រហាក់ប្រហែលគ្នាបាន យល់ឃើញលើសិស្សដែលចូលចិត្តអានសៀវភៅក្នុងបណ្ណាល័យ សិស្សដែលចូលចិត្តអានឯកសារតាមទូរស័ព្ទនិងសិស្សមិនចូលចិត្តអានសៀវភៅ។ គ្រូ៣៧% ឆ្លើយថាសិស្សមិនចូលចិត្តអានសៀវភៅក្នុងបណ្ណាល័យទេដោយសារបណ្ណាល័យ មិនសូវ សម្បូរឯកសារអាន ។ គ្រូ៣២% បានឆ្លើយថា សិស្សភាគច្រើនចូលចិត្តអានសៀវភៅតាមទូរស័ព្ទ ដោយសារសិស្សភាគភាគច្រើនមានទូរស័ព្ទSmart Phone សម្រាប់ប្រើប្រាស់ ។ គ្រូ៣០% បានឆ្លើយថា សិស្សភាគច្រើនមិនចូលចិត្តអានសៀវភៅទេ ដោយសារពួកគេមិនសូវយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ។

**ដ្យាក្រាមទី១៩ ៖ ទស្សនៈរបស់គ្រូចំពោះសេវាកម្មបណ្ណាល័យសាលារៀនរបស់ខ្លួន**




ដ្យាក្រាមទី១៩ បង្ហាញពីការយល់ឃើញរបស់គ្រូ វិទ្យាល័យគ្មានសាលាធនធាន គ្រូ១២%ស្មើ១២នាក់យល់ឃើញថាសេវាកម្មបណ្ណាល័យមានលក្ខណៈល្អ គ្រូ៣៥%ស្មើ៣៥នាក់ យល់ឃើញថាសេវាកម្មបណ្ណាល័យមានលក្ខណៈល្អបង្គួរ គ្រូ៤២% ស្មើ ៤២នាក់ យល់ឃើញថាសេវាកម្មបណ្ណាល័យមាន លក្ខ-ណៈមធ្យម និងគ្រូ ១២%ស្មើ១២នាក់ យល់ឃើញថា សេវាកម្មបណ្ណាល័យនៅមានកម្រិតខ្សោយនៅឡើយ ។ ចំពោះសេវាកម្មបណ្ណាល័យនៃសាលារបស់គាត់កំពុងបង្រៀន ។ ចំពោះវិទ្យាល័យមានសាលាធនធាន គ្រូ ៦០% ស្មើ ១២នាក់ បានយល់ឃើញថា សេវាកម្មបណ្ណាល័យមានលក្ខណៈល្អ គ្រូ៣៥%ស្មើ ៧នាក់យល់ឃើញថា សេវាកម្មបណ្ណាល័យមានលក្ខណៈល្អបង្គួរ និងគ្រូ ៥%ស្មើ ១នាក់យល់ឃើញថា សេវាកម្មបណ្ណាល័យមានលក្ខណៈមធ្យម ។ យើងឃើញថា វិទ្យាល័យគ្មានសាលាធនធានអនុវត្តផ្នែក សេវាកម្មបណ្ណាល័យបានល្អតែ ៤២%ប៉ុណ្ណោះ ចំណែកវិទ្យាល័យមានសាលាធនធាន អនុវត្តបានល្អ ៦០% ។

### *៤.១.៥.៤ បញ្ហាប្រឈមពាក់ព័ន្ធនឹងបណ្ណាល័យ*

តារាងទី១៣៖ ការយល់ឃើញរបស់គ្រូលើបញ្ហាប្រឈមពាក់ព័ន្ធនឹងបណ្ណាល័យ

| | ចំនួនអ្នកឆ្លើយ (%) វិ. គ្មានសាលាធនធាន | ចំនួនអ្នកឆ្លើយ(%) វិ.មានសាលាធនធាន |
|---|---|---|
| និយ័តភាពការងារបណ្ណារក្សនៅមានកម្រិត | ៤៤% | ៥០% |
| ការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រង នៅមានកម្រិត | ២៨% | ៤០% |
| បណ្ណាល័យគ្មានឯកសារអានគ្រប់គ្រាន់ | ៧៤% | ២០% |
| បន្ទប់អានសៀវភៅមិនមានផាសុភាព | ៥៨% | ១០% |
| គ្រូមិនយកចិត្តទុកដាក់ជំរុញសិស្សអាន | ២៥% | ២៥% |
| បណ្ណាល័យខ្វះការឧបត្ថម្ភគាំទ្រ | ៤% | 0% |

តារាងទី១៣ បង្ហាញថាវិទ្យាល័យគ្មានសាលាធនធាន មានបញ្ហាប្រឈមខ្លាំងចំនួនបី ដែលគ្រូបានឆ្លើយច្រើនជាងគេគឺ (១) គ្រូ ៧៤%ស្មើ៣៧នាក់ បានឆ្លើយថា បណ្ណាល័យគ្មានឯកសារអានគ្រប់គ្រាន់ (២) គ្រូ៥៨% ស្មើ២៩នាក់ បានឆ្លើយថា បន្ទប់អានសៀវភៅមិនមានផាសុកភាព (៣) គ្រូ៤៤% ស្មើ២២នាក់ បានឆ្លើយ ថានិយ័តភាពការងារបណ្ណារក្សនៅមានកម្រិត ។ ចំពោះបញ្ហាប្រឈមផ្សេងទៀតដូចជា ការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងសាលា គ្រូមិនយកចិត្តទុកដាក់ជំរុញសិស្សចូលអាន និងបណ្ណាល័យ ខ្វះការឧបត្ថម្ភគាំទ្រ គ្រូបានលើឡើងថាមានបញ្ហាប្រឈមតិចតួច ។ រីឯវិទ្យាល័យមាន សាលាធនធាន គ្រូបានលើកឡើងនូវបញ្ហាប្រឈមធំពីរគឺ(១)គ្រូ ៥០% ស្មើ១០នាក់បានយល់ថា និយ័តភាពការងារបណ្ណារក្ស នៅមានកម្រិត (២) គ្រូ ៤០% ស្មើ៨នាក់ បានយល់ថា ការយកចិត្តទុកដាក់របស់ គណៈគ្រប់គ្រងសាលានៅមានកម្រិត ។ ចំពោះបញ្ហាប្រឈមផ្សេងទៀតគ្រូតិចតួចបានលើកឡើង ជាបញ្ហាប្រឈម ដូចជា បណ្ណាល័យគ្មានឯកសារអានគ្រប់គ្រាន់ បន្ទប់អានមិនមានផាសុកភាព គ្រូមិនយកចិត្តទុក ដាក់ជំរុញសិស្សចូលអាន បណ្ណល័យ ខ្វះការឧបត្ថម្ភគាំទ្រ ។

តារាងទី១៤៖ ការយល់ឃើញរបស់នាយកសាលាលើបញ្ហាប្រឈមពាក់ព័ន្ធនឹងបណ្ណាល័យ ( វិទ្យាល័យគ្មានសាលាធនធាន )

| បរិយាយ | ចំនួនអ្នកឆ្លើយ(%) |
|---|---|
| បន្ទប់តូចចង្អៀត មិនមានផាសុកភាព | ៦០% |

| | |
|---|---|
| ខ្វះសម្ភារ បរិក្ខារ និងអគ្គិសនី | ២០% |
| ខ្វះសៀវភៅសម្រាប់អាន | ២០% |
| សិស្សបោះបង់ការសិក្សាមិនបានសងសៀវភៅជូនសាលាវិញ | ២០% |
| បណ្ណារក្សមិនបានឆ្លងកាត់វគ្គជំនាញគ្រប់គ្រងបណ្ណាល័យ | ៤០% |
| ការប្រមូលសៀវភៅសិក្សាគោលពីសិស្សមិនបានគ្រប់ និងមានសៀវភៅខូច | ២០% |
| បន្ទប់បណ្ណាល័យជ្រាបទឹកពីកម្រាលខាងក្រោមនៅរដូវវស្សា | ៤០% |

តារាងទី១៤ បង្ហាញថាវិទ្យាល័យមិនមានសាលាធនធាន នាយកសាលា ៦០% ស្មើ៣នាក់ បានលើកឡើងថា បន្ទប់បណ្ណាល័យតូចចង្អៀតមិនមានផាសុកភាព ជាបញ្ហាប្រឈមខ្លាំងជាង ចំពោះបញ្ហាប្រឈមបន្ទាប់គឺ នាយក ៤០% ស្មើ២នាក់ បានលើកឡើងថាបញ្ហាប្រឈមគឺ បណ្ណារក្ស មិនបាន ឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រងបណ្ណាល័យ និងម្យ៉ាងទៀតបន្ទប់បណ្ណាល័យស្ថិតនៅ ជាន់ផ្ទាល់ដីជ្រាបទឹកពីខាងក្រោមនៅរដូវវស្សា ។ នាយក ២០% ស្មើ១នាក់ បានលើកពីបញ្ហាប្រឈមមួយ ចំនួនទៀតដូចជា បណ្ណាល័យខ្វះ សម្ភារ បរិក្ខារ អគ្គិសនី បណ្ណាល័យខ្វះសៀវភៅអាន ការប្រមូលសៀវភៅពីសិស្សមានការលំបាកមានការបាត់បង់និងខូច។

**តារាងទី ១៥៖ ការយល់ឃើញរបស់បណ្ណារក្សលើបញ្ហាប្រឈម (វិទ្យាល័យមិនមានសាលាធនធាន)**

| បរិយាយ | ចំនួនអ្នកឆ្លើយ(%) |
|---|---|
| បណ្ណារក្សមិនបានទទួលការបណ្តុះបណ្តាលជំនាញបណ្ណាល័យ | ៦០% |
| សៀវភៅអានមានតិចតួច | ៦០% |
| បន្ទប់អានតូច មិនមានផាសុកភាព | ៦០% |
| ខ្វះសម្ភារ បរិក្ខារ | ៦០% |
| ថវិកាទ្រទ្រង់បណ្ណាល័យមានតិចតួច | ៤០% |
| គ្មានបណ្តាញអគ្គិសនី | ២០% |
| ខ្វះសៀវភៅសិក្សាគោលសម្រាប់សិស្ស | ២០% |
| នាយកសាលាមិនសូវយកចិត្តទុកដាក់ផ្នែក បណ្ណាល័យ | ២០% |
| អគារស្រក់ទឹកភ្លៀងនៅពេលមានភ្លៀងធ្លាក់ | ២០% |

តាមតារាងទី១៥ បណ្ណារក្សចំនួន៦០% ស្មើ៣នាក់ បានលើកឡើងនូវបញ្ហាប្រឈមចំនួន៤គឺ (១) បណ្ណារក្សខ្វះជំនាញគ្រប់គ្រងបណ្ណាល័យ (២)សៀវភៅអានមានតិចតួច (៣) បន្ទប់អានតូចមិនមានផាសុកភាព (៤) ខ្វះសម្ភារបរិក្ខារ បំពាក់ក្នុងបណ្ណាល័យ ។ បណ្ណារក្ស៤០% ស្មើ២នាក់ បានលើកឡើងពីថវិកាទ្រទ្រង់បណ្ណាល័យ មានតិចតួចជាបញ្ហាប្រឈម និងបណ្ណារក្ស២០% ស្មើ១នាក់ទៀត បានលើកឡើងនូវបញ្ហាប្រឈមបួនទៀតគឺ (១) បណ្ណាល័យគ្មានបណ្ដាញអគ្គិសនី (២)ខ្វះសៀវភៅសិក្សាគោលសម្រាប់ចែកឱ្យសិស្ស (៣)នាយកសាលាមិនសូវយកចិត្តទុកដាក់ផ្នែកបណ្ណាល័យ (៤)អគារស្រក់ទឹកភ្លៀងនៅពេលមានភ្លៀងធ្លាក់ ។

### *៤.១.៥.៥ សំណូមពរផ្សេងៗរបស់អ្នកចូលរួមឆ្លើយសំណួរក្នុងការអភិវឌ្ឍបណ្ណាល័យ*

**តារាងទី១៦៖ សំណូមពររបស់គ្រូ**

| បរិយាយ | វិ.គ្មានសាលាធនធាន (%) | វិ.មានសាលាធនធាន(%) |
|---|---|---|
| ក្រសួងអប់រំសាងសង់បន្ទប់បន្ទប់បណ្ណាល័យ ធំទូលាយ និងមាន ផាសុកភាព | ៥២ | ២០ |
| ជ្រើសរើសបណ្ណារក្សមានការងាររដ្ឋបាល ច្បាស់លាស់ និងមានមនសិការវិជ្ជាជីវៈ | ១៦ | ៥ |
| ក្រសួងអប់រំផ្ដល់សៀវភៅអានដល់បណ្ណាល័យ គ្រប់គ្រាន់ | ៧៨ | ៤៥ |
| ក្រសួងអប់រំបណ្ដុះបណ្ដាលជំនាញគ្រប់គ្រង បណ្ណាល័យដល់បណ្ណារក្ស | ២០ | ១០ |
| បំពាក់អ៊ិនធឺណិត ឧបករណ៍ អេឡិចត្រូនិច ក្នុងបណ្ណាល័យ | ៣៨ | ១៥ |
| រៀបចំឱ្យមានម៉ោងសិស្សចូលអានក្នុងបណ្ណាល័យ | ១៨ | ៣៥ |
| គ្រូជួយជំរុញសិស្សចូលអានសៀវភៅក្នុងបណ្ណាល័យ | ១៦ | ១០ |
| បង្កើតកម្មវិធីគ្រប់គ្រងបណ្ណល័យ តាមបច្ចេកវិទ្យាព័ត៌មានវិទ្យា | ២ | ០ |
| ក្រសួងផ្ដល់សៀវភៅសិក្សាគោល ដល់បណ្ណាល័យ សម្រាប់ចែកជូនសិស្សឱ្យបានគ្រប់គ្រាន់ | ១០ | ៥ |
| បង្កើតបណ្ណាល័យដែលមានលក្ខណៈស្តង់ដា | ១០ | ៥ |

| | | |
|---|---|---|
| បង្កើតបណ្ណាល័យជាអគារដាច់ដោយឡែក | ២ | ០ |
| រៀបចំបង្កើតបណ្ណាល័យអេឡិចត្រូនិច | ២ | ០ |

តាមតារាងទី១៦ វិទ្យាល័យមិនមានសាលាធនធានបាន សំណូមពរចំនួនបីដែលគ្រូបានលើកឡើងច្រើនជាងគេគឺ (១)ក្រសួងអប់រំផ្តល់សៀវភៅអានដល់បណ្ណាល័យឱ្យបានគ្រប់គ្រាន់ (២)ក្រសួងអប់រំ សាង-សង់ បណ្ណាល័យធំទូលាយ និងមានផាសុកភាព (៣)បំពាក់សម្ភារបរិក្ខារ អេឡិចត្រូនិច អ៊ិនធឺណិត ក្នុងបណ្ណាល័យ។ រីឯវិទ្យាល័យធនធានគ្រូបានលើកឡើងនូវសំណូមពរច្រើនជាងគេចំនួនពីរគឺ (១)ក្រសួងអប់រំយុវជន និងកីឡា ផ្តល់សៀវភៅអានដល់បណ្ណាល័យឱ្យបានគ្រប់គ្រាន់ (២)មានការរៀបចំម៉ោងសម្រាប់សិស្សចូលអានក្នុងបណ្ណាល័យ ។

តារាងទី១៧ ៖ សំណូមពររបស់សិស្សក្នុងការចូលរួមអភិវឌ្ឍបណ្ណាល័យ

| | វិ.មិនមាន សាលាធនធាន(%) | វិ.មានសាលា ធនធាន(%) |
|---|---|---|
| ចង់បានសៀវភៅអានសម្បូរបែប | ១០០ | ៣៥ |
| ចង់បានបណ្ណាល័យមានផាសុកភាព | ៣០ | ២.៥ |
| បំពាក់អ៊ិនធឺណិត កង្ហារ គ្រឿងអេឡិចត្រូនិចក្នុងបណ្ណាល័យ | ៣៩ | ១៧.៥ |
| ចង់បានបណ្ណាល័យដែល បើកទ្វារ រាល់ម៉ោងធ្វើការ | ២០ | ២.៥ |
| ចង់បានបណ្ណារក្សល្អ មានជំនាញ  សេវាកម្មល្អ | ១៧ | ១០ |
| ចង់បានបណ្ណាល័យធំទូលាយ | ៣៣ | ២.៥ |
| ចង់ឱ្យសិស្សយកចិត្តទុកដាក់ស្រាវជ្រាវ ក្នុងបណ្ណាល័យ | ០ | ២.៥ |
| ចង់បានសៀវភៅសិក្សាគោលគ្រប់គ្រាន់ | ២ | ២.៥ |
| គ្រូជួយណែនាំសិស្សពីសារៈសំខាន់នៃការអាន | ៥ | ៧.៥ |
| រៀបចំម៉ោងចូលបណ្ណាល័យសម្រាប់សិស្ស | ៣ | ៥ |
| សប្បុរសជនជួយគាំទ្រ បណ្ណាល័យ | ១ | ៥ |
| ចង់បានបណ្ណាល័យជាបន្ទប់ដាច់ដោយឡែក | ៤ | ៥ |

តាមតារាងទី ១៧ វិទ្យាល័យមិនមានសាលាធនធាន សិស្សភាគច្រើនបានលើកឡើងនូវ សំណូមពរចំនួនបួនគឺ (១)សិស្ស ១០០% ចង់បានបណ្ណាល័យមានឯកសារអានសម្បូរបែប (២)សិស្ស៣៩% ចង់បាន

បណ្ណាល័យមានបំពាក់អ៊ិនធឺណិត កង្ហារ អេឡិចត្រូនិច ។ ចង់បានបណ្ណាល័យមានបំពាក់អ៊ិនធឺណិត កង្ហារ គ្រឿងអេឡិចត្រូនិច សិស្ស ៣៣% ចង់បានបណ្ណាល័យមានបន្ទប់ធំទូលាយ និងសិស្ស៣០%ចង់បានបណ្ណាល័យមានផាសុកភាព។ វិទ្យាល័យមានសាលាធនធាន មានសំណូមពរពីរដែល សិស្សបានលើកឡើងច្រើនជាងគេគឺ (១)សិស្ស៣៥%ចង់បានបណ្ណាល័យមានឯកសារ សម្បូរបែប (២) សិស្ស ១៧.៥% ចង់បានគ្រឿងសម្ភារ បរិក្ខារ អេឡិចត្រូនិចបំពាក់ក្នុងបណ្ណាល័យ ។

**តារាងទី ១៨៖ សំណូមពររបស់នាយកសាលាក្នុងការចូលរួមអភិវឌ្ឍបណ្ណាល័យ ( វិទ្យាល័យ គ្មានសាលាធនធាន )**

| បរិយាយ | ចំនួនអ្នកបានឆ្លើយសំណួរ(%) |
|---|---|
| ក្រសួងអប់រំផ្តល់សៀវភៅអានតាមនិយាមស្តង់ដា | ៨០ |
| ក្រសួងអប់រំបំពាក់គ្រឿងបរិក្ខារបណ្ណាល័យគ្រប់គ្រាន់ | ២០ |
| ក្រសួងអប់រំបើកវគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រងបណ្ណាល័យ ដល់ បណ្ណារក្ស | ៦០ |
| ក្រសួងអប់រំសាងសង់បណ្ណាល័យដាច់ដោយឡែក | ៤០ |
| ក្រសួងអប់រំផ្តល់សៀវភៅសិក្សាគោលបន្ថែម | ២០ |

តាមតារាងទី១៨៖ នាយកសាលា៨០% ចង់ឱ្យក្រសួងអប់រំ យុវជន និងកីឡា ផ្តល់សៀវភៅអានថ្មីៗតាមនិយាមស្តង់ដា ។ នាយកសាលា៦០% ចង់ឱ្យក្រសួងអប់រំ យុវជន និងកីឡា បើកវគ្គបណ្តុះបណ្តាល ជំនាញគ្រប់គ្រងបណ្ណាល័យ ។ នាយកសាលា៤០%ចង់ឱ្យក្រសួងអប់រសង់បណ្ណាល័យដាច់ដោយឡែក និងនាយកសាលា ២០% ចង់ឱ្យក្រសួងអប់រំ យុវជន និងកីឡាបំពាក់គ្រឿងបរិក្ខារបណ្ណាល័យគ្រប់គ្រាន់ និងផ្តល់សៀវភៅសិក្សាគោល គ្រប់គ្រាន់ ។

**តារាងទី១៩ ៖ សំណូមពររបស់បណ្ណារក្សក្នុងការចូលរួមអភិវឌ្ឍបណ្ណាល័យ (វិទ្យាល័យគ្មានសាលាធនធាន)**

| បរិយាយ | ចំនួនអ្នកបានឆ្លើយសំណួរ(%) |
|---|---|
| ក្រសួងអប់រំបណ្តុះបណ្តាលបណ្ណារក្សលើជំនាញគ្រប់គ្រងបណ្ណាល័យ | ៨០ |
| លើកទឹកចិត្តបណ្ណារក្សដែលធ្វើការពីរវេន | ២០ |
| ក្រសួងអប់រំផ្តល់សៀវភៅអានបន្ថែម | ៨០ |
| ក្រសួងអប់រំផ្តល់សម្ភារបរិក្ខារបណ្ណាល័យឱ្យបានគ្រប់គ្រាន់ | ២០ |

| | |
|---|---|
| សាលាតភ្ជាប់ប្រព័ន្ធសេវាអ៊ិនធឺណិតក្នុងបណ្ណាល័យ | ៤០ |
| ក្រសួងអប់រំសាងសង់បណ្ណាល័យមានលក្ខណៈស្តង់ដា | ២០ |
| ក្រសួងអប់រំផ្តល់ថវិកាសម្រាប់ទ្រទ្រង់បណ្ណាល័យឱ្យបានគ្រប់គ្រាន់ | ២០ |
| គ្រូជួយជំរុញសិស្សឱ្យចូលអានក្នុងបណ្ណាល័យ | ២០ |
| ក្រសួងអប់រំផ្តល់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ | ៤០ |

តាមតារាងទី១៩ បណ្ណារក្ស៨០% បានធ្វើសំណូមពរ ក្រសួងអប់រំ យុវជន និងកីឡា បើកវគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រង បណ្ណាល័យដល់បណ្ណារក្ស និងសំណូមពរក្រសួងអប់រំ ផ្តល់សៀវភៅអានបន្ថែម។ បណ្ណារក្ស៤០% សំណូមពរក្រសួងអប់រំ យុវជន និងកីឡា ផ្តល់សៀវភៅសិក្សាគោលបន្ថែម និងសំណូមពរនាយកសាលា តភ្ជាប់បណ្តាញអ៊ិនធឺណិតក្នុងបណ្ណាល័យ។ បណ្ណារក្ស ២០% សំណូមពរ ផ្សេងៗទៀត ដូចជា (១) លើកទឹកចិត្តបណ្ណារក្សធ្វើការពីរវេន (២)ក្រសួងអប់រំ យុវជន និងកីឡាផ្តល់សម្ភារបរិក្ខារបណ្ណាល័យឱ្យបានគ្រប់គ្រាន់ (៣)ក្រសួងអប់រំ យុវជន និងកីឡាសាងសង់បណ្ណាល័យមាន លក្ខណៈស្តង់ដា (៤) ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ថវិកាសម្រាប់ទ្រទ្រង់បណ្ណាល័យឱ្យបានគ្រប់គ្រាន់។

### *៤.២ ការពិភាក្សា*

ផ្អែកលើលទ្ធផល នៃការសិក្សាស្រាវជ្រាវ យើងអាចសំយោគ កម្រងសំណួរជារួម មានបីចំណុចដូចខាងក្រោម ៖

#### *៤.២.១ ការយល់ឃើញរបស់ នាយកសាលា បណ្ណារក្ស គ្រូ សិស្ស លើស្ថានភាពនៃការគ្រប់គ្រង បណ្ណាល័យ*

- គ្រូ៩៥.៧% យល់ឃើញថា បណ្ណាល័យមានសារៈសំខាន់ណាស់ សម្រាប់ការបង្រៀន និងរៀន។
- សេវាកម្មបណ្ណាល័យវិទ្យាល័យមានសាលាធនធានគ្រូ៦០% យល់ឃើញថាល្អ ចំណែកវិទ្យាល័យគ្មានសាលាធនធាន មានគ្រូតែ ១២% ប៉ុណ្ណោះយល់ថាល្អ គ្រូភាគច្រើន(៤២%) យល់ថាផ្នែកសេវាកម្មបណ្ណាល័យមានកម្រិតមធ្យម ។
- គ្រូ សិស្ស ភាគច្រើនយល់ថាដើម្បីឱ្យការគ្រប់គ្រងបណ្ណាល័យល្អប្រសើរ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសាងសង់បន្ទប់បណ្ណាល័យធំទូលាយ និងផ្តល់សៀវភៅអាន ឱ្យបានច្រើន ។

- លោកនាយកសាលា និងបណ្ណារក្ស បានយល់ឃើញស្របគ្នាថាដើម្បីឱ្យ បណ្ណាល័យមានលក្ខណៈល្អប្រសើរ ក្រសួងអប់រំ យុវជន និងកីឡាត្រូវផ្តល់សៀវភៅអានដល់ បណ្ណាល័យតាមនិយាមស្តង់ដា និងបើកវគ្គបណ្តុះបណ្តាលផ្សេងៗលើ ជំនាញគ្រប់គ្រងបណ្ណាល័យដល់បណ្ណារក្ស ។
- គ្រូចំនួន៣៨% ដើម្បីឱ្យបណ្ណាល័យមានលក្ខណៈល្អ បណ្ណាល័យត្រូវមានសៀវភៅសិក្សាគោលសម្រាប់ ចែកជូនសិស្សអានបានគ្រប់គ្រាន់ ហើយបណ្ណាល័យត្រូវបំពាក់បណ្តាញអគ្គិសនី មានប្រព័ន្ធភ្លើងអំពូលពន្លឺ កង្ហារប្រើប្រាស់បានជាប្រចាំ និងភ្ជាប់ប្រព័ន្ធសេវាអ៊ិនធឺណិត សម្រាប់សិស្សស្រាវជ្រាវ ។

### *៤.២.២. ស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យ*

#### ក. ចំណុចវិជ្ជមាន

- ការប្រើប្រាស់និយាមបណ្ណារក្សមានចំណុចល្អ ធៀបនឹងស្តង់ដា
- វិទ្យាល័យមានសាលាធនធាន ការបំពាក់បរិក្ខារ ធ្នើដាក់សៀវភៅមានកម្រិត ប្រហាក់ប្រហែលនឹងស្តង់ដាដែលបានកំណត់
- ការងាររដ្ឋបាលនិងបច្ចេកទេស បណ្ណាល័យនៃវិទ្យាល័យមានសាលាធនធាន អនុវត្តបានកម្រិតខ្ពស់ ។
- ធនធានឯកសារបណ្ណាល័យនៃវិទ្យាល័យមានសាលាធនធាន មានចំនួនលើស្តង់ដា បានកំណត់ ។
- ការប្រើប្រាស់បណ្ណារក្សត្រឹមត្រូវ តាមកម្រិតវិជ្ជាជីវៈ គឺគ្រូបង្រៀនកម្រិតមូលដ្ឋានសមស្របតាមស្តង់ដាបានកំណត់ ។

#### ខ.បញ្ហាប្រឈមលើការគ្រប់គ្រងបណ្ណាល័យ

- ធនធានបណ្ណារក្សនៅមានកម្រិតទាប ពោលគឺ បណ្ណារក្ស ស្ទើទាំងអស់(៨៥.៧១%) មានចំណេះដឹងកុំព្យូទ័រ និងភាសាអង់គ្លេសខ្សោយ និងមិនបានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រងបណ្ណាល័យ។ មូលហេតុបណ្ណារក្សភាគច្រើន មានអាយុលើសពី ៤០ឆ្នាំ ពួកគាត់មិនបានឆ្លងកាត់ការបណ្តុះបណ្តាលផ្នែកកុំព្យូទ័រ និងភាសាអង់គ្លេសដូច សម័យបច្ចុប្បន្នទេ ។ ការរៀនភាសាអង់គ្លេស និងកុំព្យូទ័រមិនមានលក្ខណៈទូលំទូលាយ ឡើយ។

- ការងាររដ្ឋបាលបច្ចេកទេសបណ្ណារក្សវិទ្យាល័យគ្មានសាលាធនធានអនុវត្តបានកម្រិតមធ្យម ដោយសារបណ្ណារក្សមិនបានឆ្លងកាត់ វគ្គបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងបណ្ណាល័យ ខ្វះការពិនិត្យតាមដាន និងការជំរុញលើកទឹកចិត្តរបស់ថ្នាក់លើ ។
- ធនធានឯកសារ និងសម្ភារ បរិក្ខារបណ្ណាល័យ វិទ្យាល័យគ្មានសាលាធនធាន មានកម្រិតទាបជាងស្តង់ដាកំណត់។ ក្រសួងអប់រំ យុវជន និងកីឡា មិនមានគោលគារណ៍ផ្តល់សៀវ-ភៅអានថ្មីៗ ដល់បណ្ណាល័យ នាយកសាលាខ្វះការកៀរគរឯកសារសម្រាប់បណ្ណាល័យ ។
- បណ្ណារក្សវិទ្យាល័យគ្មានសាលាធនធាន ៥៥% និងបណ្ណារក្ស វិទ្យាល័យមានសាលាធនធាន ៣៨.៥%មិនបានបើកទ្វារធ្វើការជាប្រចាំ ។ បណ្ណារក្សមួយចំនួនមានកូនតូចៗ ឬចៅតូចៗ និងបណ្ណារក្សខ្លះទៀតមានបញ្ហាសុខភាពក្នុងពេលបំពេញការងារ ។
- បណ្ណារក្ស ៨៥.៧១% មិនបានទទួលការបណ្តុះបណ្តាលជំនាញគ្រប់គ្រងបណ្ណាល័យ
- ស្ថានភាពបន្ទប់បណ្ណាល័យមិនគោរពតាមស្តង់ដាបើធៀបនឹងចំនួនសិស្ស គឺ មានលក្ខណៈតូចចង្អៀត ។ មូលហេតុសាលាគ្មានលទ្ធភាពសាងសង់បន្ទប់បណ្ណាល័យដាច់ដោយឡែក។
- បណ្ណាល័យជាឃ្លាំងស្តុកសៀវភៅសិក្សាគោល ដែលធ្វើឱ្យមានភាពចង្អៀត ។
- ការអនុវត្តការពិនិត្យតាមដានរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមានកម្រិតទាប។ មន្ត្រីចុះពិនិត្យតាមដានអនុវត្តការងារមិនមានគ្រប់ជ្រុងជ្រោយ ។
- បន្ទប់បណ្ណាល័យស្រក់ទឹកនៅពេលមានភ្លៀងធ្លាក់ និងមានសំណើមពីក្រោមនៅរដូវវស្សា។
- វិទ្យាល័យគ្មានសាលាធនធាន បណ្ណាល័យមិនមានភ្ជាប់បណ្ដាញអ៊ិនធឺណិតប្រើប្រាស់ នៅឡើយ ។
- នាយកសាលាវិទ្យាល័យគ្មានសាលាធនធានមានការជំរុញសិស្សចូលអានបានតិចតួច ដោយ មិនមានការរៀបចំម៉ោងសិស្សចូលអានក្នុងបណ្ណាល័យ។
- ស្ថានភាពសៀវភៅគ្រូនៅបណ្ណាល័យ វិទ្យាល័យគ្មានសាលាធនធាន មានតិចតួចបំផុតសម្រាប់គ្រូធ្វើការសិក្សាស្រាវជ្រាវ ។ បណ្ណាល័យខ្វះការឧបត្ថម្ភគាំទ្រលើ ឯកសារសម្រាប់សិស្សអាន ។
- បណ្ណាល័យខ្វះការគាំទ្រទាំងផ្នែកសម្ភារ ទាំងផ្នែកបច្ចេកទេស ។
- បណ្ណាល័យនៃវិទ្យាល័យមួយចំនួន មិនមានបណ្តាញអគ្គិសនីប្រើប្រាស់។

- សៀវភៅសិក្សាគោលសម្រាប់ចែកឱ្យសិស្សមិនមានគ្រប់គ្រាន់ ។ បណ្ណារក្សប្រមូល សៀវភៅមិនបានមកវិញគ្រប់ចំនួនដោយសារសិស្សបោះបង់ការសិក្សាមិនបានសង សាលា វិញ ម្យ៉ាងវិញទៀតសៀវភៅថ្មីដែលសិស្សយកទៅប្រើប្រាស់ ខ្វះការថែទាំ ធ្វើឱ្យ សៀវភៅខូច មិនអាចប្រើប្រាស់បានបន្តសម្រាប់ឆ្នាំសិក្សាបន្ទាប់ ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥

# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## *៥.១ សេចក្ដីសន្និដ្ឋាន*

បណ្ណាល័យជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការលើកកម្ពស់គុណភាពអប់រំ។ តួយ៉ាង បណ្ណាល័យ ជាកន្លែងបណ្ដុះទម្លាប់អាន និងការសិក្សាស្រាវជ្រាវរបស់សិស្ស ជាកន្លែងលើកកម្ពស់ការអាន និងការសិក្សាស្រាវជ្រាវរបស់ សាធារណជនទូទៅ។ នៅប្រទេសកម្ពុជាយើងមិនទាន់មាន បណ្ណាល័យទំនើប សម្បូរបែបទេ បណ្ណាល័យសាលារៀនភាគច្រើនជាបណ្ណាល័យបន្ទប់រៀន និងសាលាខ្លះយក ទីចាត់ការ ធ្វើបណ្ណាល័យ និងសាលាខ្លះទៀត បានយកជ្រុងថ្នាក់រៀនធ្វើជាបណ្ណាល័យផងដែរ។ នេះជាបញ្ហាប្រឈមមយដែលទាក់ទងនឹង ការអានរបស់សិស្ស ។ ស្របជាមួយគ្នានេះដែរអ្នកសិក្សាស្រាវជ្រាវ បានជ្រើសរើសយកប្រធានបទមួយមក ធ្វើការសិក្សាស្រាវជ្រាវក្រោមប្រធានបទ "**ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា** " ករណីសិក្សា វិទ្យាល័យមួយចំនួនក្នុងខេត្តស្វាយរៀង។ តាមកម្រងសំណួរជាច្រើនដែលអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ ដើម្បីឱ្យសំណាកបំពេញ និងធ្វើការសម្ភាស ក្នុងគោលបំណងរកឱ្យឃើញនូវចម្លើយនៃសំណួរស្រាវជ្រាវបីគឺ (១)តើការអនុវត្តការងារគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យបានកម្រិតណា ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា? (២)តើការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការអនុវត្តការងារគ្រប់គ្រងបណ្ណាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា? (៣) តើលោកនាយកវិទ្យាល័យ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស មានទស្សនៈ ដូចម្ដេចខ្លះ ចំពោះការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា ? ក្រោយពីបានធ្វើការចុះសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ និងបកស្រាយលទ្ធផលពិភាក្សា រួចមក អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានលើស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យសាលាបានថា វិទ្យាល័យមានសាលាធនធាន ការអនុវត្តការងារគ្រប់គ្រងបណ្ណាល័យមានលក្ខណៈល្អលើផ្នែកដូចជា ស្ថានភាពបន្ទប់ បណ្ណាល័យស្អាត ធំទូលាយ មាន បំពាក់ឯកសារ សម្ភារ បរិក្ខារមានចំនួនច្រើន ការអនុវត្តការងារបច្ចេកទេសរដ្ឋបាលបណ្ណាល័យបានល្អ មានបណ្ដាញ អគ្គិសនី និងប្រព័ន្ធអ៊ិនធឺណិតសម្រាប់សិស្សធ្វើការសិក្សាស្រាវជ្រាវ។ តែនៅមានផ្នែកខ្លះ បណ្ណាល័យសាលាដែលមានវិទ្យាល័យធនធានមិនទាន់មាន លក្ខណៈស្តង់ដាគឺធនធានបណ្ណារក្សនៅមានកម្រិត បណ្ណារក្ស ៥០%មិន

បានទទួលការបណ្តុះបណ្តាលជំនាញគ្រប់គ្រង បណ្ណាល័យនិងមានចំណេះដឹងភាសាអង់គ្លេសនិងការប្រើប្រាស់កុំព្យូទ័រខ្សោយ។ រីឯស្ថានភាព នៃការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យដែលគ្មានសាលាធនធាន នៅមានបញ្ហាប្រឈម ច្រើនដូចជា សាលារៀនមិនទាន់ មានបន្ទប់បណ្ណាល័យ ធំទូលាយតាមស្តង់ដា ឯកសារសម្រាប់សិស្ស គ្រូ ធ្វើការសិក្សាស្រាវជ្រាវមានតិចតួច សម្ភារបរិក្ខារ មានតិចតួច គ្មានបណ្តាញអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ការអនុវត្តការងាររដ្ឋបាលនិងបច្ចេកទេស នៅមានកម្រិតមធ្យមធនធានបណ្ណារក្សនៅមានកម្រិត បណ្ណារក្ស១០០% មិនបានទទួលការបណ្តុះបណ្តាលជំនាញគ្រប់គ្រងបណ្ណាល័យនិងមានចំណេះដឹងភាសាអង់គ្លេស។ តែការអនុវត្តការគ្រប់គ្រងបណ្ណាល័យនៃវិទ្យាល័យទាំងនេះ ធ្វើបានល្អខ្លះ ដែរដូចជា ការប្រើប្រាស់បណ្ណារក្សបានត្រឹមត្រូវ តាមនិយាម និងតាមកម្រិតវិជ្ជាជីវៈ ដែលស្តង់ដាបណ្ណាល័យមធ្យមសិក្សាបានកំណត់។ តាមរយៈបញ្ហាប្រឈមខាងលើ លោកគ្រូអ្នកគ្រូ នៅតាមវិទ្យាល័យដែលអ្នកសិក្សាបានធ្វើការសិក្សាស្រាវជ្រាវ បានលើកឡើងថា បណ្ណាល័យមានសារៈសំខាន់ណាស់ចំពោះការបង្រៀននិងរៀន តែការអនុវត្តការងារគ្រប់គ្រងបណ្ណាល័យនៅមានកម្រិតនៅឡើយ ព្រោះថាស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យនៅមានបញ្ហាប្រឈមច្រើន ដូចជា បញ្ហាបន្ទប់អាន តូចចង្អៀតមិនមានផាសុកភាព ខ្វះឯកសារសម្រាប់សិស្សចូលសិក្សាស្រាវជ្រាវ និយ័តភាពការងារបណ្ណារក្សនៅមានកម្រិតបណ្ណារក្សមិនមានជំនាញគ្រប់គ្រងបណ្ណាល័យ បណ្ណាល័យខ្វះការឧបត្ថម្ភគាំទ្រ បណ្ណាល័យខ្វះសៀវភៅសិក្សាគោលសម្រាប់ចែកឱ្យសិស្ស ខ្វះសៀវភៅគ្រូសម្រាប់គ្រូស្រាវជ្រាវ ។

យើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវសង្ឃឹមថា ការសិក្សាស្រាវជ្រាវមួយនេះ ជាចំណែកមួយក្នុងការបញ្ជ្រាបពីសារៈសំខាន់នៃបណ្ណាល័យដល់អ្នកពាក់ព័ន្ធនឹងស្ថានភាពគ្រប់គ្រងបណ្ណាល័យ ដូចជាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មានការិយាល័យអប់រំ មន្ទីរអប់រំ នាយកសាលា គណៈកម្មការទ្រទ្រង់សាលា បណ្ណារក្ស លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស បង្កើននូវការចូលរួមអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនដែលពាក់ព័ន្ធនឹងការចូលរួម អភិវឌ្ឍបណ្ណាល័យឱ្យបានល្អដូចជា ការចូលរួមជួយផ្តល់នូវផ្នែកបច្ចេកទេស ផ្នែករដ្ឋបាលបណ្ណា-ល័យ ការឧបត្ថម្ភ គាំទ្រជាថវិកា សម្ភារ ឯកសារ ការជំរុញការអាន ការបណ្តុះទម្លាប់អាន ជាដើម។

## *៥.២ សំណូមពរ*

តាមរយៈការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំយល់ថា ការអភិវឌ្ឍបណ្ណាល័យឱ្យមានគុណភាព វាពិតជាមានសារៈសំខាន់ណាស់ សម្រាប់លើកកម្ពស់គុណភាពអប់រំឱ្យកាន់តែមានភាពប្រសើរឡើង។ ស្របជាមួយគ្នានេះដែរការសិក្សាស្រាវជ្រាវលើប្រធានបទ ″**ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងបណ្ណា-**

**ល័យនៅតាមវិទ្យាល័យធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា** "យើងខ្ញុំសង្កេតឃើញថា ស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យ នៅតាមវិទ្យាល័យក្នុងខេត្តស្វាយរៀងនៅមានកម្រិតទាបនៅឡើយ បើធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា គឺការខ្វះខាត អគារ សម្ភារ បរិក្ខារ ធនធានឯកសារ ធនធានបណ្ណារក្ស ការចុះពិនិត្យតាមដានរបស់ ថ្នាក់លើ ការឧបត្ថម្ភគាំទ្របណ្ណាល័យជាដើម។ យើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវមានសំណូមពរមួយចំនួន ដែលពាក់ព័ន្ធនឹងស្ថានភាពគ្រប់គ្រងបណ្ណាល័យ។ សំណូមពរទាំងនោះមានដូចជា៖

-ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសាងសង់អគារបណ្ណាល័យមានលក្ខណៈស្តង់ដា មានអគារដាច់ដោយឡែក នៅតាមវិទ្យាល័យនានា ត្រឹមប្រាំឆ្នាំខាងមុខ ជៀសវាងយកបន្ទប់រៀនធ្វើជាបណ្ណាល័យ។

- ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំបើកវគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រងបណ្ណាល័យដល់បណ្ណារក្ស និងនាយកសាលា នៅតាមវិទ្យាល័យឱ្យបានគ្រប់សាលា ពិសេសបណ្ណារក្សទើបនឹងចូលថ្មីសម្រាប់ឆ្នាំសិក្សាបន្ទាប់។

- ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្តល់សៀវភៅអាន សៀវភៅសិក្សាគោល និងសៀវភៅគ្រូដល់សាលាឱ្យ បានគ្រប់គ្រាន់ សម្រាប់សិស្សគ្រូធ្វើការសិក្សាស្រាវជ្រាវ ។

- ថ្នាក់ក្រសួងអប់រំ ថ្នាក់មន្ទីរអប់រំ ថ្នាក់ការិយាល័យអប់រំ ត្រូវចុះពិនិត្យតាមដានផ្ទាល់ លើការប្រើប្រាស់ បណ្ណាល័យ សៀវភៅអាន សៀវភៅសិក្សាគោល មួយឆ្នាំពីរដង និងទៀងទាត់ សូមជៀសវាង រោងចាំ ទទួលតែរបាយការណ៍ ពីសាលារៀន ។

- ថ្នាក់មន្ទីរអប់រំ ការិយាល័យអប់រំ យុវជន និងកីឡា ត្រូវបង្កើតកម្មវិធីលើកទឹកចិត្ត បណ្ណារក្ស ដែលធ្វើការងារបានល្អ ជាបណ្ណសរសើរ ជាការធ្វើទស្សនកិច្ចសិក្សា នៅបណ្ណាល័យល្អៗ ដើម្បីទទួល បានបទពិសោធន៍ល្អៗបន្ថែមទៀត។

- នាយកសាលាត្រូវមានការទទួលខុសត្រូវខ្ពស់ក្នុងការជ្រើសរើសបណ្ណារក្ស ឱ្យចូលធ្វើការក្នុងបណ្ណាល័យ ជៀសវាងជ្រើសរើសបណ្ណារក្សចេញពី គ្រូបង្រៀនដែលមានកូនតូច គ្រូបង្រៀនមានបញ្ហាសុខភាព និងគ្រូបង្រៀនអសកម្ម មកធ្វើការ។

- នាយកសាលា លោកគ្រូ អ្នកគ្រូ បណ្ណារក្ស ត្រូវលើកទឹកចិត្តសិស្សឱ្យស្រឡាញ់ការអាន តាមរយៈ

ការរៀបចំកាលវិភាគសិស្សចូលអានតាមថ្នាក់នីមួយៗ ការដាក់កិច្ចការស្រាវជ្រាវក្នុងបណ្ណាល័យ និងការរៀបចំ បរិស្ថានបណ្ណាល័យឱ្យមានសោភ័ណ្ឌភាព មានផាសុកភាព។

- នាយកសាលាគៀរគរ សប្បុរសជនឱ្យជួយចែករំលែកឯកសារអាន ឬ នាយកសាលាធ្វើទំនាក់-ទំនងជាមួយបណ្ណាល័យផ្សេងទៀតដែលនៅក្នុងតំបន់ដើម្បីផ្លាស់ប្ដូរឯកសារ សៀវភៅ ពីគ្នាទៅវិញទៅមក។

- អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ គួរតែពង្រីកវិសាលភាពនៃការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាពិសេស ភាគសំណាកឱ្យបានធំជាងនេះ សាលារៀន ស្រុក ខេត្ត នៅតាមតំបន់ជនបទ តំបន់ជួបការលំបាកជាដើម។

## ឯកសារយោង


- Bamberger,R.(1975). Promoting the Reading Habit. (pp 33-34)
- Scott, M. (2016). In Service to Iowa: Public Library Standards (Dermont, S. Ed.). Publisher: the State Library of Iowa
- Ton, S.I. (2007). Report on Secondary School Library Situation Analysis. Pedagogical Research Department of the Ministry of Education, Youth and Sport
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការនៃ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ទូត វាសនា (២០១៦) ការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល នៅក្នុងអនុវិទ្យាល័យ
- ក្រសួងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ភ្នំពេញ នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា (២០១០) ឯកសារណែនាំការងារបណ្ណាល័យសាលាមធ្យមសិក្សា ភ្នំពេញ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ប្រាក់ ទិត្យារ៉ានី (២០១៧) ឥទ្ធិពលនៃការដឹកនាំ និងគ្រប់គ្រង របស់នាយកសាលាលើ ការបង្រៀនរបស់គ្រូ
- របាយការណ៍ បូកសរុបលទ្ធផលការងារសន្និបាតអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៧ - ២០១៨ និង ទិសដៅឆ្នាំ ២០១៨ - ២០១៩
- ក្រសួងអប់រំ យុវជន និងកីឡា (២០០៧) បណ្ណាល័យ និងសៀវភៅ សម្រាប់កុមារ ភ្នំពេញ នាយកដ្ឋានបណ្ដុះបណ្ដាល នៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) ស្តង់ដាបណ្ណាល័យ ស្តង់ដាបណ្ណាល័យមធ្យមសិក្សា ភ្នំពេញនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ប៉ូល ប៊ូដេ លេខ ២ ( ២០០៦ ) ការណែនាំការងារ បណ្ណារក្ស បណ្ណាល័យជាតិនៃព្រះរាជាណាចក្រកម្ពុជា

- ក្រសួងអប់រំ យុវជន និងកីឡា (២០០៨) សៀវភៅណែនាំស្តីពីបណ្ណាល័យ ភ្នំពេញ នាយកដ្ឋានបណ្តុះបណ្តាល នៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) សេចក្តីណែនាំលេខ ៣៣ស្តីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ភ្នំពេញ នាយកដ្ឋានបុគ្គលិក នៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។
- សម្តេច ហ៊ុន សែន (២០១៣) យុទ្ធសាស្រ្តចតុកោណ នីតិកាលទី៥ ដំណាក់កាលទី៣ ភ្នំពេញ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៤ - ២០១៨ ) ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា (២០០៨) គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន ភ្នំពេញ នៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) សេចក្តីណែនាំលេខ៣៥ អយក.សណន ស្តីពីការបង្កើត ការគ្រប់គ្រង និង ដំណើរការប្រតិបត្តិការសាលាធនធាន ភ្នំពេញ នៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា ឆ្នាំ សិក្សា ២០១៦ - ២០១៧ និងទិសដៅឆ្នាំ ២០១៧ - ២០១៨ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា

# ឧបសម្ព័ន្ធ ១

# ឧបសម្ព័ន្ធ២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់បណ្ណារក្ស

ខ្ញុំបាទឈ្មោះ កុល ថាន ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ កំពុងធ្វើ និក្ខេបបទក្រោមប្រធានបទ៖ **ស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។** អាស្រ័យហេតុនេះ សូមលោកគ្រូ អ្នកគ្រូ មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះ តាមភាពជាក់ស្តែងរបស់ខ្លួន។ ព័ត៌មាន របស់លោកគ្រូ អ្នកគ្រូ នឹងត្រូវបានរក្សាការសម្ងាត់។ ការចូលរួមរបស់លោកគ្រូ អ្នកគ្រូ ពិតជាមាន សារៈសំខាន់ក្នុងការ ពង្រឹងគុណភាពអប់រំនៅប្រទេសកម្ពុជាយើង។

ជាចុងក្រោយខ្ញុំបាទសូមថ្លែងអំណរគុណដល់លោកគ្រូអ្នកគ្រូទាំងអស់ដែលបាន ចំណាយពេលវេលាក្នុងការ ចូលរួម ជាមួយខ្ញុំក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ។

*សូមមេត្តាគូសសញ្ញា ✓ ក្នុងប្រអប់ ☐ និងបំពេញចន្លោះ ព្រមទាំងឆ្លើយនូវសំណួរនីមួយៗខាងក្រោមតាមការជាក់ស្តែងរបស់ខ្លួន។*

**ផ្នែកទី១ ព័ត៌មានទូទៅ៖**

១.ភេទ....................អាយុ...............ឆ្នាំ

២. កម្រិតវប្បធម៌..........................................មុខវិជ្ជាឯកទេសបង្រៀន...................................

៣. អតីតភាពការងារជាគ្រូបង្រៀន...................ឆ្នាំ អតីតភាពជាបណ្ណារក្ស.................ឆ្នាំ ។

៤.កម្រិតវិជ្ជាជីវៈ ☐គ្រូបង្រៀនកម្រិតមូលដ្ឋាន ☐គ្រូបង្រៀនកម្រិតឧត្តម ☐ផ្សេងទៀត

៥.ចេះសរសេរ អាន ស្តាប់ និយាយ ភាសាអង់គ្លេសកម្រិតណា?

☐ល្អ ☐ល្អបង្គួរ ☐ មធ្យម ☐ ខ្សោយ

៦.ចេះប្រើប្រាស់កុំព្យូទ័រ កម្មវិធី Microsoft word and Excel កម្រិតណា?

☐ល្អ ☐ល្អបង្គួរ ☐ មធ្យម ☐ ខ្សោយ

៧. តើលោកគ្រូ អ្នកគ្រូ មានបង្រៀនម៉ោងបន្ថែមដែរឬទេ?

☐ បង្រៀន ☐ មិនបង្រៀន

ប្រសិនបើមានបង្រៀនម៉ោងបន្ថែមសូមបញ្ជាក់ចំនួនម៉ោងបន្ថែម.........................។

**ផ្នែកទី២៖ ការបំប៉នសមត្ថភាព**

៨. តើលោកគ្រូ អ្នកគ្រូ ធ្លាប់ចូលរួមសិក្ខា វគ្គបណ្តុះបណ្តាល ចំណេះដឹងអំពីការគ្រប់គ្រងបណ្ណាល័យដែរឬទេ?

☐ ធ្លាប់បានចូលរួម ☐ មិនធ្លាប់បានចូលរួម

បើលោកគ្រូ អ្នកគ្រូធ្លាប់បានចូលរួម សូមបំពេញចន្លោះខាងក្រោម៖

- លើកទី១ វគ្គបណ្តុះបណ្តាលស្តីពី.........................................................ឆ្នាំ............
- លើកទី២ វគ្គបណ្តុះបណ្តាលស្តីពី.........................................................ឆ្នាំ............
- លើកទី៣ វគ្គបណ្តុះបណ្តាលស្តីពី.........................................................ឆ្នាំ.............

៩. តើលោកគ្រូអ្នកគ្រូធ្លាប់បានចូលរួមធ្វើទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ស្តីពីការគ្រប់គ្រងបណ្ណាល័យនៅសាលាផ្សេងៗដែរឺទេ?

☐ ធ្លាប់បានចូលរួម ☐ មិនធ្លាប់បានចូលរួម

បើលោកគ្រូ អ្នកគ្រូធ្លាប់បានចូលរួម សូមបញ្ជាក់ចំនួនលើក..................................។

## ផ្នែកទី៣ ការប្រជុំក្នុងសាលា និងការចុះពិនិត្យតាមដានរបស់ថ្នាក់លើ

១០.តើរាល់ការប្រជុំប្រចាំខែនីមួយៗ តើគណៈគ្រប់គ្រងសាលាបានដាក់បញ្ចូលរបៀបវារៈទាក់ទងនឹងបណ្ណាល័យ និងដោះស្រាយបានកម្រិតណា? *( សំគាល់ ៖ ទៀងទាត់=៩០%ទៅ១០០% , ញឹកញាប់=៦០%ទៅ ៨៩% , ខ្លះៗ= ៤០%ទៅ៥៩% , ម្តងម្កាល=១%ទៅ៣៩% , មិនមាន=0% )*

- ☐មានបញ្ចូល និងបានដោះស្រាយបានទៀងទាត់
- ☐មានបញ្ចូល និងដោះស្រាយ បានញឹកញាប់
- ☐មានបញ្ចូល និងដោះស្រាយ បានខ្លះៗ
- ☐មានបញ្ចូល និងដោះស្រាយបាន ម្តងម្កាល
- ☐មិនមានការបញ្ចូល និងមិនបានដោះស្រាយ

១១. ចូរគូស ( √ ) ក្នុងកូឡោនខាងក្រោម ពី A ដល់ D៖

*កំណត់សំគាល់៖ A= មិនបានចុះ, B=បានចុះ១ដង ,C=បានចុះ២ដង, D=បានចុះលើស២ដង*

| បរិយាយ | A | B | C | D |
|---|---|---|---|---|
| ក. ការចុះពិនិត្យតាមដានរបស់ថ្នាក់ក្រសួងអប់រំក្នុង១ឆ្នាំ | | | | |
| ខ. ការចុះពិនិត្យតាមដានរបស់ថ្នាក់មន្ទីរអប់រំក្នុង១ឆ្នាំ | | | | |
| គ. ការចុះពិនិត្យតាមដានរបស់ថ្នាក់ការិយាល័យអប់រំក្នុង១ឆ្នាំ | | | | |

## ផ្នែកទី៤ អំពីធនធានសម្ភារៈ និងធនធានឯកសារៈ

១២. បណ្ណាល័យសាលាជា ☐ អគារ ☐បន្ទប់

១៣. ចូរគូស ( √ ) ក្នុងកូឡោនខាងក្រោម ពី A ដល់ F៖

*កំណត់សំគាល់៖ A=0, B=1, C=2, D=3 ,E=4 ,F =5, G=6, H=លើសពី6*

| បរិយាយ | A | B | C | D | E | F | G | H |
|---|---|---|---|---|---|---|---|---|
| ក. មានធ្នើមុខពីរសម្រាប់ដាក់សៀវភៅចំនួន | | | | | | | | |
| ខ.មានធ្នើមុខមួយសម្រាប់ដាក់សៀវភៅចំនួន | | | | | | | | |
| គ. មានតុវែងសម្រាប់សិស្សអង្គុយអានចំនួន | | | | | | | | |

១៤. តើនៅក្នុងបណ្ណាល័យរបស់លោកគ្រូ អ្នកគ្រូ មានសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់ ដែរឬទេ? *( សំគាល់៖ មានគ្រប់=១០០%, មានភាគច្រើន=៦០% -៩៩%,មានខ្លះៗ= ៤០%-៥៩%, មានភាគតិច=១០%-៣៩% , ស្ទើតែគ្មាន= ០%-៩% )*

☐ មានគ្រប់ ☐ មានភាគច្រើន ☐ មានខ្លះៗ ☐ មានភាគតិច

☐ ស្ទើតែគ្មាន

១៥.តើនៅក្នុងបណ្ណាល័យរបស់លោកគ្រូ អ្នកគ្រូ មានសៀវភៅគ្រូ គ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់ ដែរឬទេ?

☐ មានគ្រប់ ☐ មានភាគច្រើន ☐ មានខ្លះៗ ☐ មានភាគតិច

☐ ស្ទើតែគ្មាន

១៦.ចូរបំពេញទិន្នន័យក្នុងតារាងខាងក្រោម៖

| បរិយាយ | មុខវិជ្ជា សង្គម | មុខវិជ្ជា វិទ្យាសាស្ត្រ | ជាភាសា អង់គ្លេស | ជាភាសា បារាំង | ផ្សេង ទៀត | សរុប |
|---|---|---|---|---|---|---|
| ក. ចំនួនសៀវភៅអាន ( ក្រៅពីសៀវភៅសិក្សាគោល) | | | | | | |
| ខ. ចំនួនចំណងជើងសៀវភៅអាន (ក្រៅពីសៀវភៅសិក្សាគោល) | | | | | | |

### ផ្នែកទី៥ ការងារបច្ចេកទេស រដ្ឋបាល និងសេវាកម្ម

១៧. *សូមគូសធិច(✓) ក្នុងកូឡោនពី ១ ដល់ ៤ កំណត់សំគាល់៖ ១=ធ្វើបានល្អ(៨០%-១០០%) , ២=ធ្វើបានបង្គួរ (៦០%- ៧៩%) , ៣=ធ្វើបានខ្លះៗ (៤០%-៥៩%) ,៤=ធ្វើបានតិចតួច( ១%-៣៩%) ,៥= មិនមានឬមិនបានធ្វើ(០%)*

| បរិយាយ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| ក. ការចុះបញ្ជីរូមសៀវភៅចូលថ្មី | | | | | |
| ខ. ការចុះបញ្ជីសារពើភ័ណ្ឌសៀវភៅ | | | | | |
| គ. ការរៀបចំសៀវចូលធ្នើតាមលំដាប់លំដោយ | | | | | |
| ឃ. ការចុះលេខកូដ ដឺវេ និងលេខកូដសារពើភ័ណ្ឌសៀវភៅ | | | | | |
| ង. ការរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់សិស្សចូលអាន | | | | | |
| ច. ការរៀបចំឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន | | | | | |
| ឆ. ការរៀបចំបញ្ជីខ្ចី.សង និងលក្ខខ័ណ្ឌខ្ចីសង | | | | | |

១៨. ចូរបំពេញទិន្នន័យក្នុងតារាងខាងក្រោម៖

| បរិយាយ | ចំនួន | |
|---|---|---|
| | សរុប | ស្រី |
| ក. ចំនួនសិស្សចូលអានក្នុង១ខែជាមធ្យម | | |
| ខ. ចំនួនគ្រូចូលអាន ក្នុង១ខែជាមធ្យម | | |
| គ. ចំនួនអ្នកពីក្រៅចូលអានក្នុង១ខែ ជាមធ្យម | | |

១៩. តើបណ្ណាល័យសាលារបស់លោកគ្រូ អ្នកគ្រូទទួលបានការឧបត្ថម្ភគាំទ្រ ពី ស្ថាប័ន អង្គការសប្បុរសជនណាខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២០. តើលោកគ្រូ អ្នកគ្រូជួបបញ្ហាប្រឈមអ្វីខ្លះ ក្នុងការអនុវត្តន៍ការគ្រប់គ្រងបណ្ណាល័យនៅវិទ្យាល័យរបស់លោកគ្រូ អ្នកគ្រូ ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា?

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

២១. តើលោកគ្រូ/អ្នកគ្រូមានយោបល់សំណូមពរអ្វីខ្លះដើម្បីចូលរួមអភិវឌ្ឍបណ្ណាល័យឱ្យមានលក្ខណៈរីកចម្រើន?

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.......................................................................................................................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់នាយក/នាយិកា

ខ្ញុំបាទឈ្មោះ កុល ថាន ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ កំពុងធ្វើ និក្ខេបបទក្រោមប្រធានបទ៖ **ស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។** អាស្រ័យហេតុនេះ សូមលោកនាយក នាយិកា មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះ តាមភាពជាក់ស្តែងរបស់ខ្លួន។ ព័ត៌មាន របស់លោក នាយក នាយិកា នឹងត្រូវបានរក្សាការសម្ងាត់។ ការចូលរួមរបស់លោកនាយក នាយិកា ពិតជាមានសារសំខាន់ ក្នុងការពង្រឹងគុណភាពអប់រំនៅប្រទេសកម្ពុជាយើង។

ជាចុងក្រោយខ្ញុំបាទសូមថ្លែងអំណរគុណដល់លោកនាយក នាយិកាដែលបាន ចំណាយពេលវេលាក្នុងការចូលរួម ជាមួយខ្ញុំក្នុងការសិក្សាស្រាវជ្រាវដ៏មានសារសំខាន់មួយនេះ។

សូមមេត្តាគូសសញ្ញា ✓ ក្នុងប្រអប់ និងបំពេញចន្លោះ នៃសំណួរនីមួយៗខាងក្រោមតាមការជាក់ស្តែងរបស់ខ្លួន។

**ផ្នែកទី១ ព័ត៌មានទូទៅ៖**

១.ភេទ...................អាយុ...................ឆ្នាំ មុខវិជ្ជាឯកទេស....................................។

២. អតីតភាពការងារជាគ្រូបង្រៀន...................ឆ្នាំ អតីតភាពជានាយក /នាយិកា.................ឆ្នាំ ។

៣. ចំនួនសិស្សសរុប...........................នាក់ ស្រី........................នាក់ ។

៤. ចំនួនថ្នាក់សរុប ......................ថ្នាក់ ចំនួនគ្រូសរុប .....................នាក់ ស្រី ................នាក់ ។

៥. ចំនួនបន្ទប់រៀនសរុប ...................បន្ទប់

**ផ្នែកទី២ លក្ខណៈបណ្ណាល័យ ៖**

៦. មានបណ្ណាល័យជា ☐ អគារ ☐ ជាបន្ទប់រៀន

៧. ទំហំបណ្ណាល័យ បណ្តោយ............... ទទឹង....................កំពស់..................

៨. អគារ/បន្ទប់ បណ្ណាល័យសាងសង់ក្នុងគម្រោងថវិកា

☐ ក្រសួងអប់រំ ☐ ជំនួយសប្បុរសជន

☐ ផ្សេងៗ..............................................................................................

៩. គុណភាពដំបូល ជញ្ជាំង ទ្វារបង្អួច

☐ រឹងមាំល្អ ☐ រឹងមាំមធ្យម ☐ ទ្រុឌទ្រោម

១០. ការបំពាក់ប្រព័ន្ធអគ្គិសនី កង្ហារ

☐ មានប្រើប្រាស់បានជាប្រចាំ ( ប្រើបានលើសពី ៨០%)

☐ មានប្រើប្រាស់បានមិនគ្រប់គ្រាន់ (ប្រើបានពី៥០% - ៨០% )

☐ មានប្រើប្រាស់បានតិចតួច ( ប្របានតិចជាង៥០% )

☐ មិនមាន

**ផ្នែកទី៣ អំពីបណ្ណារក្ស ៖**

១១. តើសាលារៀននេះមានបណ្ណារក្សប៉ុន្មាននាក់?

☐ ១នាក់ ☐ ២នាក់ ☐ ៣នាក់

១២ តើបណ្ណារក្សក្នុងសាលារៀននេះធ្វើការប៉ុន្មានវេន?

☐ ធ្វើការ១វេន ☐ ធ្វើការ២វេន ☐ ធ្វើការ៣វេន

១៣. ចូរគូស (√) ក្នុងកូឡោនខាងក្រោមពី ១ ដល់៥ ដោយបញ្ជាក់ពីភាពទៀងទាត់របស់បណ្ណារក្ស

*កំណត់សំគាល់ ១=បានធ្វើទៀងទាត់(៩០%-១០០%), ២=បានធ្វើញឹកញាប់( ៦០%-៨៩%) , ៣=បានធ្វើខ្លះៗ(៤០%-៥៩%), ៤=បានធ្វើម្តងម្កាល( ១%-៣៩%), ៥=មិនបានធ្វើ( ០%)*

| បរិយាយ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| ក. ការចូលរួមប្រជុំប្រចាំខែនីមួយៗ | | | | | |
| ខ. ការធ្វើរបាយការណ៍ប្រចាំខែជូនអង្គប្រជុំឬ នាយកសាលា | | | | | |
| គ. ការគោរពពេលម៉ោងធ្វើការ | | | | | |

១៤. តើបណ្ណារក្សមានបានរក្សាទុកសៀវភៅសិក្សាគោលក្នុងបណ្ណាល័យ ដោយមិនបានបែងចែកដល់សិស្សដែរឬទេ?

☐ មិនបានរក្សាទុក ☐ បានរក្សាទុកសៀវភៅក្រោម១០%

☐ បានរក្សាទុកសៀវភៅពី១០%ទៅ៣០% ☐ បានរក្សាទុកសៀវភៅពី ៣១%ទៅ៥០%

☐ បានរក្សាទុកសៀវភៅលើសពី៥០%

ផ្សេងៗ.....................................................................................................................

១៥. តើលោកនាយក/នាយិកា ជួបបញ្ហាប្រឈមអ្វីខ្លះ ក្នុងការអនុវត្តន៍ការគ្រប់គ្រងបណ្ណាល័យនៅ វិទ្យាល័យរបស់លោកនាយក នាយិកា ធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា?

.........................................................................................................................

.........................................................................................................................

.........................................................................................................................

១៦. តើលោកនាយក/នាយិកាមានសំណូមពរដូចម្តេចខ្លះ ក្នុងការចូលរួមអភិវឌ្ឍបណ្ណាល័យឱ្យមានភាពកាន់តែល្អ ប្រសើរ ?

......................................................................................................................................

......................................................................................................................................

......................................................................................................................................

.....................................................................................................................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់គ្រូ

ខ្ញុំបាទឈ្មោះ កុល ថាន ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ កំពុងធ្វើ និក្ខេបបទក្រោមប្រធានបទ៖ **ស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។** អាស្រ័យហេតុនេះ សូមលោកគ្រូ អ្នកគ្រូមេត្តាជួយឆ្លើយនូវកម្រងសំណួរនេះ តាមភាពជាក់ស្តែងរបស់ខ្លួន។ ព័ត៌មាន របស់លោកគ្រូ អ្នកគ្រូ នឹងត្រូវបានរក្សាការសម្ងាត់។ ការចូលរួមរបស់លោកនាយក នាយិកា ពិតជា មានសារៈសំខាន់ ក្នុងការ ពង្រឹងគុណភាពអប់រំនៅប្រទេសកម្ពុជាយើង។

ជាចុងក្រោយខ្ញុំបាទសូមថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូដែលបាន ចំណាយពេលវេលាក្នុងការចូលរួម ជាមួយខ្ញុំក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ។

សូមមេត្តាគូសសញ្ញា ✓ ក្នុងប្រអប់ និងបំពេញចន្លោះ នៃសំណួរនីមួយៗខាងក្រោមតាមការជាក់ស្តែងរបស់ខ្លួន។

**ផ្នែកទី១ ព័ត៌មានទូទៅ៖**

១.ភេទ............អាយុ...........ឆ្នាំ បង្រៀនថ្នាក់ទី.......................

២.មុខវិជ្ជាឯកទេស...............................។ អតីតភាពការងារជាគ្រូបង្រៀន.......................ឆ្នាំ។

៣. ជាគ្រូបង្រៀនកម្រិត

☐ កម្រិតឧត្តម ☐ កម្រិតមូលដ្ឋាន ☐ ផ្សេងទៀត

**ផ្នែកទី២ ទស្សនៈរបស់គ្រូចំពោះបណ្ណាល័យ**

៤.តើលោកគ្រូអ្នកគ្រូយល់ឃើញដូចម្តេចអំពីបណ្ណាល័យសាលាទាក់ទងនឹងការរៀនសូត្ររបស់សិស្ស?

☐ មានសារៈសំខាន់ខ្លាំងណាស់ ☐ មានសារៈសំខាន់ល្មម

☐ មានសារៈសំខាន់តិចតួច ☐ មិនមានសារៈសំខាន់

៥ តើលោកគ្រូ អ្នកគ្រូ បានប្រើប្រាស់សេវាកម្មបណ្ណាល័យ សម្រាប់ការបង្រៀន និងរៀន កម្រិតណា?

☐ ញឹកញាប់ ☐ ម្តងម្កាល ☐ កម្រ ☐ មិនធ្លាប់

៦. តើសិស្សានុសិស្សដែលលោកគ្រូ អ្នកគ្រូកំពុងបង្រៀនលើមុខវិជ្ជា របស់លោកគ្រូ អ្នកគ្រូ មានសៀវភៅសិក្សាគោលប្រើប្រាស់កម្រិតណា? *( សំគាល់៖ មានស្ទើគ្រប់គ្នា=៩០%-៩៩% , មានភាគច្រើន=៦០%-៨៩%, មានខ្លះៗ=៤០%-៥៩% , មានភាគតិច=១១%-៣៩%, ស្ទើតែគ្មាន ≤១០%)*

☐ មានគ្រប់គ្នា ☐ មានស្ទើគ្រប់គ្នា ☐ មានភាគច្រើន ☐ មានខ្លះៗ

☐ មានភាគតិច ☐ ស្ទើតែគ្មានគ្រប់គ្នា

៧. តើលោកគ្រូ អ្នកគ្រូបានជំរុញសិស្សឱ្យប្រើប្រាស់សេវាកម្មបណ្ណាល័យកម្រិតណា?

☐ ជំរុញញឹកញាប់ ☐ ជំរុញម្តងម្កាល ☐ កម្រជំរុញ ☐ មិនធ្លាប់បានជំរុញ

៨.តើបណ្ណាល័យសាលារបស់លោកគ្រូ អ្នកគ្រូ មានតភ្ជាប់បណ្តាញ Internet ឬទេ?

☐ មាន និងប្រើប្រាស់បានជាប្រចាំ ☐ មានតែប្រើប្រាស់បានម្តងម្កាល

☐ មានតែប្រើប្រាស់មិនបាន ☐ មិនមានភ្ជាប់

៩. តើលោកគ្រូ អ្នកគ្រូ យល់ឃើញបែបណា ចំពោះចំណាប់អារម្មណ៍របស់សិស្ស ក្នុងការ អានសៀវភៅ និងឯកសារស្រាវជ្រាវ?

☐ សិស្សចាប់អារម្មណ៍ខ្លាំងលើការអានសៀវភៅ និងឯកសារ ក្នុងបណ្ណាល័យ

☐ សិស្សចាប់អារម្មណ៍ខ្លាំងលើការអានឯកសារ តាមរយៈSmart Phone ផ្ទាល់ខ្លួន

☐ សិស្សភាគច្រើនមិនចូលចិត្ត អានឯកសារ និងសៀវភៅទេ

☐ ផ្សេងៗ…………………………………………………………………………………………………

១០. តើលោកគ្រូ អ្នកគ្រូមានទស្សនៈបែបណាចំពោះ បណ្ណាល័យ និងសេវាកម្មបណ្ណាល័យសាលារៀនរបស់លោកគ្រូ អ្នកគ្រូ?

☐ ល្អ ☐ ល្អបង្គួរ ☐ មធ្យម ☐ ខ្សោយ

*សូមបញ្ជាក់មូលហេតុ៖*

.............................................................................................................................................

.............................................................................................................................................

១១. តើស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យសាលារៀននេះមានបញ្ហាប្រឈមដូចម្ដេចខ្លះ? ( *អាចគូសធិកចម្លើយលើសពី មួយ )*

☐ និយ័តភាពការងារ និងមនសិការរបស់បណ្ណារក្សនៅមានកម្រិត

☐ ការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងសាលាលើបណ្ណាល័យនៅមានកម្រិត

☐ បណ្ណាល័យគ្មានឯកសារសម្រាប់អានគ្រប់គ្រាន់

☐ បន្ទប់អានសៀវភៅមិនមានផាសុខភាព

☐ គ្រូមិនបានយកចិត្តទុកដាក់ក្នុងការជំរុញសិស្សឱ្យចូលអានសៀវភៅ

☐ ផ្សេងៗ

- .........................................................................................................................
- .........................................................................................................................

- ..........................................................................................................................................
- .........................................................................................................................................

១២. តើលោកគ្រូ អ្នកគ្រូ មានយោបល់ដូចម្តេច ដើម្បីរៀបចំបណ្ណាល័យសាលាឱ្យមានលក្ខណៈល្អប្រសើរ?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់សិស្ស

ខ្ញុំបាទឈ្មោះ កុល ថាន ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ កំពុងធ្វើ និក្ខេបបទក្រោមប្រធានបទ៖ **ស្ថានភាពនៃការគ្រប់គ្រងបណ្ណាល័យនៅតាមវិទ្យាល័យធៀបនឹងស្តង់ដាបណ្ណាល័យមធ្យមសិក្សា។** អាស្រ័យហេតុនេះ សូមប្អូនៗសិស្សានុសិស្ស មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះ តាមភាពជាក់ស្តែងរបស់ខ្លួន។ ព័ត៌មាន របស់ប្អូនៗនឹងត្រូវបានរក្សាការសម្ងាត់។ ការចូលរួមរបស់ប្អូនៗ ពិតជា មានសារៈសំខាន់ ក្នុងការ ពង្រឹងគុណភាពអប់រំនៅប្រទេសកម្ពុជាយើង។

ជាចុងក្រោយខ្ញុំបាទសូមថ្លែងអំណរគុណដល់ប្អូនៗទាំងអស់ ដែលបាន ចំណាយពេលវេលាក្នុងការចូលរួម ជាមួយខ្ញុំក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ។

សូមមេត្តាគូសសញ្ញា √ ក្នុងប្រអប់ និងបំពេញចន្លោះ នៃសំណួរនីមួយៗខាងក្រោមតាមការជាក់ស្តែងរបស់ខ្លួន។

**ផ្នែកទី១ ព័ត៌មានទូទៅ៖**

១.កូដសិស្ស ......................ភេទ...............អាយុ...................ឆ្នាំ រៀនថ្នាក់ទី.........................

**ផ្នែកទី២ អំពីការសិក្សាស្រាវជ្រាវ៖**

២. តើប្អូនបានចូលអានសៀវភៅក្នុងបណ្ណាល័យញឹកញាប់ដែរឬទេ ក្នុងឆ្នាំសិក្សាថ្មីនេះ ?

☐មិនធ្លាប់ចូល ព្រោះ៖……………………………………………………………………………………

☐ ធ្លាប់ចូលម្តងម្កាល ព្រោះ៖.............................................................................................

☐ ធ្លាប់ចូលញឹកញាប់ ព្រោះ៖ ............................................................................................

៣. ក្រៅពីចូលអានឯកសារក្នុងបណ្ណាល័យ តើប្អូនស្វែងរកឯកសារស្រាវជ្រាវបន្ថែមតាមរយៈអ្វីទៀត? *( អាចធិចចម្លើយលើសពីមួយ )*

☐ រកទិញសៀវភៅនៅទីផ្សារមកអាន ☐ ស្រាវជ្រាវតាម Internet

☐ ខ្ចីមិត្តភក្តិ ☐ ផ្សេងទៀត……………………………………………

៤. ចូរប្អូនបញ្ជាក់ពីកម្រិតញឹកញាប់ តាមលំដាប់ ABCD នៃមធ្យោបាយស្វែងរកឯកសារអានបន្ថែម ៖ កំណត់សំគាល់

*( A ធ្វើញឹកញាប់ខ្លាំង B ធ្វើញឹកញាប់ដែរ C ធ្វើម្តងម្កាល D មិនធ្លាប់ធ្វើ )*

| បរិយាយ | A | B | C | D |
|---|---|---|---|---|
| ស្វែងរកឯកសារអានបន្ថែមតាមរយៈបណ្ណាល័យសាលា | | | | |
| ស្វែងរកឯកសារអានបន្ថែមតាមរយៈ ការរកទិញឯកសារនៅលើទីផ្សារ | | | | |
| ស្វែងរកឯកសារអានបន្ថែមតាមរយៈ Internet ។ | | | | |
| ខ្ចីពីមិត្តភក្តិ | | | | |

**ផ្នែកទី៣ អំពីគ្រូបង្រៀន និងនាយកសាលា ៖**

៥. តើលោកគ្រូអ្នកគ្រូរបស់ប្អូនបានជំរុញឱ្យប្អូនចូលអានសៀវភៅក្នុងបណ្ណាល័យញឹកញាប់កម្រិតណា?

☐ បានជំរុញញឹកញាប់ ☐ បានជំរុញម្តងម្កាល ☐ មិនបានជំរុញ

៦. ក្រៅពីការជំរុញឱ្យប្អូនចូលស្វែងរកឯកសារក្នុងបណ្ណាល័យសាលា តើលោកគ្រូរបស់ប្អូនបានជំរុញឱ្យ ប្អូនស្វែងរក ឯកសារតាមមធ្យោបាយអ្វីទៀត ? *( អាចធិចចម្លើយលើសពីមួយ )*

☐ ស្វែងរកឯកសារអានបន្ថែមតាមរយៈ ការរកទិញឯកសារនៅលើទីផ្សារ

☐ ស្វែងរកឯកសារអានបន្ថែមតាមរយៈ Internet

☐ ស្វែងរកឯកសារពីមិត្តភក្តិ

☐ មិនបានជំរុញ

☐ តាមមធ្យោបាយផ្សេងទៀត.............................................................................។

៧. តើលោកគ្រូអ្នកគ្រូរបស់ប្អូនបានត្រួតពិនិត្យ និងណែនាំឱ្យប្អូនថែទាំសៀវភៅសិក្សាគោលបាន ញឹកញាប់កម្រិតណា?

☐ មិនបានត្រួតពិនិត្យនិងណែនាំ ☐ បានត្រួតពិនិត្យ និងណែនាំម្តងម្កាល ☐ តែងតែត្រួតពិនិត្យណែនាំ

៨. តើក្នុងពេលប្រជុំរួមម្តងៗ លោកនាយកសាលាធ្លាប់បានជំរុញឱ្យប្អូនស្វែងរកឯកសារក្នុងបណ្ណាល័យបាន ញឹកញាប់កម្រិតណា?

☐ បានជំរុញញឹកញាប់ ☐ បានជំរុញម្តងម្កាល ☐ មិនបានជំរុញ

៩. ក្រៅពីការជំរុញឱ្យប្អូនចូលស្វែងរកឯកសារក្នុងបណ្ណាល័យសាលា តើលោកនាយករបស់ប្អូនបានជំរុញឱ្យ ប្អូនស្វែងរក ឯកសារតាមមធ្យោបាយអ្វីទៀត ? *( អាចផិចចម្លើយលើសពីមួយ )*

☐ ស្វែងរកឯកសារអានបន្ថែមតាមរយៈ ការរកទិញឯកសារនៅលើទីផ្សារ

☐ ស្វែងរកឯកសារអានបន្ថែមតាមរយៈ Internet

☐ ស្វែងរកឯកសារពីមិត្តភក្តិ

☐ មិនបានជំរុញ

☐ តាមមធ្យោបាយផ្សេងទៀត.............................................................................។

១០. តើក្នុងពេលប្រជុំរួមម្តងៗ លោកនាយកសាលាធ្លាប់បានរំលឹកណែនាំប្អូន ពីរបៀបថែទាំសៀវភៅសិក្សាគោល បានញឹកញាប់កម្រិតណា?

☐ តែងតែរំលឹក និងណែនាំ ☐ បានរំលឹក និងណែនាំម្តងម្កាល

☐ មិនបានរំលឹកនិងណែនាំ

**ផ្នែកទី៤ អំពី បណ្ណាល័យ និងបណ្ណារក្ស ៖**

ចំពោះប្អូនដែលបានឆ្លើយសំណួរទី២ ដោយ គូសធិកយកចម្លើយ ( មិនធ្លាប់ចូល ) សូមរំលងសំណួរបន្តបន្ទាប់ខាង ក្រោម៖

១១. តើបណ្ណាល័យសាលារបស់ប្អូនមានសៀវភៅអានគ្រប់គ្រាន់សម្រាប់ប្អូនធ្វើការសិក្សាស្រាវជ្រាវឬទេ?

☐ មានគ្រប់គ្រាន់ ☐ មានខ្លះៗ ☐ មិនមាន

១២. តើសៀវភៅមានចំណងជើងអ្វីខ្លះដែលប្អូនត្រូវការស្រាវជ្រាវ ដែលបណ្ណាល័យសាលារបស់ប្អូនមិនមាន?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

...................................................................................................................................

១៣.តើបណ្ណារក្សនៅសាលារបស់ប្អូន បានណែនាំពីរបៀបស្វែងរកឯកសារក្នុងបណ្ណាល័យដល់ប្អូនបានញឹកញាប់ កម្រិតណា?

☐ តែងតែណែនាំ ☐ បានណែនាំម្តងម្កាល ☐ មិនបានណែនាំ

១៤. តើបណ្ណារក្សបើកទ្វារបណ្ណាល័យសាលា ធ្វើការញឹកញាប់កម្រិតណា?

☐ បើកទ្វារជាប្រចាំ ☐ បើកទ្វារញឹកញាប់ ☐ បើកទ្វារម្តងម្កាល

១៥. តើបណ្ណារក្ស បានសម្អាតបណ្ណាល័យ បានកម្រិតណា?

☐ ជាប្រចាំ ☐ ញឹកញាប់ ☐ ម្តងម្កាល ☐ ដោយកម្រ

១៦. តើប្អូនៗមានមតិសំណូមពរអ្វីខ្លះដើម្បីចូលរួមកែលម្អបណ្ណាល័យសាលាឱ្យមានលក្ខណៈរីកចម្រើន?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

...............................................................................................................................................